# ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹងស្តីពីការមិនឈប់សម្រាកក្នុង ឱកាសបុណ្យអុំទូក ចាប់ពីថ្ងៃទី ២ ដល់ទី ៤ ខែវិច្ឆិកា ខាងមុខនេះ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ សូមជម្រាបព័ត៌មានដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា៖ ដើម្បីជួយសម្រួលដល់បងប្អូនពលករ ក្នុងការបញ្ជាក់អត្តសញ្ញាណឱ្យបានលឿន និងទាន់ពេលវេលា នាឱកាសបុណ្យអុំទូក សំពះព្រះខែ និងអកអំបុក ចាប់ពីថ្ងៃទី ២ ដល់ទី ៤ ខែវិច្ឆិកា ខាងមុខនេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ នឹងបន្តការងារបញ្ជាក់អត្តសញ្ញាណជូនដល់បងប្អូនពលករជាធម្មតា។ សូមសាធារណជន និងបងប្អូនពលករកម្ពុជាទាំងអស់ជ្រាបជាព័ត៌មាន និងបន្តផ្សព្វផ្សាយ។

## ដំណឹងផ្អាកចែកលេខរៀង ចំពោះទីតាំង(ប៊ិកស៊ីឡាតប្លាវ)

http://pheaktraprak.com/archives/ By ប្រាក់ ភក្ត្រា November 1, 2017

កាលពីថ្ងៃអង្គារ ទី31 ខែតុលា ឆ្នាំ2017 គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃ បានប្រកាសជូនដំណឹងដល់បងប្អូនពលករកម្ពុជា ដែលកំពុងត្រៀមទៅទទួលលេខរៀងធ្វើប៉ាស្ព័រ នៅការិយាល័យធ្វើប៉ាស្ព័រស្ថិតនៅហាងទំនើប Big C ឡាតប្លាវ អោយបានជ្រាបថា៖ ចាប់ពីថ្ងៃពុធទី01 ខែវិច្ឆិកា ឆ្នាំ2017 នេះតទៅ គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា ប្រចាំទីតាំងការិយាល័យ Big C ឡាតប្លាវ បានផ្អាកចែកលេខរៀងជូនបងប្អូនពលករកម្ពុជាមួយរយៈសិន អាស្រ័យហេតុនេះសូមបងប្អូនពលករកម្ពុជាទាំងអស់ ដែលត្រៀមមកទទួលលេខរៀងនៅទីតាំងខាងលើ មេត្តាជ្រៀបជាដំណឹង។ ចំពោះករណីបងប្អូនពលករកម្ពុជាដែលបានទទួលលេខរៀងធ្វើប៉ាស្ព័រនាពេលកន្លង បងប្អូនអាចធ្វើដំណើរទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅទីតាំងហាងទំនើប Big C ឡាតប្លាវ បានតាមលេខរៀងកំណត់។

## ពាក្យចចាមអារ៉ាមពលករខ្មែរម្នាក់បានទទួលមរណៈភាពនៅខេត្តរ៉ាក់យ៉ុងប្រទេសថៃ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧

កាលពីថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០១៧ នៅការិយាល័យបញ្ជាក់អត្តសញ្ញាណខេត្តរ៉ាក់យ៉ុង មានពលករកម្ពុជា១រូប ដែលមកធ្វើការបញ្ជាក់អត្តសញ្ញាណ មានអាការៈខ្យល់គរ និងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ បន្ទាប់មកនៅយប់ថ្ងៃ ខែ ឆ្នាំ ដដែល មានពាក្យចចាមអារ៉ាមថា ពលករម្នាក់នេះ បានទទួលមរណៈភាព។ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ សូមធ្វើការបញ្ជាក់ថា ព័ត៌មាននៃការទទួលមរណៈភាពនេះគឺមិនពិតឡើយ។ ដោយនៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧ ពលកររូបនោះ និងភរិយា បានត្រឡប់មកធ្វើការបញ្ជាក់អត្តសញ្ញាណពីក្រុមការងារវិញ និងទទួលបានលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) រួចរាល់ហើយ។ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ មេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយបន្ត។

# ថៃបញ្ជូនសពពលករខ្មែរម្នាក់ ដែលស្លាប់ដោយគ្រោះចរាចរមកឲ្យគ្រួសារ

https://kohsantepheapdaily.com.kh/article ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ម៉ោង ១៣:៥៦

ខេត្តបន្ទាយមានជ័យ ៖ សពពលករម្នាក់ត្រូវបានភាគីថៃធ្វើការបញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅម៉ោងជិត០៧យប់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ បន្ទាប់ពីស្លាប់ដោយគ្រោះថ្នាក់ចរាចរជិះម៉ូតូដួលខណៈចុះផ្លូវចំណោតពីលើភ្នំមួយនៅខេត្តនគររាជសីមា ប្រទេសថៃ ។

ស្ត្រីរងគ្រោះឈ្មោះ ឡូន ហៀម អាយុ៣៦ឆ្នាំ មានទីលំនៅភូមិគោកស្វាយ ឃុំប៉ុស្សស្បូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ តាមសាច់ញាតិសពប្រាប់ថា ជនរងគ្រោះមុនជួបឧប្បត្តិហេតុគ្រោះថ្នាក់នេះ បានចូលទៅធ្វើការជាកម្មករសំណង់នៅក្នុងខេត្តកើតហេតុ ។

សាច់ញាតិសពបន្តថា ជនរងគ្រោះជួបគ្រោះថ្នាក់ចរាចរកាលពីវេលាម៉ោងជាង១០ព្រឹក ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ខណៈបើកបរម៉ូតូដឹកគ្នាចុះផ្លូវចំណោតពីលើភ្នំដួលបណ្ដាលឲ្យជនរងគ្រោះស្លាប់ ឯអ្នករួមដំណើរម្នាក់ជាពលករខ្មែរដូចគ្នារងរបួសសន្លប់ស្ដូកស្ដឹង ពេលនេះកំពុងសម្រាក ព្យាបាលនៅមន្ទីរពេទ្យក្នុងខេត្តកើតហេតុ ។ ដោយជីវភាពគ្រួសារសពក្រីក្រក្រុមយោធាបាននាំគ្នាយករថយន្តសង្គ្រោះរបស់អង្គភាពកងពលតូចថ្មើរជើងលេខ ៥១ ជួយដឹកសពទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

# ស្ថានតំណាងកម្ពុជាប្រចាំម៉ាឡេស៊ី អន្តរាគមន៍ ជួយពលរដ្ឋខ្មែរ២១នាក់

https://www.dap-news.com/kh ថ្ងៃពុធ, 01 វិច្ឆិកា ២០១៧ 08:59 ដោយ: ស៊ាន កុសល ID:069

ភ្នំពេញ៖ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍ របស់ពលករ-ពលការិនីខ្មែរ ចំនួន១១នាក់ ឲ្យបានវិលមកមាតុភូមិវិញ។ បើតាម លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងនៅព្រឹកថ្ងៃទី១ វិច្ឆិកា ឆ្នាំ២០១៧នេះ បានឲ្យដឹងថា ពលករ-ពលការិនីដែលអាជ្ញាធរកម្ពុជា បានជួយអន្តរាគមន៍នោះ៖

១.ពលការិនី រិន ស្រីល័ក្ខ អាយុ២០ឆ្នាំ មកពីស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង បានទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី កាលពីខែសីហា ឆ្នាំ២០១៧ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ នៅថ្ងៃទី១២ ខែតុលា ពលការិនីបានស្នើសុំស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ ដោយសារមានជំងឺ។ ភ្នាក់ងារក្រុមហ៊ុនបានប្រគល់ថ្លៃសំបុត្រយន្តហោះ និងថ្លៃបង់ពិន័យជូនពលការិនី តាមសំណើរបស់ស្ថានទូត។

២.ពលការិនី គ្រុងម៉េង អាំង អាយុ២៥ឆ្នាំ មកពីស្រុកកោះធំ ខេត្តកណ្ដាល បានធ្វើដំណើរតាមរថយន្ត ឆ្លងកាត់ប្រទេសថៃ ទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី កាលពីខែសីហា ឆ្នាំ២០១៥។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ពលការិនីបានទៅស្ថានទូត ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ ពីព្រោះនាងពុំមានលិខិតឆ្លងដែន។

៣.ពលការិនី ងួន ស្រីនាថ អាយុ២១ឆ្នាំ មកពីស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានធ្វើដំណើរ តាមរថយន្តឆ្លងកាត់ប្រទេសថៃ ដោយខ្លួនឯង ទៅធ្វើការនៅអាហារដ្ឋានមួយ នៅម៉ាឡេស៊ី កាលពីខែឧសភា ឆ្នាំ២០១៧។

៤.ពលការិនី ពៅ សារឿន អាយុ៤០ឆ្នាំ មកពីស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង បានធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃដោយខុសច្បាប់ ទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី ពីខែសីហា ឆ្នាំ២០១៥។ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៧ ពលការិនីបានមកស្ថានទូត ស្នើសុំជួយទាមទារប្រាក់ខែ ដែលនៅសល់ពីនិយោជក និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ ដោយសារបញ្ហាសុខភាព។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជកបានប្រគល់ប្រាក់ខែដែលនៅខ្វះ និងសំបុត្រយន្តហោះជូននាង នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ ។

៥.ពលករ សួន ណាំ អាយុ១៩ឆ្នាំ ៦.ពលករ រី ឈុនឡេង អាយុ២៣ឆ្នាំ ៧.ពលការិនី ធីវធី អាយុ២២ ឆ្នាំ ៨.ពលការិនី សួន ម៉ៅ អាយុ២១ឆ្នាំ ៩.ពលការិនី សួន ណូ អាយុ៣៧ឆ្នាំ ១០.ពលការិនី ឈីវ ការ៉េ អាយុ១៧ ឆ្នាំ ពលករ-ពលការិនីទាំង៦នាក់ (លេខរៀងទី៥-១០) មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានធ្វើដំណើរតាមរថយន្ត ឆ្លងកាត់ប្រទេសថៃ ទៅធ្វើការនៅរោងចក្រប្លាស្ទិក ក្នុងរដ្ឋ Johor ប្រទេសម៉ាឡេស៊ី កាលពីខែឧសភា ឆ្នាំ ២០១៦ តាមរយៈមេខ្យល់។ និងទី(១១) ពលករ ប៊ុន អេនឌី អាយុ១៧ឆ្នាំ មកពីស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានធ្វើដំណើរតាមរថយន្ត ឆ្លងកាត់ប្រទេសថៃទៅម៉ាឡេស៊ី ដោយខ្លួនឯង និងធ្វើការនៅរោងចក្រកាត់ដេរ នៅក្នុងរដ្ឋ Johor កាលពីខែឧសភា ឆ្នាំ២០១៦។

លោក ជុំ សុនី្ទ បានបន្តថា ស្ថានទូតបានចេញលិខិតធ្វើដំណើរ និងសម្របសម្រួល ជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលករ-ពលការិនី ទាំង១១នាក់នេះ បានមកដល់អាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ តាមកាលបរិច្ឆេទខាងក្រោម៖

-ពលការិនី២នាក់ (លេខរៀងទី១និងទី២) នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង០៧:៣៥នាទីព្រឹក តាមជើងយន្តហោះ AK536 ។

-ពលការិនី ងួន ស្រីនាថ (លេខរៀងទី៣) នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង០៧:៣៥នាទីព្រឹក តាមជើងយន្តហោះ AK536។

-ពលករ៨នាក់ទៀត (លេខរៀងទី៤-១១) នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧វេលាម៉ោង១២:៥៥នាទីរសៀល តាមជើងយន្តហោះ AK538 ។

២.ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសសិង្ហបូរី បានអន្តរាគមជួយពលការិនីខ្មែរម្នាក់ ឈ្មោះ សេង សំណាង អាយុ២៧ឆ្នាំ មកពីខេត្តកំពង់ស្ពឺ ដែលបានទៅបម្រើការងារតាមផ្ទះ នៅសិង្ហបូរី កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ តាមរយៈក្រុមហ៊ុនមួយ នៅកម្ពុជា។ ដោយសារពលការិនី មានសុខភាពខ្សោយ មិនអាចបំពេញការងារបន្ត នាងបានស្នើស្ថានទូត ជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជកបានទិញសំបុត្រយន្តហោះ ហើយភ្នាក់ងារនាំពលករ បានប្រគល់លិខិតឆ្លងដែនជូន ពលការិនីវិញ។ ពលការិនី បានមកដល់អាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង១៤:៤០នាទី តាមជើងយន្តហោះJetstar 3K593។

៣.ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ បានសហការជាមួយ អាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ ចំនួន៩នាក់ ដែលចូលទៅប្រកបរបរលក់ឆ្នោត នៅប្រទេសវៀតណាម។ ពលរដ្ឋទាំង៩នាក់ មានអាយុចន្លោះពី ១ឆ្នាំដល់៤០ឆ្នាំ (ក្នុង កុមារមានចំនួន៧នាក់) មកពីស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយត្រូវបានអាជ្ញាធរវៀតណាម រៀបចំអោយស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារ សង្គមទីក្រុងហូជីមិញ មុនពេលបញ្ជូនមកស្ថានអគ្គកុងស៊ុលកម្ពុជា។

ស្ថានអគ្គកុងស៊ុលនឹងជូនពលរដ្ឋទាំង៩នាក់ មកកម្ពុជាវិញនៅថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ២០១៧ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត (ខេត្តស្វាយរៀង) ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត៕

# ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧

# ឧទ្ធរណ៍បន្ថយទោសស្ត្រីនាំនារីខ្មែរទៅការប្តីចិនពី ១៥ មក ៥ ឆ្នាំ

http://www.postkhmer.com/ Thu, 2 November 2017 គឹម សារុំ

**ភ្នំពេញៈ** ស្ត្រីជាប់ចោទម្នាក់កាលពីម្សិលមិញត្រូវបានសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ប្រកាសសាលដីកាភ្លាមៗ បន្ទាប់ពីជំនុំជម្រះដោយសម្រេចបន្ថយទោសពីជាប់គុក ១៥ ឆ្នាំមកត្រឹម ៥ ឆ្នាំវិញពាក់ព័ន្ធនាំនារីម្នាក់ទៅរៀបការប្តីនៅប្រទេសចិនកាលពីឆ្នាំ ២០១៣ នៅខេត្តព្រៃវែង។ បន្ទាប់ពីថយទៅពិភាក្សាគ្នារយៈពេលជិតមួយម៉ោងមកលោកចៅក្រម សេង ស៊ីវុត្ថា ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានអានសាលដីកានៅចំពោះមុខស្ត្រីជាប់ចោទថាក្រោយពីបានស្តាប់ការសួរដេញដោលពីខាងតំណាងមហាអយ្យការ និងស្តាប់ការសន្និដ្ឋានរបស់មេធាវី ស្ត្រីជាប់ចោទមកក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាស្ត្រីជាប់ចោទបានឆ្លើយសារភាពថាពិតជាបានរត់ការ និងជូននារីរងគ្រោះទៅដល់ប្រទេសចិនមែន។

ប៉ុន្តែលោកចៅក្រមថានារីរងគ្រោះបានរៀបការជាមួយបុរសជនជាតិចិនគឺជាការស្ម័គ្រចិត្តរបស់នាងផ្ទាល់ទេ ហើយរហូតបង្កើតបានកូនម្នាក់ និងក្រោយមកមានទម្ងន់មានកូនម្នាក់ទៀតតែត្រូវប្តីវាយឲ្យរលូតកូន។ ដោយរស់នៅមិនចុះសម្រុងគ្នានារីរងគ្រោះនោះបានសុំប្តីមកមើលជំងឺម្តាយ ហើយប្តីក៏ឲ្យមកកម្ពុជាវិញ។ លោកថ្លែងថាដោយឃើញថា ស្ត្រីជាប់ចោទមានវ័យចាស់ និងមិនបង្ខំឲ្យនារីរងគ្រោះរៀបការនោះ ដូច្នេះក្រុមប្រឹក្សាសម្រេចៈ «កែប្រែបទចោទពីបទនាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅមកជាបទការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែនវិញ និងកែប្រែទណ្ឌកម្មទោសពី ១៥ ឆ្នាំមកជាប់គុក ៥ ឆ្នាំ និងសំណង ៤០ លានរៀលមកត្រឹម ៥ លានរៀលវិញ»។

ស្ត្រីជាប់ចោទឈ្មោះ ផាត់ ឡៃ អាយុ ៥៧ ឆ្នាំដែលត្រូវចៅក្រមផ្តល់សិទ្ធិឡើងឆ្លើយបំភ្លឺក្នុងសវនាការនោះបាននិយាយថាគាត់មានកូនស្រីម្នាក់រៀបការប្តីនៅប្រទេសចិន ហើយពេលគាត់ទៅលេងកូនស្រីរបស់គាត់ត្រូវម្តាយនារីរងគ្រោះ ផ្ញើកូនស្រីម្នាក់ឈ្មោះ សេង ស៊ីណាក់ អាយុ ២៦ ឆ្នាំទៅជាមួយដើម្បីរកការងារធ្វើ។ លុះទៅដល់ប្រទេសចិននារីរងគ្រោះបានរៀបការជាមួយបុរសចិនដោយស្ម័គ្រចិត្ត និងបង្កើតបានកូនម្នាក់ទៀតផង។ ប៉ុន្តែពេលនារីនោះឈ្លោះគ្នាជាមួយប្តីក៏មកកម្ពុជាវិញបាន ៣ ឆ្នាំទើបប្តឹងសមត្ថកិច្ចឲ្យចាប់ស្ត្រីជាប់ចោទ។

ទោះយ៉ាងណារបាយការណ៍នគរបាលខេត្តព្រៃវែងបង្ហាញថាស្ត្រីជាប់ចោទ ផាត់ ឡៃ រស់នៅភូមិព្រៃកតាវ័ន្ត ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង កាលពីអំឡុងខែកក្កដាឆ្នាំ ២០១៣ បានលួងលោមនារីឈ្មោះ សេង ស៊ីណាក់ អាយុ ២៦ ឆ្នាំឲ្យទៅរៀបការប្តីនៅប្រទេសចិនដោយស្ត្រីជាប់ចោទជាអ្នករត់ការរហូតនាំនារីរងគ្រោះទៅដល់ប្រទេសចិនទៀត។ ប៉ុន្តែដោយប្តីវាយធ្វើបាបនារីរងគ្រោះបានមកកម្ពុជាវិញហើយ ៣ ឆ្នាំក្រោយទើបប្តឹងស្ត្រីជាប់ចោទ។

សំណុំរឿងនេះត្រូវសាលាដំបូងខេត្តព្រៃវែងប្រកាសសាលក្រមកាលពីខែមេសាឆ្នាំ ២០១៧ សម្រេចផ្តន្ទាទោសស្ត្រីជាប់ចោទ ១៦ ឆ្នាំ និងបង្គាប់ឲ្យសងជំងឺចិត្តទៅនារីរងគ្រោះ ៤០ លានរៀល ខណៈនារីរងគ្រោះទារសំណងចំនួន ២ ម៉ឺនដុល្លារ៕

# រដ្ឋមន្ត្រីក្រសួងការងារថៃ មួយចំនួនត្រូវ បានដកហូតមុខតំណែងបន្ទាប់ពីធ្វើត្រួតសញ្ជាតិ ជូនពលករបរទេស មានភាពយឺតយ៉ាវ

http://pheaktraprak.com/archives/ By ប្រាក់ ភក្ត្រា November 2, 2017

យោងតាមប្រភពព័ត៌មានបាន ចុះផ្សាយកាលពីថ្ងៃពុធទី01 ខែវិច្ឆិកា ឆ្នាំ2017 បានអោយដឹងថារដ្ឋមន្ត្រីក្រសួងការងារថៃ យ៉ាងហោចណាស់5នាក់ ត្រូវនាយករដ្ឋមន្ត្រីថៃ ប្ដូរដកចេញពីតំណែង បន្ទាប់ឮពីមានព័ត៌មានចចាមអារ៉ាមថារដ្ឋមន្ត្រី ទាំងនោះធ្វើឱ្យដំណើរការត្រួតសញ្ជាតិ ជូនពលករបរទេសមានភាពយឺតយាវ ក្នុងការត្រួតសញ្ជាតិជូនពលករបរទេសនាពេលកន្លងមក។ បញ្ជាក់:កាលពីថ្ងៃទី01ម្សិលមិញនេះគណៈរដ្ឋមន្ត្រីថៃ ឬហៅថាកាត់ថា(ក,ស,ធ) បានប្រើអំណាចច្បាប់មាត្រា44 ធ្វើការប្ដូរនិងដកមុខតំណែងរដ្ឋមន្ត្រីក្រសួងការងារថៃ មួយចំនួនបន្ទាប់ពីការដំណើរការត្រួតសញ្ជាតិ ជូនពលករបរទេស នៅក្នុងប្រទេសថៃ ចំនួនតិចជាងអ្វីដែលគ្រោងទុក។

## ពលករនៅថៃប្ដឹងមេខ្យល់ម្នាក់ឈ្មោះ ថៃ ធា ស៊ីលុយច្រើន

http://www.nokor-wat-news.html ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៧

ភ្នំពេញ៖ ពលករខ្មែរដែលបានទៅធ្វើការនៅប្រទេសថៃខុសច្បាប់បានស្នើសុំឲ្យសមត្ថកិច្ចពាក់ព័ន្ធជួយធ្វើអន្តរាគមន៍ និង ជួយសម្របសម្រួលក្នុងករណីមេខ្យល់ឈ្មោះ ថៃ ធា បាននាំពួកគេទៅធ្វើការនៅប្រទេសថៃទាំងខុសច្បាប់ ហើយកំពុងកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់ពួកគេយ៉ាងខ្លាំង ។

យោងតាមពលករខ្មែរម្នាក់ដែលមិនស៊ូទ្រាំជាមួយស្ថានភាពការងារដ៏លំបាក ហើយត្រូវមេខ្យល់កាត់លុយអស់ៗថៃមទៀតនោះបានថ្លែងថា ពួកគេត្រូវបានមេ ខ្យល់ឈ្មោះ ថៃ ធា ធានាអះអាងនាំទៅធ្វើ ការដោយមិនមានលិខិតស្នាមអ្វីទាំងអស់ ដោយគ្រាន់តែឲ្យបង់ប្រាក់ម្នាក់ប្រមាណ ៣៥០ដុល្លារប៉ុណ្ណោះ។ ទឹកប្រាក់៣៥០ ដុល្លារនេះត្រូវបានមេខ្យល់ឈ្មោះ ថៃ ធា អះអាងថា យកទៅធ្វើលិខិតឆ្លងដែនជូន ពួកគេនៅពេលក្រោយ ។ ពលករខ្មែររូបនេះបានរៀបរាប់ទៀតថា សម្រាប់ការធ្វើដំណើរពីកម្ពុជាទៅប្រទេស ថៃវិញត្រូវបានមេខ្យល់យកម្នាក់២០ម៉ឺនរៀល ហើយពេលទៅដល់ប្រទេសថៃពួកគេបានយកថ្លៃ១០០ដុល្លារម្នាក់បន្ថែម ទៀតក្រោមហេតុផលថា ជួររោងចក្រសម្រាប់ធ្វើការ ។

នៅពេលបានទៅធ្វើការនៅប្រទេសថៃហើយនោះក្រុមពលករទាំងនេះក៏មិនសូវសល់លុយនោះដែរបើទោះបីពួកគេប្រឹងប្រែងធ្វើការជាច្រើនម៉ោងនិងគ្មានថ្ងៃឈប់សម្រាកក៏ដោយ។ មិនសល់ដោយសារតែ មេខ្យល់ឈ្មោះ ថៃ ធា បានយកលុយពីពួកគេប្រមាណ៣៦ម៉ឺនរៀលទៀតក្នុងរយៈ ពេល៦ខែ។ ប្រាក់នេះត្រូវមេខ្យល់ ថៃ ធា អះអាងថាជាថ្លៃសម្រាប់ទិដ្ឋាការធ្វើការ ងារនៅក្នុងប្រទេសថៃរយៈពេល២ឆ្នាំ។

ពលករខ្មែរដែលអះអាងថាខ្លួនត្រូវមេខ្យល់ឈ្មោះ ថៃ ធា កេងប្រវ័ញ្ចកម្លាំងញើស ឈាមនេះបានឲ្យដឹងទៀតថា ករណីបែប នេះមិនមែនកើតមានសម្រាប់រូបគាត់តែ ម្នាក់នោះទេគឺនៅមានពលករជាច្រើននាក់ទៀតក៏រងការកេងប្រវ័ញ្ចកម្លាំងបែបនេះ ដែរហើយគ្រាន់តែពលករដែលចេញទៅ ប្រទេសថៃជំនាន់គាត់នោះមានរហូតដល់ទៅ ៣០នាក់ ។ មេខ្យល់រូបនេះបានសុំសមត្ថកិច្ចពាក់ ព័ន្ធ ជាពិសេសក្រុមការងារក្រសួងការងារដែលដឹកនាំដោយលោក ហ៊ុន ម៉ាណែត មេត្តាជួយផ្ដល់ភាពស្របច្បាប់ក្នុងការបំពេញការងារជូនពលករនៅថៃនោះផងព្រោះរហូតមកដល់ ពេលនេះបើទោះបីបង់អស់លុយជាច្រើនយ៉ាងណាក៏ដោយក៏មេខ្យល់ឈ្មោះថៃ ធា មិនបានផ្ដល់លិខិតឆ្លងដែនជូនពួកគេឡើយ ។

ពាក់ព័ន្ធនឹងការប្ដឹងរបស់ពលករខ្មែរនៅ ប្រទេសថៃនេះយើងមិនទាន់អាចស្វែងរកការបំភ្លឺពីឈ្មោះ ថៃ ធា បាននៅឡើយទេ៕ ហេង សូរិយា

## ចង់ប្តូរថៅកែ ត្រូវមើលច្បាប់ការងារជាមុនសិន (ករណីចង់ប្តូរថៅកែថ្មី)

http://pheaktraprak.com/archives/ By ប្រាក់ ភក្ត្រា November 6, 2017

ច្បាប់ការងារប្រទេសថៃ បានកំណត់លក្ខខ័ណ្ឌចំនួន5(ខ) ចំពោះករណីពលករប្តូរថៅកែថ្មីនិងការងារថ្មី.! ចំពោះពលករបងប្អូនពលករកម្ពុជា ដែលមានប៉ាស្ព័រMOU ឬក៏លិខិតឆ្លងដែនពលករបរទេស និងប័ណ្ណអនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃ យ៉ាងត្រឹមត្រូវស្របច្បាប់ តាមច្បាប់ការងាររបស់ថៃរួចនោះករណីចង់ប្តូរថៅកែថ្មីឬការងារថ្មី សូមអានលក្ខខ័ណ្ឌដូចខាងក្រោម។ ច្បាប់ការងារប្រទេសថៃ បានកំណត់លក្ខខ័ណ្ឌចំនួន5 (ខ) ដល់ពលករបរទេស ករណីចង់ប្តូរនិយោជិតថ្មី( ថៅកែថ្មី) ចំពោះពលករដែលមានកិច្ចសន្យាការងារមិនទាន់ផុតកំណត់, អានលក្ខខណ្ឌការងារដូចខាងក្រោម៖

1-និយោជិតឈប់ដួល ឬនិយោជិតស្លាប់បាត់បង់ជីវិត

2-និយោជិតក្ស័យធន,ឬក្រុមហ៊ុនត្រូវបិទទ្វារឈប់ដំណើរការ។

3-និយោជិតធ្វើទារុណកម្មលើពលករ,ដូចជាអ្នកគ្រប់គ្រងការងារវាយធ្វើបាប,បង្ខិតបង្ខំ រំលោភបំពានលើរាងកាយទាំងផ្លូវកាយនិងផ្លូវចិត្តរបស់ពលករ។

4-និយោជិតមិនគោរពតាមកិច្ចសន្យាការងារ, និយោជិតមិនគោរពតាមច្បាប់ការងារដែលក្រសួងបានកំណត់ដូចជា,ឱ្យតំលៃប្រាក់ឈ្នួលមិនសមរម្យ, មិនបើកប្រាក់ខែអោយពលករ, ធ្វើការហួសម៉ោងមិនគិត(អូទី), ថ្ងៃឈប់សម្រាកផ្សេងៗ ឬបង្ខំឱ្យពលករមានផ្ទៃពោះធ្វើការនៅពេលយប់ជាដើម។

5-និយោជិតអោយពលករធ្វើការនៅនិងកន្លែងដែលគ្មានសុវត្ថិភាពទាំងរាងកាយនិងសុខភាពរបស់ពលករ។

ក្នុងករណីខាងលើបើសិនជាបងប្អូនប្តូរនិយោជិត ត្រូវរាយការណ៍ជូនដំណឹងដល់ភ្នាក់ងារមានសមត្ថកិច្ចនៅក្នុងប្រទេសថៃជាមុនសិន.។ រៀបរៀងដោយៈប្រាក់ភក្ត្រា

## ក្រសួងការងារថៃ កំណត់ឱ្យពលករចុះឈ្មោះថ្មី ទៅយកលេខរៀងត្រួតសញ្ជាតិ ធ្វើប៉ាស្ព័រមុន

http://pheaktraprak.com/archives/ By ប្រាក់ ភក្ត្រា November 5, 2017

យោងតាមលិខិតប្រកាសរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃ បានបិទប្រកាសនៅក្នុងការិយាល័យធ្វើប៉ាស្ព័រក្នុងប្រទេសថៃកាលពីថ្មីៗ បានអោយដឹងថាចាប់តាំងពីថ្ងៃទី02 ខែវិច្ឆិកា ឆ្នាំ 2017នេះតទៅ ក្រសួងការងារថៃ ជាអ្នកកំណត់ផ្តល់លេខរៀងជូនពលករកម្ពុជាដោយខ្លួនឯង។ ក្នុងការផ្តល់លេខរៀងជូនពលករកម្ពុជានោះ ក្រសួងការងារថៃ បានបែងចែកដំណាក់កាលចេញជាពីក្រុមដូចខាងក្រោម៖

1-ចំពោះបងប្អូនពលករពលករកម្ពុជា ដែលមានលិខិតបញ្ជាក់អត្តសញ្ញាណពីក្រសួងការងារថៃ ឬហៅថា (ឯកសារសម្ភាសន៍) ក្រសួងការងារថៃបានកំណត់ឱ្យពលករ ឬ បុគ្គលដែលបានទទួលសិទ្ធិ យកឯកសារសម្ភាសន៍ (ច្បាប់ដើម) ទៅស្នើសុំលេខរៀងនៅមន្ទីរការងារថៃក្នុងតំបន់ដែលពលករស្នាក់នៅ ឬភាសាថៃហៅថា (สำนักจัดหางาน

พื้นที่) ចាប់តាំងពីថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2017 នេះតទៅ ដើម្បីយកលេខរៀងនេះទៅបញ្ជាក់អត្តសញ្ញាណ(ត្រួតសញ្ជាតិ)ធ្វើប៉ាស្ព័រ នៅក្នុងការិយាល័យដែលក្រសួងការងារថៃបានកំណត់។

2-ចំពោះពលករកម្ពុជា ដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់នៅថ្ងៃទី31 ខែមេសា ឆ្នាំ2018 វិញ គឺក្រសួងការងារថៃ បានកំណត់អោយទៅស្នើសុំលេខរៀង ដើម្បីត្រួតសញ្ជាតិបាន ចាប់តាំងពីថ្ងៃទី03 ខែមករា ឆ្នាំ2018 ដើម្បីយកទៅត្រួតសញ្ជាតិនៅតាមការិយាល័យដែលក្រសួងការងារថៃបានកំណត់។ អាស្រ័យហេតុនេះសូមបងប្អូនពលករកម្ពុជា មេត្តាជ្រាបជាដំណឹង។ រៀបរៀបដោយ÷ប្រាក់ភត្រ្តា

## កម្មករសំណង់សញ្ជាតិខ្មែរម្នាក់ ដេកស្លាប់នៅក្នុងបន្ទប់ ដោយមិនមូលហេតុ

http://pheaktraprak.com/archives/ By ប្រាក់ ភត្រ្តា November 4, 2017

កាលពីវេលាម៉ោង01យប់ថ្ងៃសៅរ៍ ទី04 ខែវិច្ឆិកា ឆ្នាំ2017 មានករណីកម្មករសំណង់សញ្ជាតិខ្មែរម្នាក់ បានដេកស្លាប់ក្នុងបន្ទប់ស្នាក់នៅក្នុងការដ្ឋានសំណង់ស្ថិតក្នុងភូមិបានធុង ឃុំធុងសុខឡា ស្រុកស៊ីរាចឆា ខេត្តឈុនបុរី ។ បច្ចុប្បន្នសាកសពកម្មករខ្មែររូបនោះ ត្រូវបានសមត្ថកិច្ចថៃ បញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យស្រុកស៊ីរាចឆា ដើម្បីរង់ចាំប្រគល់ជូនសាច់ញាតិ អោយយកទៅធ្វើបុណ្យ តាមប្រពៃណី។

## ថៃហួសចិត្ត កម្មករខ្មែររងរបួសធ្ងន់9នាក់ តែតៃកុងឡានកុហក់ ថាគ្មានមនុស្សរងរបួសទេ

http://pheaktraprak.com/archives By ប្រាក់ ភត្រ្តា November 3, 2017

កាលពីថ្ងៃទី30 ខែតុលា ឆ្នាំ2017 កន្លងទៅថ្មីនេះ មានករណីគ្រោះថ្នាក់ចរាចរក្រឡាប់រថយន្តឈ្នួលដឹកអ្នកដំណើរមួយគ្រឿងបណ្តាលពលករកម្ពុជាចំនួន9នាក់រងរបួសយ៉ាងធ្ងន់ធ្ងរ។ ករណីនេះបានកើតឡើងនៅវេលាម៉ោង 10 ព្រឹក នៅត្រង់ចំណុចផ្លូវជាតិលេខ359 ខាស៊ីនសន-ខេត្តស្រះកែវ ស្ថិតនៅក្នុងភូមិ6 ឃុំខៅម៉ៃកែវ ស្រុកកាបីនបុរី ខេត្តប្រាជីនបុរី ប្រទេសថៃ ប្រភពពីកន្លែងកើតហេតុដំបូងដែគេប្រទះឃើញរថយន្តម៉ាកToyota comener ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ6884 ទីក្រុងបាងកក កំពុងក្រឡាប់ផ្អៀងម្ខាងនៅលើផ្លូវជាតិ ព្រំប្រទល់ជាប់ខេត្តស្រះកែវ។

តាមការត្រួតពិនិត្យនៅកន្លែងក្នុងរថយន្តកើតហេតុលើកដំបូង គេមិនឃើញមានមនុស្សរងរបួសឡើយ ហើយបើតាមភ្នាក់ងារសង្គ្រោះចុះទៅដល់កន្លែងកើតហេតុ បានសួរទៅអ្នកបើកបររថយន្តToyota ខាងលើបានប្រាប់ភ្នាក់ងារសង្គ្រោះថា ការក្រឡាប់រថយន្តនេះមិនមានមនុស្សរងគ្រោះឡើយ មានតែឥវ៉ាន់រងការខូចខាតបន្តិចបន្តួចប៉ុណ្ណោះ។ លុះភ្នាក់ងារសង្គ្រោះស្រុកកាបីនបុរី បានចាកចេញពីកន្លែងកើត ស្រាប់តែបានទទួលដំណឹងរាយការណ៍តាមរយៈវិទ្យុទាកទង់របស់(មូលនិធិសង្គ្រោះទីក្រុងបាងកក) ដែលធ្វើដំណើរឆ្លងកាត់កន្លែងកើតហេតុ បានប្រទះឃើញមនុស្សប្រុសស្រីមួយចំនួនកំពុងស្រែកទ្រហោយំក្បែរមាត់ព្រៃ បន្ទាប់ពីរងគ្រោះដោយសារក្រឡាប់ឡានដឹកអ្នកដំណើរខាងលើ។ ភ្លាមៗនោះភ្នាក់ងារសង្គ្រោះស្រុកការប៊ុនបុរីបានវិលត្រឡប់ទៅដឹកជនរងគ្រោះម្តងទៀតដើម្បីបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ ស្រុកកាប៊ុនបុរី។ លុះតម្រួតទើបដឹងថា រថយន្តToyotaខាងលើស៊ីឈ្នួលដឹកពលករកម្ពុជាគ្មានឯកសារចុះទៅជាយដែនថៃ-ខ្មែរនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត តែអ្នកបើកបររថយន្តងងុយដេកបានធ្វើឲ្យរថយន្តក្រឡាប់តែម្តង។

## ពលករខ្មែរ៣នាក់ទៀតហើយដែលសមត្ថកិច្ចថៃចាប់ខ្លួន ពេលចូលកាប់ឈើក្រញូងក្នុងខេត្តបូរីរាំប្រទេសថៃ

http://cambodiapolice.com/blog/archives/ ម៉ោង 11:38 am ថ្ងៃទី06 វិច្ឆិកា 2017 14

**បន្ទាយមានជ័យ ៖** ពលករខ្មែរ៣នាក់ទៀតហើយដែល សមត្ថកិច្ចថៃចាប់ខ្លួនពេលចូលកាប់ឈើក្រញូងក្នុងតំបន់ស្រុនួនកិនដែងកាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ថិតក្នុងខេត្តបូរីរាំប្រទេសថៃ។ ព័ត៌មានបានអោយដឹងថាមានប្រជាពលរដ្ឋចំនួន៣នាក់ ត្រូវបានកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួនខណៈពេលដែលលួចកាប់ឈើក្រញូងនៅក្នុងតំបន់ស្រុនួនកិនដែងខេត្តបូរីរាំ ដែលឈមក្នុងខេត្តឧត្តរមានជ័យចាប់មានឈើក្រញូងជាច្រើនដំនិងរណាដៃធំសម្រាប់លួចកាត់ឈើក្រញូង។

គួររំលឹកថា៖កាលពីកន្លងទៅថ្មីៗនេះសម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា បញ្ហាច្រករបៀងខុសច្បាប់ត្រូវបិទអោយអស់មិនអោយមានបើសិនមានអ្នកដែលទទួលខុសត្រូវមានកម្លាំងនគបាលការពារព្រំដែនគោកនិងយោធាការពារដែន។ ព្រោះបញ្ហាច្រករបៀងខុសច្បាប់គឺត្រូវបានកងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនបានលួចបើកច្រករបៀងល្មើសច្បាប់ឃុបឃិតជាមួយមេខ្យល់អោយពលខ្មែរលួចចូលកាប់ឈើប្រទេសជិតខាងដោយខុសច្បាប់។

សម្តេចក្រឡាហោមដាក់វិធានការចំពោះកម្លាំងនគរការពារព្រំដែនគោក និងកម្លាំងយោធារការពារព្រំដែនបើសិនមានលួចបើកច្រករបៀងល្មើសនិងច្បាប់គឺត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ព្រោះការលួចបើកច្រករបៀងឃុបឃិតជាមួយមេខ្យល់និងឈ្មួញលួចចូលកាប់ឈើក្រញូងខុសច្បាប់ត្រូវសមត្ថកិច្ចប្រទេសជិតខាងចាប់បានដាក់គុកនិងប្រវ៉ាក់។ ដើម្បីចូលរួមការពារសុវត្ថិភាពប្រជាពលរដ្ឋត្រូវលុបបំបាតអោយអស់មិនអោយមានលួចបើកច្រករបៀងដោយល្មើសច្បាប់ឡើយ ៕ ដោយ៖ចន្ត្រា

## អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវប្រទេសថៃបានបញ្ជូនសាកសពពលករខ្មែរ២នាក់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត

http://cambodiapolice.com/blog/archives/ 11:05 am 6 វិច្ឆិកា 2017 15

**បន្ទាយមានជ័យ ៖** សពប្រជាពលរដ្ឋខ្មែរ ២នាក់ដែលបានទទួលមរណៈភាពនៅក្នុងប្រទេសថៃ ត្រូវបានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវប្រទេសថៃបានបញ្ជូនមកស្រុកកំណើតវិញកាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

សាកសពពលករខ្មែរ ២នាក់ដែលបញ្ជូនមករួមមានទី១-ឈ្មោះ ឡៃ ហួន ភេទប្រុស អាយុ២៩ឆ្នាំ មុខរបបកម្មករសំណង់ នៅខេត្តឈុនបូរីប្រទេសថៃបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ រស់នៅភូមិពោធិ៍ពីរដើម ឃុំរហាត់ទឹក ស្រុកមង្គលបូរី ទី២-ឈ្មោះ សួន ភ័ណ ភេទស្រី អាយុ២៦ឆ្នាំ មុខរបបកម្មករសំណង់ ក្រុងបាងកកប្រទេសថៃ ដែលស្លាប់ដោយសារជំងឺក្អកធ្លាក់ឈាមរហូតដល់ស្លាប់កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ រស់នៅភូមិគោកព្រិចឃុំតាផូ ស្រុកស្វាយចេក។ មន្ត្រីអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវបានប្រាប់ថា សាកសពពលករខ្មែរ២នាក់ដែលត្រូវបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែខេត្តបន្ទាយមានជ័យដើម្បីប្រគល់ជូនសាច់ញាតិទទួលយកធ្វើបុណ្យតាមប្រពៃណី ៕ ដោយ: ចន្ត្រា

# ស្ថានទូតព្រះរាជណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ សូមជូនដំណឹងដល់សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជា

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok November 2 at 8:57pm

យោងតាមសារព័ត៌មាន Fresh News ដែលបានចុះផ្សាយនាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ ករណីជនឆបោកឈ្មោះ ថៃ ជា បានបោកប្រាស់ពលករ តាមរយៈការធានារៀបចំបែបបទស្របច្បាប់អោយពលករបានមកធ្វើការក្នុងប្រទេសថៃ។ ស្ថានទូតព្រះរាជណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ សូមជូនដំណឹងដល់សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជាជ្រាបថា ដើម្បីជៀសវាងការឆបោកពីសំណាក់មេខ្យល់ សូមបងប្អូនដែលមានបំណងចូលមកធ្វើការក្នុងប្រទេសថៃដោយស្របច្បាប់ ទំនាក់ទំនងទៅទីភ្នាក់ងារជ្រើសរើសឯកជន ដែលបានទទួលការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស ដូចមានបញ្ជីឈ្មោះជូនភ្ជាប់។

ក្នុងករណីបងប្អូនពលករមានការគៀបសង្កត់ ឬបំបិទសិទ្ធិសេរីភាពក្នុងការបំពេញការងារនៅក្នុងប្រទេសថៃ ឬជួបប្រទេះនូវបញ្ហាផ្សេង សូមទំនាក់ទំនងមកស្ថានទូតព្រះរាជណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ តាមរយៈលេខទូរសព្ទ ០២៩៥៧៥៨៥១ ០៨៦៧៩៩៩៩៥៧ ០៩៤០៩២៥៩០៥ ០៩២៨០៥០៥៦១ ០៦៤៧៥៤៧៤០១ ។

## ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧

## អាមេរិកណាធ្លាប់ជាប់ទោសរំលោភផ្លូវភេទកុមារ ត្រូវបានកត់ត្រាក្នុងប៉ាស្ព័រ

http://www.postkhmer.com Tue, 7 November 2017 Daphne Chen

**ភ្នំពេញ:** ជនជាតិអាមេរិកដែលធ្លាប់ជាប់ទោសពីបទល្មើសផ្លូវភេទលើកុមារឥឡូវនេះនឹងត្រូវកំណត់អត្តសញ្ញាណនៅក្នុងទំព័រខាងក្រោយលិខិតឆ្លងដែន។ នេះបើយោងតាមក្រសួងការបរទេសអាមេរិកដែលបានប្រកាសកាលពីសប្តាហ៍មុនមកនេះ។ គោលនយោបាយនេះត្រូវបានតម្រូវក្រោមច្បាប់ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១៦ ដែលមានគោលបំណងការពារកុមារពីការរំលោភបំពានផ្លូវភេទ ឬកេងប្រវ័ញ្ចនៅក្នុងប្រទេសដទៃៗ។ ច្បាប់នេះត្រូវបានរិះគន់ដោយក្រុមតស៊ូមតិអាមេរិកមួយចំនួនដែលគាំទ្រអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលនិយាយថា ច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើរំលោភបំពានផ្លូវភេទគឺមានលក្ខណៈទូលំទូលាយពេក។ ទោះយ៉ាងណាក្តីការកែប្រែនៃច្បាប់នេះត្រូវបានស្វាគមន៍ដោយមន្ត្រីរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា ដែលនិយាយថា ពួកគេមិនមានធនធានដើម្បីពិនិត្យប្រវត្តិរូបទៅលើជនបរទេសដែលព្យាយាមចូលមកក្នុងប្រទេស។

លោក សុខ វាសនា នាយកនៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃបានថ្លែងថានាយកដ្ឋាននឹងធ្វើការបណ្តុះបណ្តាលមន្ត្រីអន្តោប្រវេសន៍ ដើម្បីពិនិត្យការកំណត់សម្គាល់នៅពេលពួកគេត្រូវបានជូនដំណឹងជាផ្លូវការអំពីការកែប្រែដោយរដ្ឋាភិបាលអាមេរិក។ លោក វាសនា បានថ្លែងបន្តថា៖ «[ច្បាប់នេះ] ជួយយើងកំណត់អត្តសញ្ញាណអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ ដោយសារភាគច្រើនបំផុតយើងមិនចង់ឲ្យពួកគេចូលក្នុងប្រទេសកម្ពុជានោះទេ»។

អ្នកកំណត់អត្តសញ្ញាណនឹងរារាំងមិនឲ្យមនុស្សមួយចំនួនចូលក្នុងប្រទេសដូចជា Robert Boehlein ដែលជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទជនជាតិអាមេរិកដែលធ្លាប់ជាប់ទោស និងកំពុងប្រឈមមុខនឹងបទចោទប្រកាន់រំលោភសេពសន្ថវៈលើកុមារអាយុ ៥ ឆ្នាំក្នុងខេត្តបាត់ដំបងបន្ទាប់ពីចាកចេញពីសហរដ្ឋអាមេរិកដោយមិនជម្រាបដល់អាជ្ញាធរ។

ទោះយ៉ាងណាក្តីលោក Jim McCabe នាយកនៃអង្គភាពការពារកុមារបានថ្លែងថាសេចក្តីសម្រេចដាក់ឲ្យមានការសរសេរនៅទំព័រខាងក្រោយ «ហាក់បីដូចជារាងខ្សោយ» ដោយលើកឡើងនូវក្តីបារម្ភថាវាអាចនឹងត្រូវបិទបាំង ឬខកខានមិនបានសរសេរដោយមន្ត្រីអន្តោប្រវេសន៍។ លោក McCabe បានអំពាវនាវឲ្យអាមេរិកធ្វើតាមប្រទេសអូស្ត្រាលីដែលបានបោះឆ្នោតកាលពីខែមិថុនាដើម្បីដកហូតលិខិតឆ្លងដែនរបស់អ្នកប្រព្រឹត្តបទល្មើសផ្លូវភេទលើកុមារដែលធ្លាប់ជាប់ទោសនៅពេលមានសំណើពី «អាជ្ញាធរសមត្ថកិច្ច»។ ច្បាប់នេះត្រូវបានរំពឹងថានឹងចូលជាធរមាននៅខែធ្នូ (ខាងមុខនេះ)។ លោក McCabe បានថ្លែងបន្តថា៖ «វាជារឿងអកុសល»។ «ខ្ញុំគិតថាពួកគេ [អាមេរិក] បាត់បង់ឱកាសដើម្បីមានឥទ្ធិពលក្នុងការរារាំងពលរដ្ឋអាមេរិកមិនឲ្យធ្វើដំណើរទៅក្រៅប្រទេសបំពានការរំលោភបំពានទៅលើកុមារ»។

បើតាមការប្រកាសរបស់ក្រសួងការបរទេសអាមេរិកបានឲ្យដឹងថា អ្នកកំណត់អត្តសញ្ញាណនឹងសរសេរថា «អ្នកកាន់លិខិតឆ្លងដែននេះធ្លាប់ជាប់ទោសពីបទល្មើសផ្លូវភេទទៅលើកុមារ និងជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលស្ថិតនៅក្រោមច្បាប់អាមេរិក ២២ រដ្ឋផ្នែក ២១២ ខ (គ) (១)»។ ជនល្មើសផ្លូវភេទដែលធ្លាប់ជាប់ទោសដែលដាក់ពាក្យសុំលិខិតឆ្លងដែនជាលើកទីមួយនឹងត្រូវបានចេញជាមួយនឹងការកំណត់អត្តសញ្ញាណ។ ចំពោះអ្នកដែលមានលិខិតឆ្លងដែនរួចហើយនឹងត្រូវដកលិខិតឆ្លងដែន ហើយនឹងត្រូវតម្រូវឲ្យដាក់ពាក្យសុំលិខិតឆ្លងដែនថ្មី៕ PS

## រយៈពេល២ថ្ងៃភាគីថៃបានបន្តបញ្ជូនសាកសពពលករខ្មែរចំនួន៤នាក់ទៀតតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត

http://cambodiapolice.com/blog/archives ម៉ោង 12:09 am ថ្ងៃទី07 វិច្ឆិកា 2017

បន្ទាយមានជ័យ ៖ ភាគីថៃបានបន្តបញ្ជូនសាកសពពលករខ្មែរចំនួន២នាក់ទៀតតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតជូនដល់សាច់ញាតិយកទៅធ្វើបុណ្យកាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ខេត្តបន្ទាយមានជ័យ។ សាកសពដែលត្រូវភាគីថៃបញ្ជូនមានទី១.ឈ្មោះ លឹម សុខហ៊ុយ ភេទស្រី អាយុ៤៩ឆ្នាំ ជាកម្មករសំណង់មានស្រុកកំណើតស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ទី២.ឈ្មោះ សាលី ប៉ាសើត ភេទប្រុសអាយុ៤៧ឆ្នាំ ជាងសំណង់ មានស្រុកកំណើតនៅភូមិ/ឃុំបត់ត្រង់ស្រុកមង្គលបូរី។

មន្ត្រីអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវបានប្រាប់ថា៖សាកសពពលករខ្មែរចំនួន២នាក់ ដែលត្រូវភាគីថៃបញ្ជូនមកតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យមានទី១.ឈ្មោះ លឹម សុខហ៊ុយ ភេទស្រី អាយុ៤៩ឆ្នាំ ជាកម្មករសំណង់នៅទីក្រុងបាងកក ដែលស្លាប់ដោយជំងឺក្រោយពេលដែលបញ្ជូនដល់មន្ទីរពេទ្យក្រុងបាងកកប្រទេសថៃកាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ទី២.ឈ្មោះ សាលី ប៉ាសើត ភេទប្រុស អាយុ៤៧ឆ្នាំជាងសំណង់ខេត្តឈុនបូរី បានដេកស្លាប់ក្នុងបន្ទប់ដោយជំងឺគាំងបេះដូងកាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៧។ មន្ត្រីអគ្គកុងស៊ុលបានបញ្ជាក់ថា៖រយៈពេល២ថ្ងៃនេះភាគីថៃបានបញ្ជូនសាកសពពលករខ្មែរចំនួន៤នាក់មានសាកសពបុរស

២នាក់ និងស្ត្រី២នាក់ដែលស្លាប់ដោយជំងឺ៣នាក់និងស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ម្នាក់ដែលត្រូវបានបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតដើម្បីប្រគល់ជូនសាច់ញាតិទទួលយកធ្វើបុណ្យតាមប្រពៃណី ។ដោយៈចន្ទ្រា

**LPNជំរុញឲ្យប្រើគ្រឿងស្កេនផ្ទៃមុខនិងកែវភ្នែក ចំពោះការបញ្ជាក់អត្តសញ្ញាណ លើពលករបរទេស**

http://pheaktraprak.com/archives/ By ប្រាក់ ភក្ត្រា November 7, 2017

យោងតាមប្រភពព័ត៌មានពីប្រទេសថៃបានអោយដឹងថា រដ្ឋមន្ត្រីក្រសួងការងារថៃត្រៀមនិងទំនិញឧបករណ៍ស្កេនផ្ទៃមុខនិងកែវភ្នែក ដើម្បីយកមកប្រើប្រាស់ក្នុងការត្រួតសញ្ជាតិ លើកម្មករចំណាក់ស្រុកបរទេសដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងធ្វើប្រវត្តិរូប។ កាលពីថ្ងៃច័ន្ទទី06 ខែវិច្ឆិកា ឆ្នាំ2017 ម្សិលមិញនេះ លោក Som phung ប្រធានមូលនិធិលើកកម្ពស់ជីវិតពលករ ក្នុងប្រទេសថៃដែលហៅកាត់ថា LPN បានស្នើទៅរដ្ឋមន្ត្រីក្រសួងការងារថៃ ដែលទើបតែឡើងតំណែងថ្មី ជំរុញអោយយកគ្រឿងស្កេនផ្ទៃនិងមុខកែវភ្នែកមកត្រួតសញ្ជាតិលើពលករ បរទេសទាំងបីសញ្ជាតិ ដើម្បីភាពងាយស្រួលក្នុងការបញ្ជាក់ បុគ្គលិករបស់ពលករនិងងាយស្រួលក្នុងការត្រួតពិនិត្យប្រវត្តិរូបអត្តសញ្ញាណរបស់ពលករផងដែរ។

## ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧

## ស្ថានទូតខ្មែរនៅម៉ាឡេស៊ី និងវៀតណាមជួយសង្គ្រោះពលករ-ពលការិនីខ្មែរ៦នាក់

https://kohsantepheapdaily.com.kh ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង១០:០៤ ស.សុខុម អ៊ាង ម៉េងឡេង

រាជធានីភ្នំពេញ ៖ អ្នកនាំពាក្យក្រសួងការបរទេស លោកជុំ សុន្ទរី បានបញ្ជាក់ឱ្យដឹងតាមសារអេឡិចត្រូនិចកាលពីថ្ងៃទី៧ វិច្ឆិកា ថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន៤នាក់ និងប្រទេសវៀតណាម២នាក់។

ពលការិនី សឿន ម៉ារឌី អាយុ២៩ឆ្នាំ មកពីខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និង (២) ពលការិនី សាំង ស៊ន អាយុ៣៨ឆ្នាំ មកពីស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃទៅធ្វើការជាអ្នកបោសសំអាតនៅម៉ាឡេស៊ី កាលពីខែមីនា ឆ្នាំ២០១៧ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយចង់ត្រឡប់មកកម្ពុជាវិញ ពលការិនីទាំងពីរនាក់ បានស្នើសុំកិច្ចអន្តរាគមន៍ពីស្ថានទូតនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧។ អ្នកទាំងពីរ បានទទួលប្រាក់ខែគ្រប់ចំនួនពីនិយោជក។ ពលការិនី ណាង ធូយ អាយុ២៧ឆ្នាំ មកពីស្រុកតំបែរ ខេត្តកំពង់ចាម បានទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី កាលពីខែកញ្ញា ឆ្នាំ២០១៦។ ដោយសារពលការិនីចង់ត្រឡប់មកកម្ពុជាវិញ ភ្នាក់ងារក្រុមហ៊ុន បាននាំនាងទៅស្ថានទូតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ព្រមទាំងប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅខ្វះ ជូនពលការិនី។

ពលករ គង់ សុខុន អាយុ៣៥ឆ្នាំ មកពីស្រុកបាណន់ ខេត្តបាត់ដំបង បានទៅរកការងារធ្វើនៅម៉ាឡេស៊ី កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ តាមរយៈមេខ្យល់។ ក្រោយដឹងថាចាញ់បោកមេខ្យល់ គាត់បានលួចរត់ចេញពីផ្ទះមេខ្យល់ និងទៅលាក់ខ្លួននៅផ្ទះមិត្តភក្តិនៅរដ្ឋ Selangor។ ស្ថានទូតបានទទួលយកពលករ គង់ សុខុន មកស្នាក់នៅក្នុងស្ថានទូតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ និងបានចេញលិខិតធ្វើដំណើរ និងឧបត្ថម្ភថ្លៃបង់ពិន័យឲ្យការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយអង្គការអន្តរជាតិទេសន្តប្រវេសន៍(IOM) បានឧបត្ថម្ភសំបុត្រយន្តហោះជូនពលករ តាមសំណូមពររបស់ស្ថានទូត។

ពលការិនី៣នាក់ បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង០៩និង៥០នាទីព្រឹក តាមជើងយន្តហោះ MH754។ ចំណែកពលករ គង់ សុខុន បានមកដល់នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង០៩និង៥០នាទីព្រឹក តាមជើងយន្តហោះ AK754។ លោកបានលើកឡើងថា៖ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម បានសហការជាមួយនគរបាល ខេត្តឡាក់សឺន ជួយសង្គ្រោះនារីខ្មែរ២នាក់ ឈ្មោះ ព.ឡ.ល អាយុ២១ឆ្នាំ និងឈ្មោះ ល.ច អាយុ២៧ឆ្នាំ មកពីស្រុកឆ្លូង ខេត្តក្រចេះ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំយកទៅរៀបការនៅប្រទេសចិន។ នារីទាំងពីរនាក់ បានចេញដំណើរពីកម្ពុជានៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ ទៅដល់ខេត្តឡាក់សឺន នៅថ្ងៃទី២៩ ខែតុលា ដោយមេខ្យល់រង់ចាំទទួលនៅចំណតរថយន្ត ហើយបម្រុងនាំឆ្លងដែនទៅប្រទេសចិន ប៉ុន្តែត្រូវបាននគរបាលខេត្តឡាក់សឺន ឃាត់ខ្លួនសួរនាំ។ ស្ថានទូតបានទទួលនារីទាំងពីរនាក់មកស្នាក់នៅបណ្តោះអាសន្ន ដើម្បីរៀបចំសំណុំបែបបទបញ្ជូនមកកម្ពុជាវិញ ហើយពួកគេបានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង១៤និង១០នាទី។

## ឯកសារសម្រាប់ ទៅស្នើសុំលេខរៀងនៅ មន្ទីរការងារថៃ ដើម្បីត្រួតសញ្ជាតិ ធ្វើប៉ាស្ព័រ ចំពោះពលករចុះឈ្មោះថ្មី.!

http://pheaktraprak.com/archives By ប្រាក់ ភក្ត្រា November 8, 2017

ចំពោះបងប្អូនពលករខ្មែរធ្វើការរស់នៅក្នុងប្រទេសថៃ ដែលតែងតែសួរមកយើងខ្ញុំថា តើឯកសារទៅសុំលេខរៀងនៅមន្ទីការងារថៃ ឬភាសាថៃហៅថា (กรมการจัดหาจังหวัด หรือ สำนักจัดหาเขต)តើត្រូវត្រៀមឯកសារអ្វីទៅខ្លះដើម្បីសុំលេខរៀងបានដោយខ្លួនឯង។ ចម្លើយមានពីយ៉ាងដូចខាងក្រោម៖

A-ករណីថៅកែថៃទៅសុំលេខរៀងនៅមន្ទីការងារដោយខ្លួនឯងដោយមិនចាំបាច់នាំពលករទៅជាមួយ ក៏បាន។ ថៅកែថៃត្រូវនាំយកនៅឯកសារបញ្ជាក់របស់ពលករ ដែលចេញដោយក្រសួងការងារថៃ ឬភាសាសាមញ្ញហៅថា (លិខិតសម្គាសន៍)ច្បាប់ដើម។ អត្តសញ្ញាណសញ្ជាតិថៃរបស់ថៅកែថៃ ច្បាប់ថតចម្លង។ សៀវភៅគ្រួសាររបស់ថៅកែថៃ ច្បាប់ថតចម្លង។

B-ករណីពលករធ្វើដំណើរទៅសុំលេខរៀងនៅមន្ទីការងារថៃដោ យខ្លួនឯងឬផ្ទេរសិទ្ធិអោយបុគ្គលដទៃទៀតជាអ្នកទៅយកជំនួស។ អត្តសញ្ញាណរបស់ថៅកែថៃ (สำเนาบัตรประจำตัวประชาชนนายจ้าง) ច្បាប់ថតចម្លងចំនួន2 សន្លឹក។ សៀវភៅគ្រួសាររបស់ថៅកែថៃ (ทะเบียนบ้านนายจ้าง) ច្បាប់ថតចម្លងចំនួន2 សន្លឹក។ លិខិតប្រគល់សិទ្ធិចេញពីថៅកែថៃ (หนังสือมอบอำนาจ) អោយបុគ្គលណាមួយតាមការបញ្ជាក់។

បញ្ជាក់÷លេខរៀងដែលបងប្អូនទៅសុំនៅមន្ទីការងារថៃ គឺមិនមានគិតថ្លៃសេវាកម្មអ្វីទាំងអស់។ សូមបងប្អូនពិនិត្យមើលលើលិខិតលេខរៀងអោយបានច្បាស់អំពីថ្ងៃ ខែ ឆ្នាំ ដែលក្រសួងកំណត់អោយពលករទៅត្រួតសញ្ជាតិ (ធ្វើប៉ាស្ព័រ) នៅទីតាំងនីមួយក្នុងប្រទេសថៃ។ ចំពោះព័ត៌មានលម្អិតសូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ1694 រៀងរាល់ម៉ោងធ្វើការ។ រៀបរៀងប្រែសម្រួលដោយ: ប្រាក់ ភក្ត្រា

## ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧

## កំពូលជម្រះក្តីបុរសចិន ២ នាក់រឿងនាំស្ត្រីខ្មែររៀបការប្តី

http://www.postkhmer.com Thu, 9 November 2017 គឹម សារុំ

**ភ្នំពេញ:** តុលាការកំពូលកាលពីម្សិលមិញបានបើកសវនាការជំនុំជម្រះជនជាតិចិន ២ នាក់ពាក់ព័ន្ធនឹងករណីប៉ុនប៉ងនាំស្ត្រីខ្មែរ ៤ នាក់ទៅរៀបការប្តីនៅប្រទេសចិនប្រព្រឹត្តនៅឆ្នាំ ២០១៤ ដែលនារីរងគ្រោះត្រូវសមត្ថកិច្ចឃាត់ខ្លួនបាននៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ តាមរបាយការណ៍នគរបាលយុត្តិធម៌បានបង្ហាញថាបុរសជាតិចិនឈ្មោះ HUDEHUA អាយុ ៣៩ ឆ្នាំមានប្រពន្ធខ្មែរ និងម្នាក់ទៀតឈ្មោះ XIE TAO SHENG អាយុ ៥៨ ឆ្នាំ

បានរត់ការរៀបចំឯកសារនៅស្ថានទូតចិនប្រចាំកម្ពុជា ឯស្ត្រីខ្មែរ ៤ នាក់មានអាយុចាប់ពី ២១ ដល់អាយុ ២៤ ឆ្នាំ។ អង្គហេតុបង្ហាញបន្តថាក្រោយពីរត់ការបំពេញបែបបទចប់ឈ្មោះ XIE TAO SHENG បានឲ្យឈ្មោះ HU DE HUA នាំស្ត្រីរងគ្រោះទាំង ៤ នាក់ធ្វើដំណើរកាត់តាមក្រុងប៉ោយប៉ែត តែត្រូវសមត្ថកិច្ចឃាត់នៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១៤ ។

សំណុំរឿងនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញប្រកាសផ្តន្ទាទោសម្នាក់ៗ ៧ ឆ្នាំនៅថ្ងៃទី ២ កញ្ញាឆ្នាំ ២០១៥ ដោយចោទពីបទ «ប៉ុនប៉ងនាំចេញសម្រាប់ឆ្លងដែន» តែជនជាប់ចោទមិនសុខចិត្តប្តឹងមកឧទ្ធរណ៍ ហើយត្រូវសាលាឧទ្ធរណ៍តម្កល់សាលក្រមដដែល។ ជនជាប់ចោទ HU DE HUA បានប្រាប់ចៅក្រមថាគាត់ធ្វើការក្នុងរោងចក្រកាត់ដេរ និងមានប្រពន្ធខ្មែរហើយមានកូនតូច ៥ នាក់ឯស្ត្រីទាំង ៤ នាក់ក៏ជាកម្មកររោងចក្រដែរ។ ពេលនោះគាត់ត្រូវឈ្មោះ ឆាយ ពឹងឲ្យជួយនាំស្ត្រីរងគ្រោះទៅដាក់ត្រឹមទល់ដែនកម្ពុជា-ថៃ គេឲ្យ ២០០ ដុល្លារគាត់ក៏នាំទៅ។ ជនជាប់ចោទបន្តទៀតថាពួកគេបានពឹងឲ្យគាត់ជួយរត់ការបំពេញបែបបទដើម្បីទៅរៀបការប្តីនៅប្រទេសចិន ហើយបុរសជនជាតិចិនឈ្មោះ ឆាយ បានទូរស័ព្ទប្រាប់ខ្លួនឲ្យនាំពួកនាងទៅព្រំដែនប៉ោយប៉ែត។ «ខ្ញុំពិតជាដឹងកំហុសហើយសូមតុលាការពិចារណាផង»។

ចំពោះឈ្មោះ XIE TAO SHENG ក៏ប្រាប់ចៅក្រមដែរថាគាត់មកកម្ពុជាក្នុងឆ្នាំ ២០១០ ហើយមុនកើតហេតុគាត់ត្រូវឈ្មោះ ឆាយ ផ្តាំផ្ញើឲ្យជួយចាត់ចែងស្ត្រីទាំងនោះគេនឹងឲ្យលុយតែមិនទាន់ទទួលលុយផងក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន។

លោកព្រះរាជអាជ្ញា ជុំ សំបាន តំណាងមហាអយ្យការសន្និដ្ឋានថារឿងនេះឆ្លងតាមអង្គហេតុបង្ហាញថាជនជាប់ចោទត្រូវសមត្ថកិច្ចចាប់ក្នុងបទល្មើសជាក់ស្តែង។ «ដូច្នេះសាលាឧទ្ធរណ៍ផ្តន្ទាទោសជនជាប់ចោទទាំង ២ នាក់ត្រឹមត្រូវហើយ»។

លោក អ៊ី ចំរើន មេធាវីការពារសិទ្ធិឲ្យឈ្មោះ XIE TAO SHENG សន្និដ្ឋានថា កំណត់ហេតុដែលសមត្ថកិច្ចកសាងគ្មានការបកប្រែច្បាស់លាស់ទេ ហើយរឿងនេះកូនក្តីលោកបដិសេធរហូត។ តែតុលាការនៅតែជឿរបាយការណ៍នោះដដែល។ លោកថា៖ «នារីរងគ្រោះពួកគេស្ម័គ្រចិត្តទេ ព្រោះពួកគេថាឃើញនារីខ្មែររៀបការប្តីចិនមានជីវភាពធូរធារ ដូច្នេះពួកគេពឹងឲ្យកូនក្តីខ្ញុំជួយ។ ម្យ៉ាងតុលាការចោទកូនក្តីខ្ញុំពុំមានជាតុផ្សំគ្រប់គ្រាន់ទេសូមតុលាការកំពូលបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ជម្រះឡើងវិញ»។ ក្រោយជំនុំជម្រះលោក ចៅក្រម ស៊ឹង បញ្ញាវុឌ្ឍ ប្រធានក្រុមប្រឹក្សាជំនុំជម្រះថ្លែងថាសាលដីកានឹងប្រកាសនៅថ្ងៃទី ១៧ ខែវិច្ឆិកាខាងមុខ៕

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរពីរនាក់ឱ្យសមត្ថកិច្ចកម្ពុជាវិញ

http://www.rasmeinews.com November 10, 2017

(ឧត្តរមានជ័យ)៖អាជ្ញាធរថៃបានបញ្ជូពលរដ្ឋខ្មែរចំនួន២នាក់ដែលបានឆ្លងព្រំដែនខុសច្បាប់ចូលកាប់ឈើឱ្យមកសមត្ថកិច្ចកម្ពុជា ប្រចាំច្រកជាំសាងាំព្រំដែនវិញ។ ការប្រគល់ស្ថិតនៅភូមិជើងភ្នំឃុំត្រពាំប្រីយស្រុកអន្លង់វែងកាលពីវេលាម៉ោង៣រសៀលថ្ងៃទី៩ខែវិច្ឆិកាឆ្នាំ២០១៧។

សមត្ថកិច្ចកម្ពុជាការពារព្រំដែនបានឱ្យដឹងថា ពលរដ្ឋខ្មែរចំនួន២នាក់ ដែលអាជ្ញាធរថៃប្រគល់ឱ្យសមត្ថកិច្ចកម្ពុជាវិញនៅច្រកព្រដែនខាងលើឈ្មោះ គៀនចាន់ សារឿន ភេទប្រុស អាយុ១៧ឆ្នាំ រស់នៅភូមិតូច ឃុំក្រាំងស្នាយស្រុកឈូក ខេត្តកំពត។ ជននេះបានចូលឆ្លងព្រំដែនចូលកាប់ឈើខុសច្បាប់ និងបានជាប់គុកនៅខេត្តអូរប៊ុន(ថៃ)។ ឃាត់ខ្លួនតាមច្រកត្រពាំងបី ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ។ ឈ្មោះ ឃួន អ៊ុំ ភេទប្រុស អាយុ៦២ឆ្នាំ រស់នៅភូមិតាឡាត់ខ្វាយ ឃុំតាឡាត់ខ្វាយ ស្រុកព្រៃវែង ខេត្តព្រៃវែង បានចូលឆ្លង

ព្រំដែនកាប់ឈើខុសច្បាប់តាមច្រកទំនប់ដាច់ ក្នុងឃុំ-ស្រុកត្រពាំងប្រាសាទ ជាមួយគ្នា ហើយត្រូវបានចាប់ខ្លួនថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៧ ជាប់គុកនៅខេត្តស៊ីសាកេតប្រទេស(ថៃ)៕ S/ដោយៈសហការី

## ពលករខ្មែរ ចំណាកស្រុកខុសច្បាប់ 9 នាក់ត្រូវកម្លាំងតម្រួតខេត្ត ស្រះកែវចាប់ខ្លួន

http://pheaktraprak.com/archives By ប្រាក់ ភក្ត្រា November 10, 2017

ពលករខ្មែរចំណាកស្រុកមកខេត្តសៀមរាប,បន្ទាយមានជ័យ,ត្បូងឃ្មុំចំនួន 9នាក់ត្រូវកម្លាំងសមត្ថកិច្ចតម្រួតខេត្តស្រះកែវ ប្រទេសថៃ ធ្វើការចាប់ខ្លួនបន្ទាប់ពីឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ។ ករណីឃាត់ខ្លួនពលករខ្មែរខុសច្បាប់នេះបានកើតឡើងកាលពីវេលាម៉ោង05:00ល្ងាច ថ្ងៃព្រហស្បតិ៍ទី09 ខែវិច្ឆិកា ឆ្នាំ2017 បន្ទាប់ពីកម្លាំងសមត្ថកិច្ចតម្រួតខេត្ត ស្រះកែវបានប្រដេញចាប់រថយន្តម៉ាកtoyota ពណ៌សមួយគ្រឿងពាក់ស្លាកលេខ6396ក្លែងក្លាយ បើកបរដោយបុរសជនជាតិថៃវ័យ40ឆ្នាំម្នាក់ ក្នុងការឆែកឆេរក្នុងរថយន្ត សមត្ថកិច្ចបានរកឃើញពលករខ្មែរប្រុសស្រីចំនួន9នាក់ ខណៈពេលកំពុងធ្វើដំណើរក្នុងរថយន្ត ខាងលើនៅលើទឹកដីខេត្តស្រះកែវ។ យោងតាមប្រភពព័ត៌មានថៃបានឱ្យដឹងថា ពលករខ្មែរខុសច្បាប់ទាំង9នាក់បានធ្វើដំណើរឆ្លងដែនខុសច្បាប់តាមរយៈច្រកព្រំដែនធម្មជាតិ ស្រុកអូរបើជាន់ខេត្តបន្ទាយមានជ័យ ពលករខ្មែរត្រូវបានចាប់ខ្លួននោះរួមមានៈ

1- ឈ្មោះ ម៉េត ភេទប្រុស អាយុ37 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្តបន្ទាយមានជ័យ

2-ឈ្មោះ ណា ភេទប្រុស អាយុ20 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្ត បន្ទាយមានជ័យ

3-ឈ្មោះ ឡាត ភេទប្រុស អាយុ20 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្ត ត្បូងឃ្មុំ

4-ឈ្មោះ រ៉េន ភេទប្រុស អាយុ24 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្តសៀមរាប

5-ឈ្មោះ អន ភេទស្រី អាយុ26 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្តបន្ទាយមានជ័យ

6-ឈ្មោះ សេន ដាវី ភេទស្រី អាយុ24 ឆ្នាំសញ្ជាតិខ្មែរ រស់នៅក្នុងខេត្ត បន្ទាយមានជ័យ

7-ឈ្មោះ រួន ភេទស្រី អាយុ30 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្តសៀមរាប

8-ឈ្មោះ ស្រី រួត ភេទស្រី អាយុ30ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្តត្បូងឃ្មុំ

9-ឈ្មោះ ពិត ភេទប្រុស អាយុ10 ឆ្នាំ សញ្ជាតិខ្មែរ រស់នៅក្នុងខេត្តបន្ទាយមានជ័យ

តាមការត្រួតពិនិត្យរបស់កម្លាំងសមត្ថកិច្ចតម្រួតថៃបានបញ្ជាក់ថាពលករខ្មែរទាំង9នាក់ គ្មានឯកសារចេញចូលប្រទេសថៃតាមផ្លូវច្បាប់ទេ។ នៅពេលវេលាបន្តបន្ទាប់កម្លាំងសមត្ថកិច្ចថៃដដែលបានឃាត់រថយន្តម៉ាក(ប៉ាសេរ៉ូ)ពាក់ស្លាក2940 ឈុនបុរីមួយគ្រឿងទៀត ព្រមទាំងឆែករកឃើញសម្ភារៈប្រើប្រាស់ខោអាវ,បារីបរទេសមួយចំនួននៅក្នុងរថយន្តខាងលើព្រមទាំងឃាត់ខ្លួនបានអ្នកបើកបររថយន្តជនជាតិថៃ2នាក់ ។ តាមចម្លើយសារភាពរបស់អ្នកបើកបររថយន្តToyota បានប្រាប់ថា រូបគេបានដឹកពលករខ្មែរទាំងអស់មកពីឃុំកូកសូង ស្រុកអារញ្ញ ទៅខេត្តឆាក់ឈើងសៅ ក្នុងតំលៃមនុស្សម្នាក់1.000បាត ការដឹកមនុស្សខុសច្បាប់បែបនេះជាលើកដំបូងត្រូវតម្រួតចាប់តែម្តង។

ប្រភពពីពលករការីនីឈ្មោះ សេន ដាវី បានប្រាប់អោយដឹងថា រូបនាងមានឯកសារធ្វើការនៅក្នុងប្រទេសថៃត្រឹមត្រូវ តែនៅពេលចុះមកផ្ទះបានផ្ញើរឯកសារទាំងអស់អោយថៅកែរក្សាទុក ព្រោះអាងថាមិនអីក្រោយសាកសួរពលករខ្មែរទាំងអស់ត្រូវបានសមត្ថកិច្ចថៃប្រគល់ជូនតម្រួតអន្តោប្រវេសន៍ខេត្តស្រះកែវ បន្តចាត់វិធានការតាមផ្លូវច្បាប់។ ដកស្រង់ព័ត៌មាន:Thairath.co.th

# កុមារខ្មែរជាច្រើននាក់មិនបានចូលសាលាខណៈឪពុកម្ដាយយកតាមពេលធ្វើការនៅថៃ

http://www.rfa.org/khmer/news ដោយ អាស៊ីសេរី 2017-11-08

កុមារខ្មែរជាច្រើននាក់ មានអាយុចន្លោះពី៦ ទៅ ១០ឆ្នាំ ដែលទៅតាមឪពុកម្ដាយធ្វើការងារនៅទីក្រុងបាងកក ប្រទេសថៃ ប្រឈមមុខជួបគ្រោះ មិនចេះអក្សរនៅពេលអនាគត ព្រោះពួកគេភាគច្រើនមានអាយុជិត ១០ឆ្នាំទៅហើយ នៅមិនបានចូលសាលារៀនដូចកូនអ្នកដែលមានជីវភាពធូរធារ នៅកម្ពុជានោះឡើយ។ តើមូលហេតុអ្វីបានជាឪពុកម្ដាយចាំបាច់យកកូនទៅធ្វើការជាមួយ ដោយមិនបានឲ្យរៀនសូត្របែបនេះ?

តាំងពីម៉ោង ៧ព្រឹក ទល់ព្រលប់ស្ទើររៀងរាល់ថ្ងៃ ក្រុមពលករខ្មែរដែលធ្វើការនៅទីក្រុងបាងកកភាគច្រើនពួកគេហាក់មិនបានយកចិត្តទុកដាក់រឿងការអប់រំ ប្រៀនប្រដៅដល់កូនៗ របស់ពួកគេនោះទេ ដោយឪពុកចេញទៅធ្វើការបាត់ ចំណែកឯម្ដាយក៏ទៅធ្វើការដោយខ្លួន ហើយទុកកូនរបស់ពួកគេ ឲ្យរស់នៅឯកោតាមយថាកម្មនៅក្នុងផ្ទះដែលមានបន្ទប់តូច ធ្វើពីស័ង្កសីមើលថៃដោយខ្លួនឯង។ កំពុងសម្រាកនៅក្នុងបន្ទប់ស្នាក់នៅជាមួយប្រពន្ធ និងកូនតូច ២នាក់ ក្នុងបន្ទប់ នៅទីក្រុងបាងកក ប្រទេសថៃ លោក ព្រឹម វ៉ាន់ស៊ី រៀបរាប់ក្នុងទឹកមុខស្រពោនថា លោកមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ ហើយមកធ្វើការងារ ជាកម្មករសំណង់ជាមួយប្រពន្ធ និងកូនតូច២នាក់ នៅទីក្រុងបាងកក ជាង ៩ខែហើយ ដោយបានប្រាក់ឈ្នួល ៣២០បាត ឬប្រមាណ ៤ម៉ឺនរៀលក្នុងមួយថ្ងៃ។ បុរសសម្បុរសណ្ដែកបាយរ៉ៃ ៣២ឆ្នាំរូបនេះ បន្ថែមដោយសម្ដីមួយៗថា មូលហេតុដែលលោកនាំប្រពន្ធ និងកូនៗមកធ្វើការនៅប្រទេសថៃ ដោយសារជីវភាពក្រីក្រ ហើយជំពាក់ប្រាក់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ជាង ២ពាន់ដុល្លារអាមេរិក។ លោកបន្ថែមទៀតថា សព្វថ្ងៃលោកធ្វើការងារសន្សំប្រាក់យកសងគេជិតអស់ហើយ នៅសល់តែជាង២ម៉ឺនបាត ឬប្រមាណ៦០០ដុល្លារទៀតអស់ហើយ។លោកអះអាងទៀតថា អំឡុងពេលធ្វើការនៅប្រទេសថៃ គឺកូនរបស់លោកមិនបានចូលសាលារៀននោះទេ ហើយលោកក៏ព្រួយបារម្ភពីអនាគតរបស់ពួកគេដែរ តែលោកថា មិនដឹងធ្វើយ៉ាងណាព្រោះជីវភាពក្រីក្រ ទើបបង្ខំចិត្តមករស់នៅស្រុកគេ។ «»លោក ព្រឹម វ៉ាន់ស៊ី មានកូនប្រុសចំនួន ២នាក់ ពួកគេទៅនៅជាមួយឪពុកម្ដាយ ដែលធ្វើការនៅប្រទេសថៃទាំងអស់គ្នា កូនទី១ អាយុប្រហែល ៣ឆ្នាំ និងកូនប្រុសច្បងអាយុ ៩ឆ្នាំ។ ខណៈដែលឪពុកម្ដាយទៅធ្វើការអស់ កុមារទាំងនោះតែងនាំគ្នារត់ប្រឡែងលេង ជាមួយកុមារដទៃទៀតនៅតាមមាត់ផ្លូវក្នុងទីក្រុងបាងកកយ៉ាងសប្បាយ ដោយមិនគិតពីអ្វីទាំងអស់។

ចំណែក ពលករដែលត្រូវជាម្ដាយរបស់កុមារទាំង ២នាក់ អ្នកស្រី ផង់ សៅរី ថ្លែងថា អ្នកស្រីក៏អាណិតកូនៗដែរ ក៏ប៉ុន្តែគ្មានជម្រើសផ្សេងក្រៅពីទៅធ្វើជាកម្មករសំណង់នៅប្រទេសថៃទេ ព្រោះនៅផ្ទះឯស្រុកកំណើតគ្មានការងារធ្វើ ហើយម្យ៉ាងជំពាក់លុយគេច្រើនគ្មានប្រាក់សងគេ ទើបមករស់នៅប្រទេសគេមួយរយៈ។ ស្ត្រីសម្បុរស្រអែមរ៉ៃ ៣០ឆ្នាំរូបនេះ បន្ថែមថា អ្នកស្រីចេញពីបន្ទប់ទៅធ្វើការ បែកពីកូនតាំងពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ នៅពេលសម្រាកហូបបាយថ្ងៃ ទើបត្រឡប់មកវិញម្ដង។ ប៉ុន្តែ អ្នកស្រីអះអាងថា អំឡុងពេលពួកគាត់ធ្វើការនោះ ប្រមាណ ២ម៉ោងអ្នកស្រីក៏បានផ្លាស់គ្នាជាមួយប្ដីរបស់គាត់ទៅមើលកូនម្ដងម្នាក់ ព្រោះខ្លាចពួកគេមានបញ្ហាអ្វី នឹងអាចជួយពួកគេបានទាន់ពេល។

ស្រដៀងគ្នានេះដែរ ពលករមកពីខេត្តបន្ទាយមានជ័យម្នាក់ទៀត អ្នកស្រី ផង់ យក់ រៀបរាប់ថា អ្នកស្រីមានកូនស្រីម្នាក់អាយុ ៧ឆ្នាំហើយ ដោយនាងបាននាំកូនមករស់នៅជាមួយអំឡុងពេលធ្វើការងារ នៅទីក្រុងបាងកកដែរ ម្យ៉ាងទៀតកូនអ្នកស្រីមិនបានចូលសាលារៀនទេ។ ស្ត្រីវ៉ៃ ២៥ឆ្នាំរូបនេះ បន្តថា មូលហេតុដែលនាំកូនមកជាមួយ ព្រោះនៅផ្ទះគ្មានអ្នកមើលថៃ ដូច្នេះទើបសម្រេចនាំកូនមកនៅជាមួយប្រសើរជាងទុកកូនចោលគ្មានអ្នកមើល។

ផ្ទះដែលក្រុមពលករស្នាក់នៅ ធ្វើការក្នុងប្រទេសថៃនោះ គឺធ្វើពីកំណាត់ឈើ ចន្ទល់សល់ ពីធ្វើសំណង់ ក្នុងទំហំទទឹងប្រមាណ ៣ម៉ែត្រ និងបណ្ដោយ ៣ម៉ែត្រ ប្រក់ដំបូលស័ង្កសី ដោយមានបន្ទប់ជាប់ៗគ្នា មានប្រមាណ

៤០បន្ទប់ ចែកចេញជា ៣ជួរ ទល់មុខគ្នា ដោយទុកចន្លោះផ្លូវដើរកណ្ដាលប្រមាណ ១ម៉ែត្រកន្លះ។ រីឯនៅខាងមុខបន្ទប់នីមួយៗ យើងឃើញមានការដាក់ហាលខោអាវរយីងរយោង របស់ពួកគាត់រៀងៗខ្លួន។ ក្នុងចំណោមនោះ មានពលករខ្មែរប្រមាណ ៧០នាក់ ហើយពួកគាត់ភាគច្រើនមកពីខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ក្នុងនោះយើងឃើញមានកុមារអាយុចន្លោះពី ៦ឆ្នាំ ទៅ១០ឆ្នាំ ប្រហែលជិត ១០នាក់ ហើយពួកគេមួយចំនួនបានមករស់នៅជាមួយអាណាព្យាបាលជាង ២ឆ្នាំក៏មាន គឺពុំបានទៅរៀនសូត្រដូចកូនអ្នកស្រុក នៅឯខាងក្នុងប្រទេសនោះទេ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc) ខេត្តបន្ទាយមានជ័យលោក ស៊ុំ ច័ន្ទគា លើកឡើងថា ករណីពលករនាំកូនទៅរស់នៅខណៈពេលធ្វើការនៅប្រទេសថៃនេះ ជារឿងមិនល្អឡើយ ព្រោះពួកគេប្រឈមនឹងជួបការមិនចេះអក្សរ និងគ្មានអនាគត។ លោក ស៊ុំ ច័ន្ទគា បន្ថែមថា កាលណាកុមារដែលជាទំពាំងស្នងឫស្សី របស់ជាតិមិនបានរៀនសូត្រជាច្រើននាក់ និងជះឥទ្ធិពលអាក្រក់នៅក្នុងសង្គមជាតិ នាំឲ្យអភិវឌ្ឍន៍រីកចំរើនទៅមុខយឺត។ សព្វថ្ងៃពលករខ្មែរដែលធ្វើការនៅប្រទេសថៃ មានជាង ១លាន់នាក់។ លោក ស៊ុំ ច័ន្ទគា ប៉ាន់ប្រមាណថា សព្វថ្ងៃកុមារដែលទៅរស់នៅជាមួយឪពុកម្ដាយ ខណៈពួកគេធ្វើការងារ នៅប្រទេសមួយនេះមានរាប់ពាន់នាក់ ដោយភាគច្រើនមិនបានចូលសាលារៀនឡើយ៕

## ឥណ្ឌូនេស៊ីគ្រោងបញ្ជូនកម្មករនេសាទខ្មែរ៤នាក់មកកម្ពុជាក្រោយចាប់ខ្លួន

http://vodhotnews.com ដោយ លោក ពេជ្រ ចំរុង ថ្ងៃព្រហស្បតិ៍ ទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ម៉ោង 5:08 PM

អាជ្ញាធរឥណ្ឌូនេស៊ីថា គ្រោងនឹងបញ្ជូនពលរដ្ឋខ្មែរ ៤នាក់ ដែលចូលនេសាទខុសច្បាប់ ក្នុងប្រទេសនេះត្រឡប់មកកម្ពុជាវិញ។ យោងតាមការផ្សាយរបស់សារព័ត៌មាន The Jakata Post នៅថ្ងៃព្រហស្បតិ៍នេះថា កម្លាំងល្បាតសមុទ្រឥណ្ឌូនេស៊ី បានឃាត់ខ្លួនជនជាតិខ្មែរ ៤នាក់ នៅក្បែរកំពង់ផែ Belawan ភាគឦសាននៃកោះស៊ូម៉ាត្រា កាលពីថ្ងៃទី១៦ ខែតុលា ដោយចោទថា បានចូលទៅនេសាទខុសច្បាប់ក្នុងតំបន់សេដ្ឋកិច្ចដែនទឹករបស់ខ្លួន និងប្រើប្រាស់នាវា ដែលមានទង់ជាតិម៉ាឡេស៊ី។ បើតាម The Jakata Post អាជ្ញាធរឥណ្ឌូនេស៊ី អះអាងថា បច្ចុប្បន្ន កំពុងរកការសហការជាមួយស្ថានទូតកម្ពុជា ប្រចាំនៅទីនោះ ដើម្បីសម្រួលឲ្យពួកគេ អាចវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងខែវិច្ឆិកានេះ៕

## ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

## ថៃបើកយុទ្ធនាការ ត្រួតពិនិត្យឯកសារពលករចំណាកស្រុកខុសច្បាប់

http://www.trolldee.com/archives/ November 11, 2017

កាលពីថ្ងៃទី09 ខែវិច្ឆិកា ឆ្នាំ2017កន្លងទៅ លោកអភិបាលស្រុកបាងឡេន ខេត្តណាខនប៉ាធុមប្រទេសថៃ បានដឹកនាំកម្លាំងតម្រួត, ទាហាន អាជ្ញាធរមូលដ្ឋាន ប្រមាណជាង50នាក់ ចុះត្រួតពិនិត្យ ឯកសារពលករចំណាកស្រុកដែលកំពុងធ្វើការនៅក្នុងផ្សា(ផែរប្លា) ស្ថិតនៅក្នុងស្រុកបាងឡេន ខេត្តណាខនប៉ាធុម ។ ការចុះត្រួតពិនិត្យឯកសាររបស់ពលករនេះ គឺតាមនយោបាយរបស់ក្រសួងការងារថៃ ដើម្បីទប់ស្កាត់ពលករចំណាកខុសច្បាប់ដែលគ្មានឯកសារធ្វើការ ហើយលួចលាក់ធ្វើការដោយគ្មានច្បាប់អនុញ្ញាត និងត្រួតពិនិត្យឯកសារបញ្ជីឈ្មោះពលករដែលបានចុះឈ្មោះថ្មីនាពេលកន្លងមក។

## ទីតាំងធ្វើប៉ាស្ព័រ ក្នុងខេត្តសង់ក្លាមានភាពស្ងប់ស្ងាត់ជាងមុន

http://www.trolldee.com/archives/ November 11, 2017

ទីតាំងត្រួតសញ្ជាតិជូនដល់ពលករកម្ពុជានៅក្នុងខេត្តសង់ក្លារៀងស្ងើយមនុស្សបន្ទាប់ពីថៃប្តូរចែកលេខរៀងបន្ទាប់ពីក្រសួងការងារថៃ បានចាត់ចែងប្តូរកម្មវិធីមកចែកលេខរៀងជូនពលករកម្ពុជា ដោយខ្លួនឯងគេសង្កេតឃើញថា នៅក្នុងទីតាំងត្រួតសញ្ជាតិ ជូនបងប្អូនពលករកម្ពុជានៅក្នុងខេត្តសង់ក្លា ប្រទេសថៃ មានសភាពស្ងប់ស្ងាត់ជាងមុន។ ដោយសារក្រសួងការងារថៃ បានរៀបចំអោយពលករកម្ពុជា ដែលបានចុះឈ្មោះថ្មីកាលពី 2ខែមុន ដើម្បីទៅយកលេខរៀង ចូលត្រួតសញ្ជាតិមុនពេលកំណត់។ ព្រោះពលករកម្ពុជាដែលចុះឈ្មោះថ្មី មានលិខិតបញ្ជាក់ចេញពីក្រសួងការងារថៃ មានសុពលភាពស្នាក់នៅក្នុងប្រទេសថៃ ត្រឹមតែ2ខែប៉ុណ្ណោះ ដូច្នេះក្រសួងការងារថៃបានរៀបចំអោយពលករចុះឈ្មោះថ្មីទាំងអស់ត្រួតសញ្ជាតិអោយចប់សព្វគ្រប់មុនថ្ងៃទី31 ខែធ្នូ ឆ្នាំ2017។ ចំពោះពលករកម្ពុជាដែលមានប័ណ្ណស៊ីម្ពូផុតកំណត់នៅថ្ងៃទី31 ខែមិនា ឆ្នាំ2017 អាចយកទៅយកលេខនៅមន្ទីការងារថៃ ចាប់តាំងពីថ្ងៃទី03 ខែមករា ឆ្នាំ2018 ខាងមុខនេះ។

## ទីតាំងត្រួតសញ្ជាតិ ក្រុងថេប និងរ៉ាក់យ៉ង លេខរៀងពេញ

http://www.trolldee.com/archives/ November 11, 2017

កាលពីថ្ងៃទី09 ខែវិច្ឆិកា ឆ្នាំ2017 មន្ទីរការងារថៃចេញសេចក្តីចេញប្រកាសជូនដំណឹងដល់បងប្អូនពលករកម្ពុជា ដែលបានទទួល លេខរៀងពីការងារថៃ ខណៈពេលនេះទីតាំងត្រួតសញ្ជាតិជូនបងប្អូនពលករកម្ពុជា ទាំងនៅទីក្រុងបាងកក និងខេត្តរ៉ាក់យ៉ង បានពេញលេខរៀងអស់ហើយ។ នៅសល់តែទីតាំងត្រួតសញ្ជាតិ នៅខេត្តសង់ក្លា ប៉ុណ្ណោះដែលមិនទាន់ពេញ អាស្រ័យហេតុនេះសូមបងប្អូនពលករខ្មែរទាំងអស់ជ្រាបជាដំណឹង ចំពោះព័ត៌មានលំអិត សូមបងប្អូនទំនាក់ទំនងទៅកាន់លេខទូរស័ព្ទ1694 /ភាសាខ្មែរ។

## ថៅកែថៃ សម្តែងការព្រួយបារម្ភបន្ទាប់ពីលេខរៀងអស់

http://www.trolldee.com/archives/ November 12, 2017

ថៅកែថៃកំពុងព្រួយបារម្ភរឿងត្រួតសញ្ជាតិធ្វើប៉ាស្ព័រជូនពលករកម្ពុជា បន្ទាប់ពីទៅយកលេខរៀងនៅមន្ទីរការងារថៃ តែអស់ ហើយកន្លែងធ្វើប៉ាស្ព័រលេខរៀងពេញទៀត។ យោងតាមបណ្តាញសង្គមទំនាក់ទំនងហ្វេសប៊ុកប្រទេសថៃ បានអោយដឹងថា ថៅកែជនជាតិថៃកំពុងគ្រប់គ្រងពលករកម្ពុជាអោយធ្វើការ បានសម្តែងការព្រួយបារម្ភអំពីបញ្ហានាំពលករកម្ពុជាទៅបញ្ជាក់អត្តសញ្ញាណ(ធ្វើប៉ាស្ព័រ) អោយបានទាន់ពេលវេលាតែត្រូវជួបបញ្ហាបន្ទាប់ពីក្រសួងការងារថៃបានផ្អាកចែកលេខរៀងជូន ដោយសារលេខរៀងអស់។ ការព្រួយបារម្ភនេះបានកើតឡើងបន្ទាប់ពីរាជរដ្ឋាភិបាលថៃ បានកំណត់អោយពលករបរទេសដែលចុះឈ្មោះកាលពី2ខែមុន ត្រូវទៅបញ្ជាក់អត្តសញ្ញាណ(ធ្វើប៉ាស្ព័រ) អោយចប់សព្វគ្រប់នៅមុនថ្ងៃទី31 ខែធ្នូ ឆ្នាំ2017 ខាងមុខនេះ បើមិនដូច្នេះទេ គឺមិនអាចស្នាក់នៅធ្វើការក្នុងប្រទេសថៃបានទៀតឡើយ ។

## ពលករកម្ពុជាកំពុងព្រួយបារម្ភ រឿងផ្តល់លេខរៀង ធ្វើប៉ាស្ព័ររបស់មន្ទីរការងារថៃ

http://www.trolldee.com/archives/ November 13, 2017

ពលករកម្ពុជាកំពុងព្រួយបារម្ភរឿងបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រនៅក្នុងប្រទេសថៃ បន្ទាប់ពីមានភាពអាក់អេួលរឿងលេខរៀងរបស់មន្ទីរការងារថៃ។ ពលករកម្ពុជាកំពុងធ្វើការនៅក្នុងប្រទេសថៃប្រមាណជិត70ម៉ឺននាក់ បានសម្តែងការព្រួយបារម្ភ អំពីបញ្ហាចែកលេខរៀងបញ្ជាក់អត្តសញ្ញាណរបស់មន្ទីរការងារថៃ បន្ទាប់ពីក្រសួងការងារថៃបានទាមទារផ្តល់លេខរៀងជូនពលករកម្ពុជាដោយខ្លួនឯងកាលពីថ្ងៃទី10 ខែវិច្ឆិកាកន្លងទៅ។ ក្នុងការផ្តល់លេខរៀងរបស់មន្ទីរការងារថៃប៉ុន្មានថ្ងៃកន្លងមកនេះ គឺភាគច្រើនបានតែពួកក្រុមហ៊ុនរកស៊ីរត់ការធ្វើឯកសាររបស់ថៃប៉ុណ្ណោះដែលបានលេខរៀងធ្វើប៉ាស្ព័រ ចំណែកឯថៅកែថៃវាយរងដែលចង់សុំរៀងធ្វើប៉ាស្ព័រអោយពលករដោយខ្លួនឯងគឺមិនអាចទៅទាន់ពួកក្រុមហ៊ុនឡើយ ដូចជាឧទាហរណ៍ប៉ុន្មានថ្ងៃមុននេះក្រសួងការងារថៃប្រកាសចែកលេខរៀងតែ 5 ថ្ងៃសោះស្រាប់តែប្រាប់ថាអស់លេខរៀងបាត់ទៅហើយ។

បញ្ហានេះហើយ ដែលធ្វើឲ្យពលករកម្ពុជាមានការព្រួយបារម្ភ ព្រោះរយៈពេលបញ្ជាក់អត្តសញ្ញាណរបស់ពលករកម្ពុជាចុះឈ្មោះថ្មីនៅសល់ត្រឹមតែជាង45ថ្ងៃប៉ុណ្ណោះនឹងផុតកំណត់ហើយ តែហាក់បីដូចជាភាគីថៃមិនសូវយកចិត្តទុកដាក់លើរឿងនេះទាល់តែសោះ។

## ពលករខ្មែរម្នាក់ស៊ីឈ្នួលលក់បាយ ដេកស្លាប់នៅប្រទេសថៃ

http://ppt-news.net ចេញផ្សាយ ថ្ងៃទី 13/11/2017

ខេត្តបន្ទាយមានជ័យ ៖ រថយន្តថៃមួយគ្រឿងបានដឹកបញ្ជូនសពពលករខ្មែរម្នាក់មកប្រគល់ឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត កាលពីវេលាម៉ោងជិត៣រសៀល នាថ្ងៃទី១០ វិច្ឆិកា ២០១៧នេះ ក្រោយដែលដេកស្លាប់សង្ស័យខ្យល់គ នៅខេត្តឈុនបូរី ប្រទេសថៃ។ សមត្ថកិច្ចបានឲ្យដឹងថា ជនរងគ្រោះឈ្មោះ ចែម យឹម ភេទប្រុស អាយុ២៩ឆ្នាំ ជាកម្មករស៊ីឈ្នួលលក់បាយឲ្យថៅកែថៃក្នុងខេត្តឈុនបូរី និងមានទីលំនៅភូមិត្រពាំងរាំង ឃុំអភិវឌ្ឍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ តាមសាច់ញាតិសពប្រាប់ថា ជនរងគ្រោះបានដេកស្លាប់ក្នុងបន្ទប់ជួល លុះម៉ោងជាង១រសៀល ថ្ងៃទី៩ វិច្ឆិកា២០១៧ មិនឃើញទៅធ្វើការដូចសព្វមួយដង ខណៈសាច់ញាតិទៅរុញទ្វារមើលទើបដឹង។ សពត្រូវបានសាច់ញាតិជួលរថយន្តដឹកបន្តទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី៕

## មន្ត្រីទំនាក់ទំនងព្រំដែនច្រកអូរអន្លក់ ត្រូវថៃចាប់ខ្លួនពេលចូលទៅដឹកគ្រញូង

http://cambodiapolice.com/ ម៉ោង 11:22 am ថ្ងៃទី13 ខែវិច្ឆិកា ឆ្នាំ2017

បាត់ដំបង៖ ជនសង្ស័យចំនួនពីរនាក់ ដែលម្នាក់ជាប្រជាពលរដ្ឋ និងម្នាក់ទៀតមាននាទី ជាមន្ត្រីយោធា ក្នុងអង្គភាពទំនាក់ទំនងការងារព្រំដែនកម្ពុជា ថៃ ប្រចាំច្រកតំបន់ អូរអន្លក់ ត្រូវបានភាគីថៃចាប់ខ្លួន រួមជាមួយនឹងរថយន្តពីរគ្រឿង ព្រមទាំងវត្ថុតាងដែលជាឈើគ្រញូងមួយចំនួនផងដែរ ខណៈដែលជនសង្ស័យទាំងពីរខាងលើ បានបើករថយន្តចូលទៅក្នុងទឹកដីថៃដើម្បីដឹកឈើគ្រញូងឆ្លងដែនចូលមកកម្ពុជា ។

យោងតាមរបាយការណ៍ដែលយើងទទួលបានគឺ ការចាប់ខ្លួននេះបានប្រព្រឹត្តឡើង នៅវេលាម៉ោង ១១ ព្រឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ត្រង់ចំណុចផ្លូវបំបែកទៅកាន់ច្រកស៊ុំ ក្នុងភូមិបានផ្លែង ឃុំថេបនិមិត្ត ស្រុកពោងណាំរ៉

ន ខេត្តច័ន្ទបុរី ប្រទេសថៃ ដោយនៅក្នុងរថយន្តទាំងពីរគ្រឿង មានទាំងវត្ថុតាងនៅក្នុងនោះផង ។ ជនសង្ស័យទាំងពីរនាក់មានឈ្មោះ យេ លុច ភេទប្រុស អាយុ៣០ឆ្នាំ ជាមន្ត្រីយោធា ផ្នែកទំនាក់ទំនង ការងារព្រំដែន កម្ពុជា ថៃ ប្រចាំច្រកតំបន់ អូរអន្លក់ ក្នុងស្រុកកំរៀងនិងឈ្មោះ វ៉ាន់ ឡុង ជាប្រជាពលរដ្ឋធម្មតា ដោយនៅមុនពេលចាប់ខ្លួន គឺជនសង្ស័យទាំងពីរនាក់ បានប្រើប្រាស់រថយន្តចំនួន២គ្រឿង គឺ១ ម៉ាកលុចស៊ីស ព៌ណស្គរ ពាក់ស្លាកលេខ ភ្នំពេញ 2X-8301 និង២ ម៉ាកលុចស៊ីស ព៌ណស ពាក់ស្លាកលេខ ឧត្តរមានជ័យ 2A-0099 បានបើកឆ្លងដែនតាមច្រកអន្តរជាតិដូង ឆ្ពោះទៅកាន់ គោលដៅដើម្បីដឹកឈើគ្រញូងក្នុងខេត្ត ច័ន្ទបុរី ។ ពួកគេបានសារភាពបន្ថែមថា ក្រោយពីបានដាក់ឈើគ្រញូងរួចរាល់ហើយ គេក៏បាន បើករថយន្តចេញមកវិញ ក្នុងគោលបំណងចេញតាមច្រកតំបន់ អូរអន្លក់ ដែលជាចំណុច ឈរជើងរបស់ខ្លួន ប៉ុន្តែនៅពេលចេញមកដល់ត្រង់ចំណុចផ្លូវបំបែក ទៅកាន់ច្រកអូរអន្លក់ក៏ត្រូវតម្រួតថៃឃាត់រថយន្ត និងចាប់ខ្លួនតែម្តង ដោយសមត្ថកិច្ចថៃបានដកហូតវត្ថុតាង មានឈើគ្រញូងសរុបចំនួន ២០ ដុំ

ជុំវិញបញ្ហានេះ លោកឧត្តមសេនីយ៍ ពេជ្រ វណ្ណា នាយករងទីចាត់ការ ការងារព្រំដែន និងជាប្រធានការិយាល័យ ទំនាក់ទំនងព្រំដែន កម្ពុជា ថៃ បានមានប្រសាសន៍នៅព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នេះថា ថ្វីត្បិតតែរឿងនេះជារឿងរបស់បុគ្គល ហើយត្រូវបានមន្ត្រីថ្នាក់ក្រោមមួយចំនួនព្យាយាមបិទបាំង មិនអោយលោកដឹងក៏ដោយ ក៏នៅតែមានអ្នករាយការណ៍ប្រាប់លោកដែរ ដូច្នេះក្នុងនាមជាឪពុក ម្តាយ គឺលោក បាន និងកំពុងទាក់ទងទៅភាគីថៃរួចហើយ ដើម្បីស្នើសុំយកមនុស្សខាងលើមកដាក់ទោសនៅកម្ពុជាវិញ ប៉ុន្តែរហូតមកទល់នឹងពេលនេះនៅមិនទាន់មានចម្លើយនៅឡើយ ៕ សោ និយមវត្ថែ

## ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧

## ពលរដ្ឋកម្ពុជាទៅធ្វើការនៅថៃជាងមួយលាននាក់ ទាំងស្របច្បាប់និងមិនស្របច្បាប់

http://www.rasmeinews.com/ November 14, 2017

(ភ្នំពេញ)៖ លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំកិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទរយៈពេល១០ខែ ឆ្នាំ២០១៧ កាលពីរសៀលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ។ លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា រយៈពេល១០ខែ ឆ្នាំ២០១៧ នេះ ស្ថានភាពជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ត្រូវបានរកឃើញជាបន្តបន្ទាប់ គួរឲ្យកត់សម្គាល់។ មិនតែប៉ុណ្ណោះក៏មានលេចចេញបទល្មើសជួញដូរសរីរាង្គ និងបទអន្តរការី នៃអំពើពរពោះជំនួស ដើម្បីនាំយកចេញទៅក្រៅប្រទេស ដែលជាសញ្ញាថ្មីពាក់ព័ន្ធនិងបទល្មើសរត់ពន្ធ ឬជួញដូរមនុស្សឆ្លងដែន។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោះស្រាយ និងបង្ការទប់ស្កាត់ជាបន្ទាន់ ហើយចាប់ផ្តើមកសាងច្បាប់ ដើម្បីគ្រប់គ្រងសកម្មភាពពពោះជំនួសអោយបានឆាប់។ លោកស្រីបញ្ជាក់ថា ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតីដោយមានប្រជាពលរដ្ឋចាកចេញទៅធ្វើការនៅប្រទេសថៃរហូតដល់ជាង ១លាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់ ។

នៅមានពលករជាង៣០ម៉ឺននាក់ទៀត នៅមិនទាន់មានឯកសារស្របច្បាប់នៅឡើយក្នុងប្រទេសថៃ និយាយដោយឡែក និងជារួមនៅតាមបណ្តាប្រទេសមួយចំនួន។ លទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិទី១ នៃការអនុវត្តផែនការសកម្មភាពជាតិ ២០១៤-២០១៨ ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៦ បានរកឃើញចំណុចខ្លាំង

ចំណុចប្រឈម និងខ្វះខាតជាច្រើនដែលចាំបាច់ត្រូវកែលំអរ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញផែនការសកម្មភាពក្នុងដំណាក់កាលទី២ (២០១៧-២០១៨) ដោយបានឆ្លើយតបទៅនិងចំណុចខ្វះខាតទាំងឡាយដែលបានរកឃើញក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការ។ លោកស្រីបានបន្តទៀតថា អាស្រ័យដោយមានការប្រែប្រួលគោលនយោបាយក្នុងប្រទេសថៃ ក្នុងការរឹតបន្តឹងច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារថៃ ពលករកម្ពុជាដែលមួយចំនួនធំ បានឆ្លងដែនចូលទៅធ្វើការដោយខុសច្បាប់ គ្មានឯកសារត្រឹមត្រូវ បានប្រឈមនឹងការបញ្ជូនត្រឡប់ជាបន្តបន្ទាប់។

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្ហាញឲ្យដឹងថា ពលករដែលត្រូវបានបញ្ជូនដោយអាជ្ញាធរថៃបញ្ជូនមកតាមច្រកព្រំដែន ចំនួន១៨៧៦លើក មានមនុស្សចំនួន ១១៤.៩៥៨នាក់ (ស្រី៥១.៩២៨នាក់ និងកុមារ៦.៧៣១នាក់)។ ចំណែកពលករដែលត្រូវបានបញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន មានចំនួន ២.២០៥លើក មានមនុស្សចំនួន ១១៦.០០៥នាក់ (ស្រី៥២.៣៤០នាក់ និងកុមារ៦.៧៣១នាក់) ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ចំនួន២៩៦លើក មនុស្សចំនួន ៧៦៣នាក់ ស្រី៣៥៥នាក់៕ដោយៈ *មុនីរ័ត្ន/sn*

## ស្ថានភាពជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ មានការកើនឡើងគួរឲ្យកត់សម្គាល់

http://kleykley.sabay.com.kh/ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៧ ម៉ោង 15:57

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា រយៈពេល ១០ខែ ឆ្នាំ២០១៧នេះ ស្ថានភាពជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ត្រូវបានរកឃើញជាបន្តបន្ទាប់ គួរឲ្យកត់សម្គាល់។ ការលើកឡើងនេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទរយៈពេល ១០ខែ ឆ្នាំ២០១៧ នៅរសៀលថ្ងៃទី១៣ ខែវិច្ឆិកានេះ នៅទីស្តីការក្រសួងមហាផ្ទៃ។ លោកស្រី ជូ ប៊ុនអេង បន្តថាស្ថានភាពនេះក៏មានលេចចេញបទល្មើសជួញដូរសរីរាង្គ និងបទអន្តរការី នៃអំពើពពោះជំនួស ដើម្បីនាំយកចេញទៅក្រៅប្រទេស ដែលជាសញ្ញាថ្មីពាក់ព័ន្ធ និងបទល្មើសរត់ពន្ធ ឬជួញដូរមនុស្សឆ្លងដែន។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោះស្រាយ និងបង្ការទប់ស្កាត់ជាបន្ទាន់ ហើយចាប់ផ្តើមកសាងច្បាប់ ដើម្បីគ្រប់គ្រងសកម្មភាពពពោះជំនួសឲ្យបានឆាប់។ លោកស្រីបញ្ជាក់ថា ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតីដោយមានប្រជាពលរដ្ឋចាកចេញទៅធ្វើការនៅប្រទេសថៃ រហូតដល់ជាង ១លាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់។ លើសពីនេះ មានពលករជាង ៣ផម៉ឺននាក់ទៀត នៅមិនទាន់មានឯកសារស្របច្បាប់ក្នុងប្រទេសថៃនៅឡើយ៕

## វិចារណកថា: បទល្មើសតាមព្រំដែន នៅតែកើតឡើង យ៉ាងពេញបន្ទុក

http://www.kungbunang.net/ អង្គារ, ១៤ វិច្ឆិកា ២០១៧ 13:38 ដោយ: វាសនាដារាវិជ័យ ID:012

កន្លងមកថ្នាក់ ដឹកនាំក្រសួងមហាផ្ទៃ បានចេញបទបញ្ជា ឲ្យបិទច្រករបៀងទាំងអស់ តាមតំបន់ ព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តបន្ទាយមានជ័យ ក៏ប៉ុន្តែរហូតមកដល់ពេលនេះ ច្រករបៀងជា ច្រើនកន្លែង ដែលគ្រប់គ្រង ដោយនគរបាលឬយោធា នៅតែដំណើរការយ៉ាងរលូន ដូចមុន ដដែល ។ ឈ្មួញមួយចំនួន នៅតែអាចនាំទំនិញគេចពន្ធ ទំនិញខុសច្បាប់ រថយន្ត ចង្កូតស្តាំ និងម៉ូតូគេចពន្ធពីទឹកដីថៃ ចូលទឹកដីខ្មែរ តាមអំពើចិត្ត ដោយគ្មានញញើតអ្វីទាំងអស់ ព្រោះ មាន ការឃុបឃិតជាប្រព័ន្ធរួចទៅហើយ ។ ជាពិសេសនៅតាមច្រករបៀងមួយចំនួន នៅតែ មានបើកឲ្យ

ពលករខ្មែរឆ្លងដែនខុសច្បាប់ ចូលទៅរកការងារធ្វើ លើទឹកដីថៃហើយត្រូវ សមត្ថកិច្ច អាជ្ញាធរថៃ ចាប់បញ្ជូនត្រឡប់មកវិញ ជាបន្តបន្ទាប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងតាមច្រកព្រំដែននៅក្នុងខេត្តបាត់ដំបង ។

ថ្មីៗកន្លងទៅនេះ មានសេចក្តីរាយការណ៍ថា ម៉ូតូទំនើបៗគេចពន្ធ និងរថយន្តចង្កូតស្តាំ នៅតែ ត្រូវឈ្មួញនាំចូលតាមច្រករបៀងក្នុងឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមាន ជ័យ ជាបន្តបន្ទាប់ហើយគ្មានមន្ត្រីជំនាញ ឬសមត្ថកិច្ចពាក់ព័ន្ធណាចាត់វិធានការ ទប់ស្កាត់ នោះឡើយ ។ ប្រភពខ្លះបានឲ្យដឹងថា សាច់ញាតិមន្ត្រីនគរបាលជាន់ខ្ពស់ ក្នុងខេត្តបន្ទាយ មានជ័យ គឺជាអ្នកជាប់ពាក់ព័ន្ធ ក្នុងការនាំចូលម៉ូតូគេចពន្ធ និងរថយន្តចង្កូតស្តាំតាមច្រករបៀងចំការគ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ហើយមានការឃុបឃិតពីសំណាក់ មន្ត្រីយោធានិងមន្ត្រីនគរបាលឈរជើងការពារតាមព្រំដែនផងដែរ ។ តាមច្រករបៀង ជាច្រើន កន្លែងក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នៅតែមានឈ្មួញនាំចូល ទំនិញគេច ពន្ធ ទំនិញខុសច្បាប់ ពីទឹកដីថៃចូលទឹកដីខ្មែរ ហើយមានឈ្មួញខ្លះនាំចូលឈើគ្រញូង តែត្រូវសមត្ថកិច្ចគយចល័តបង្ក្រាបកាលពីពេលថ្មីៗកន្លងទៅនេះ។ ដូច្នេះតាមពិនិត្យជាក់ ស្តែងគឺបទល្មើសឆ្លងដែនតាមបណ្តោយព្រំដែនក្នុងខេត្តបន្ទាយមានជ័យ នៅតែកើ តមានបទ ល្មើសឆ្លងដែនយ៉ាងពេញបន្ទុក។

ចំណែកនៅច្រកព្រំដែនអូរជ្រៃល ក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង សមត្ថកិច្ចប្រចាំច្រ កនេះបាន ឃុបឃិតបើកដៃឲ្យឈ្មួញនាំចូលគ្រឿងឧបភោគបរិភោគដូចជាគ្រឿងក្នុងជ្រូក សាច់មាន់ ជង្គង់មាន់ ស្លាបមាន់ ត្រីនិងប្រហិតខូចគុណភាពពីទឹកដីថៃ ចូលទឹកដីកម្ពុជាយ៉ាងពេញ បន្ទុកតែម្តង។ ទំនិញជាប្រភេទចំណីអាហារដែលឈ្មួញសម្រុកនាំចូលតាមច្រក អូរជ្រៃល មិនត្រូវបានសមត្ថកិច្ចជំនាញត្រួពិនិត្យ គុណភាពមុនពេលអនុញ្ញាត្ត ឲ្យឈ្មួញនាំ ចូលនោះទេ ហើយបញ្ហានេះកំពុងបង្កផលប៉ះពាល់យ៉ាងខ្លាំង ដល់សុខភាពពលរដ្ឋខ្មែរ ដែល ទិញ ចំណីអាហារទាំងនោះ យកទៅទទួលទាន។ ឈ្មួញម្នាក់ឈ្មោះ យាយញ៉ បានប្រកប របរ នាំចូលផលិតផលពីសត្វតាមច្រកអូរជ្រៃលច្រើនឆ្នាំមកហើយដោយសារមានការ ឃុបឃិតពី សំណាក់មេគយនៅច្រកនេះដែលគិតតែពីរឿងផលប្រយោជន៍ផ្ទាល់ខ្លួនហើយ បើកដៃឲ្យ ឈ្មួញធ្វើអ្វីៗតាមអំពើចិត្ត។ ចំណែកមន្ត្រីកាំកុងត្រូលនិងមន្ត្រីពេទ្យសត្វកំពុង សប្បាយប្រមូលលុយពីឈ្មួញនាំចូលទំនិញ ជាប្រភេទចំណីអាហារខូចគុណភាពនិងមាន លាយសារ ជាតុគីមីមកផ្លាញសុខភាពប្រជាពលរដ្ឋកម្ពុជា។

តាមព្រំដែនក្នុងខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ និងខេត្តឧត្តរ មានជ័យ មិនត្រឹមតែកើតមានករណី ឈ្មួញលួចនាំចូលទំនិញគេចពន្ធ ទំនិញបង់ពន្ធមិនគ្រប់និងទំនិញខូចគុណភាពប៉ុណ្ណោះទេ គឺមានករណីពលរដ្ឋកម្ពុជាឆ្លងដែនខុសច្បាប់ចូល ទៅកាប់ឈើគ្រញូងទៀតផង។ ករណីពលរដ្ឋកម្ពុជាឆ្លងដែនចូលកាប់ឈើ គ្រញូងលើទឹកដី ថៃក្នុងខេត្តច័ន្ទបុរី ខេត្តស្រះកែវ ខេត្តនគររាជសីមា ខេត្តសុរិន្ទ ខេត្ត ស៊ីសាកេតនិងខេត្តអ៊ូប៊ុន ជាដើមត្រូវសមត្ថកិច្ចថៃបង្ក្រាបនិងចាប់ខ្លួនជាបន្តបន្ទាប់។ ក៏ប៉ុន្តែរហូតមកដល់ពេលនេះ ឈ្មួញឈើគ្រញូងក្នុងខេត្តឧត្តរមានជ័យ ដែលជាមន្ត្រី យោធានិងមន្ត្រីនគរបាលនៅតែអាច គេចផុតពីសំណាញ់ច្បាប់ដដែល។ ឈ្មួញឈើគ្រញូង នៅតែអាចដឹកជញ្ជូនឈើគ្រញូងពី ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ឆ្លងកាត់ខេត្ត សៀមរាបនិងខេត្តកំពង់ធំ ចេញទៅវៀត ណាម យ៉ាងគគ្រឹកគគ្រេងហើយសមត្ថកិច្ច បង្ក្រាបបានតិចតួចបំផុត។

បើតាមសេចក្តីរាយការណ៍ ពីមន្ត្រីតូចតាចនៅច្រកតន់ហាន់ ស្រុកកំពង់ត្រាច ខេត្តកំ ពត បានឲ្យដឹងថា មួយរយៈពេលកន្លងទៅនេះ ឈ្មួញដឹកជញ្ជូនឈើចេញទៅវៀតណាម តាម ច្រកតន់ហាន់ រាប់រយម៉ែត្រគូប ក្នុងមួយថ្ងៃៗហើយគ្មានមន្ត្រីជំនាញឬសមត្ថកិច្ចពាក់ ព័ន្ធណា ចាត់វិធានការបង្ក្រាបឡើយ។ ឈើទាំងនោះឈ្មួញប្រមូលទិញពី

ស្រុកវាលវែង ស្រុកភ្នំក្រវាញ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ហើយដឹកជញ្ជូនឆ្លងកាត់ខេត្តកំពង់ស្ពឺនិងខេត្ត កំពត ចេញទៅ វៀតណាមតាមច្រកតន់ហន់ យ៉ាងរលូនហើយនៅច្រកព្រៃកចាក ស្រុក កំពង់ត្រាច ខេត្តកំពត ក៏មាន ឈ្មួញដឹកជញ្ជូនឈើចេញទៅវៀតណាមដែន។ សរុបសេចក្តីមកបទល្មើសឆ្លងដែន កំពុងកើតឡើងយ៉ាងពេញបន្ទុក ទាំងនៅតាមតំបន់ព្រំ ដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម។ ក្នុងនោះបទល្មើសនាំចូលទំនិញគេចពន្ធ ទំនិញ បង់ពន្ធមិនគ្រប់និងចំណីអាហារ ខូចគុណភាព មិនត្រឹមតែធ្វើឲ្យរដ្ឋត្រូវខាតបង់ចំណូលពន្ធ យ៉ាងច្រើនសន្ធឹកសន្ធាប់ ប៉ុណ្ណោះទេ គឺធ្វើឲ្យប៉ះពាល់ដល់សុខភាព របស់ពលរដ្ឋខ្មែរកាន់តែ ខ្លាំងឡើងៗទៀតផង៕

## ពលករកម្ពុជាធ្វើការនៅប្រទេសថៃជិត 50នាក់ ត្រូវថៅកែថៃបញ្ឈប់ពីការងារ

http://www.trolldee.com/archives November 14, 2017

កាលពីវេលាម៉ោង 06:00 ល្ងាចថ្ងៃច័ន្ទ ទី13 ខែវិច្ឆិកា ឆ្នាំ2017 ម្សិលមិញនេះ កម្មការិនីកម្ពុជាចំនួន42នាក់ ត្រូវក្រុមហ៊ុនស្ប៉ាម៉ាស្សាមួយកន្លែងស្ថិតនៅមុខវត្តស៊ីវ៉ាំ ស្រុកបាងសៅធុង ខេត្តសាមុតប្រាកាន ប្រទេសថៃ ត្រូវអ្នកគ្រប់គ្រងក្រុមហ៊ុនបញ្ឈប់ពីការងារដោយសារតែកម្មការនីខ្មែរទាំងនោះមិនគោរពតាមកិច្ចសន្យារបស់ក្រុមហ៊ុន។ យោងតាមប្រភពព័ត៌មានរបស់ប្រទេសថៃ បានចុះផ្សាយអោយដឹងថា មូលហេតុដែលកម្មការនីខ្មែរចំនួន 42នាក់ ត្រូវក្រុមហ៊ុនស្ប៉ាម៉ាស្សាខាងលើនេះបញ្ឈប់នោះ គឺដោយសារតែកម្មការនីខ្មែរនិងថៃ បាននាំគ្នាឈប់ការងារហើយធ្វើកូដកម្មទាមទារឲ្យក្រុមហ៊ុនបញ្ឈប់កិច្ចសន្យា កាត់ប្រាក់ឈ្នួលប្រចាំថ្ងៃរបស់ពួកគេ។

ប្រភពពីកម្មករខ្មែរនិងកម្មករថៃមួយចំនួនបានប្រាប់សាព័ត៌មានប្រទេសថៃ អោយដឹងថា កាលពីពេលថ្មីកន្លងទៅនេះក្រុមហ៊ុនស្ប៉ាម៉ាស្សាខាងលើ ធ្វើកិច្ចសន្យា កាត់ប្រាក់កកនៅពេលចូលធ្វើការលើកដំបូងក្នុងម្នាក់2000បាតទៅ3000បាត ដោយចាប់ផ្តើមកាត់រយ:10 ថ្ងៃ 1 ក្នុងថ្ងៃចំនួនទឹកប្រាក់ 200បាត និងប្រចាំខែចំនួន600បាត ហើយនៅពេលកម្មករលាឈប់ធ្វើការត្រូវរាយការណ៍ជូនដំណឹងដលក្រុមហ៊ុនមុនរយ:15ថ្ងៃ ទើបទទួលបានប្រាក់កក់ដែលកាត់ចំនួនទាំងអស់នោះមកវិញ តែក្រុមកម្មកមិនយល់ព្រមតាមកិច្ចសន្យារបស់ក្រុមហ៊ុនទើបនាំគ្នាឈប់ការងារ ហើយមកធ្វើកូដកម្មទាមទារនៅមុខក្រុមហ៊ុនដូច្នេះ។

បើយោងតាមតាមការរៀបរាប់របស់អ្នកគ្រប់គ្រងក្រុមហ៊ុនស្ប៉ាម៉ាស្សាមួយនេះ បានបញ្ជាក់ឱ្យដឹងថា កម្មការនីខ្មែរទាំង 42នាក់ មិនយល់ព្រមគោរពតាមកិច្ចសន្យារបស់ក្រុមហ៊ុនដែលបានប្រកាសឡើង ទើបក្រុមហ៊ុនសម្រេចចិត្តបញ្ឈប់កម្មការនីខ្មែរទាំង42នាក់ អោយធ្វើការម្តង ព្រមទាំងរៀបចំពាក្យបណ្តឹងប្តឹងទៅសមត្ថកិច្ចថៃ អោយចាត់វិធានការលើកម្មករខ្មែរទាំង42នាក់ពីបទល្មើសបុករុកគេហដ្ឋានរបស់ក្រុមហ៊ុន។ ចំពោះកម្មករជនជាតិថៃក្រុមហ៊ុនបានទុកឱកាសឲ្យកម្មករសម្រេចចិត្តរយ:ពេល1ថ្ងៃ ដើម្បីអោយចូលវិញ តែបើមិនចូលធ្វើការតាមការកំណត់របស់ក្រុមហ៊ុននិងបញ្ឈប់កម្មករថៃទាំងអស់នោះផងដែរ ក្នុងករណីនេះដែរអ្នកគ្រប់គ្រងក្រុមហ៊ុនដដែលបានលើកឡើងថាចំពោះកម្មការនីខ្មែរចំនួន42នាក់នេះ ធ្លាប់ឈប់ការងារលក្ខណ:បែបនេះម្តងរួចហើយ ហើយធ្វើឱ្យក្រុមហ៊ុនខាតបង់ប្រាក់ចំណូល ព្រមទាំងបាត់បង់ភ្ញៀវទេសចរមួយចំនួនទៀត ហើយកម្មការិនីខ្មែរទាំងអស់នោះថែមទាំងនិស្ស័យឌឹងងមិនស្តាប់បង្គាប់របស់ក្រុមហ៊ុនឡើយ។

យ៉ាងមិញរឿងរាវដែលក្រុមហ៊ុនស្ប៉ាម៉ាស្សាមួយនេះបញ្ឈប់ការងារកម្មការិនីខ្មែរចំនួន 42នាក់ នៅក្នុងប្រទេសថៃលើកនេះ នៅមិនទាន់មានការបកស្រាយពីខាងភាគីកម្មការនីកម្ពុជានៅឡើយទេ។

## អ្នកវិភាគសង្គម ស្នើទៅរាជរដ្ឋាភិបាលថៃ ឱ្យបន្តរយៈពេលស្នាក់នៅដល់ពលករកម្ពុជា ក្នុងករណីផ្ទៀងផ្ទាត់សញ្ជាតិ មិនទាន់ពេលកំណត់

http://www.trolldee.com/archives November 13, 2017

លោកបណ្ឌិតផ្នែកសក្សាស្រាវជ្រាវបញ្ហាសង្គមនៅមហាវិទ្យាល័យធំក្នុងប្រទេសថៃ បានបើកកិច្ចប្រជុំពិភាក្សាអំពីបញ្ហាពលករបរទេស និងការផ្ទៀងផ្ទាត់សញ្ជាតិ របស់ពលករកម្ពុជា បន្ទាប់ពីមានភាពយឺតយ៉ាវ អាចបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសថៃ។ ក្នុងកិច្ចប្រជុំនេះលោកសាស្ត្រាចារ្យនៃមហាវិទ្យាល័យក្នុងប្រទេសថៃ បានស្នើសុំដល់រាជរដ្ឋាភិបាលថៃ អោយបន្ត សុពលភាពស្នាក់នៅដល់ពលករកម្ពុជា ដើម្បីធ្វើការបញ្ជាក់អត្តសញ្ញាណបានត្រឹមត្រូវ តាមច្បាប់ប្រទេសថៃ បន្ទាប់ពីបញ្ហាផ្ទៀងផ្ទាត់សញ្ជាតិជូនពលករកម្ពុជាមានភាពយឺតយ៉ាវ។ អាចធ្វើឲ្យពលករទាំងនោះផ្ទៀងផ្ទាត់សញ្ជាតិមិនទាន់ រយៈពេលដែលរាជរដ្ឋាភិបាលថៃបានកំណត់ ហើយបញ្ហានេះហើយដែលធ្វើឲ្យសេដ្ឋកិច្ចថៃជួបបញ្ហានៅពេលខ្វះខាតពលករធ្វើការ។

## ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧

## សមត្ថកិច្ចស្នាក់ចាប់អ្នកឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ លួចកាប់ឈើ

http://ann.com.kh/site/news/ ថ្ងៃពុធ, 15 ខែវិច្ឆិកា 2017 8:22 ព្រឹក

**ខេត្តប៉ៃលិន៖** ប្រជាពលរដ្ឋដែលញៀននឹងការឆ្លងដែនលួចកាប់ឈើ នៅក្នុងទឹកដីប្រទេសថៃ ចំនួន៤នាក់ត្រូវបានសមត្ថកិច្ចចាប់ខ្លួន រួមជាមួយនឹងម៉ូតូកញ្ចាស់ចំនួន៤គ្រឿង ម៉ាស៊ីនត្រង់ស៊ីន័រ១គ្រឿង ព្រមទាំងឈើធ្នង់ជាច្រើនដុំផងដែរ។ ករណីនេះធ្វើឡើងកាលពីវេលាម៉ោង១០ និង៣០នាទីព្រឹក ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅចំណុចចន្លោះបង្គោលសីមាលេខ៦៧ និង៦៨ ក្នុងភូមិបហ៊ុយត្បូង សង្កាត់បយ៉ាខា ក្រុងប៉ៃលិន។

សូមបញ្ជាក់ថា ជនសង្ស័យទាំង៤នាក់ខាងលើ មិនត្រូវបានគេអនុញ្ញាតឱ្យស្គាល់ឈ្មោះនោះទេ ពួកគេរស់នៅក្នុងក្រុងប៉ៃលិន ដោយបាននាំគ្នាឆ្លងដែនទៅលួចកាប់ឈើនៅក្នុងទឹកដីថៃអស់រយៈពេលជាយូរមកហើយ ដោយមានការបើកដៃពីសមត្ថកិច្ចការពារព្រំដែនមួយចំនួន។ បន្ទាប់ពីប្រទះឃើញពួកគេដឹកឈើធ្នង់ជាច្រើនដុំ សមត្ថកិច្ចក៏ធ្វើស្ទាក់ចាប់យកទៅបន្ទាយយោធា ហើយក៏ប្រគល់ជូនទៅខាងរដ្ឋបាលព្រៃឈើដើម្បីចាត់ការបន្តតែម្តង។

លោក មិន រ៉ាវុធ នាយផ្នែករដ្ឋបាលព្រៃឈើប៉ៃលិន បានឲ្យដឹងថា បន្ទាប់ពីធ្វើការឃាត់ខ្លួន លោកក៏បានធ្វើការអប់រំដល់ប្រជាពលរដ្ឋទាំង៤នាក់នោះ មិនឲ្យបន្តឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅក្នុងទឹកដីប្រទេសថៃទៀតឡើយ។ លោកបន្តទៀតថា ឈើទាំងអស់ និងម៉ាស៊ីនកាត់ឈើ១គ្រឿង ខាងលោកនឹងចាប់ យកទៅរក្សាទុកនៅក្នុងស្នាក់ការ, ដោយឡែកមនុស្សទាំង៤នាក់ បន្ទាប់ពីធ្វើការអប់រំរួចឲ្យយកម៉ូតូត្រឡប់ទៅផ្ទះរៀងៗខ្លួន។

ប្រជាពលរដ្ឋរស់នៅក្នុងក្រុងប៉ៃលិន បានលើកឡើងថា ចំណុចខាងលើ ជាកន្លែងដែលមានពលរដ្ឋឆ្លងដែនខុសច្បាប់ទៅលួចកាប់ និងលីសែងឈើនៅក្នុងទឹកដីប្រទេសថៃ ដោយមានអ្នកខ្លះត្រូវថៃចាប់ដាក់គុក បាញ់សម្លាប់បណ្តាលឲ្យព្រាត់ប្រាសប្តីប្រពន្ធ, ហើយអ្នកខ្លះទៀត បានបាត់ខ្លួនរហូតមកដល់ពេលនេះទៅហើយមិនទាន់ឃើញត្រឡប់មកផ្ទះវិញនៅឡើយទេ។ ដូច្នេះប្រជាពលរដ្ឋសំណូមពរឲ្យខាងសមត្ថកិច្ច ធ្វើការរឹតបន្តឹង ដោយមិនត្រូវបណ្តែតបណ្តោយឲ្យពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ទៅលួចកាប់ឈើនៅប្រទេសថៃបន្ត ទៀតនោះឡើយ៕ **ដោយ៖ ឡេ សុខហៃ**

## ១០ខែដំបូងឆ្នាំ២០១៧ មានពលរដ្ឋខ្មែរឆ្លងទៅថៃ កើនឡើងជាង៣ម៉ឺននាក់

http://kleykley.sabay.com.kh/article/ ម៉ោង 16:46 ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៧

អាជ្ញាធរថៃ បានបញ្ជូនពលរដ្ឋខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញក្រោមរូបភាព និរទេស តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន ១.៤៧៨ ជើង/រថយន្ត មានមនុស្សចំនួន ៦៥.៨២៥ នាក់ ស្រី ២៣.១៥១ នាក់ ក្នុងនោះកុមារ ៦.៤៤១ នាក់។ បើប្រៀបធៀបក្នុងរយៈពេល១០ខែ ឆ្នាំ២០១៦ ប្រជាពលរដ្ឋខ្មែរមានចំនួនតែ ៣៥.៨២៣ នាក់ គឺកើនឡើង ៣០.០០២ នាក់ ស្មើនឹង ៨៣,៧៥ ភាគរយ។ នេះបើយោងតាមរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រយៈពេល១០ខែ ឆ្នាំ២០១៧ ដែលបានផ្សព្វផ្សាយកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។ ប្រភពដដែលឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរចំនួន ៥៣០៦នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេលមួយខែមុននឹងបញ្ជូនមកកម្ពុជាវិញ។

ទីចាត់ការការងារព្រំដែន នៃអគ្គបញ្ជាការដ្ឋានក្រសួងការពារជាតិ បានទទួលសាកសពពលរដ្ឋខ្មែរពីអាជ្ញាធរថៃចំនួន ១៥៨លើក សរុបចំនួន ១៦២សព ក្នុងនោះស្រី ២៩នាក់។

ប្រជាពលរដ្ឋខ្មែរចេញទៅប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន ២៦.០៨២ នាក់ និងតាមច្រករបៀងមានចំនួន ៣៩.៧៤៣ នាក់។ ហើយក្នុងនោះចេញដោយខ្លួនឯងមានចំនួន ២៩.៤៨៦ នាក់ និងតាមគេនាំមានចំនួន ៣៦.៣៣៩ នាក់៕ អត្ថបទ៖ សោភា

## ប្រមុខដឹកនាំអាស៊ាន ចុះកិច្ចព្រមព្រៀងការពារសិទ្ធិពលករចំណាកស្រុកអាស៊ាន ឲ្យមានសេរីភាពកាន់តែទូលំទូលាយ ក្នុងការស្វែងរកការងារធ្វើ ក្នុងប្រទេសអាស៊ានទាំង១០ ដោយគ្មានការភិតភ័យ

http://www.freshnewsasia.com/ 2017-11-15

**(ភ្នំពេញ)៖** កិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ នៅប្រទេសហ្វីលីពីន បានបញ្ចប់ហើយនៅយប់មិញនេះ ដោយទទួលបាននូវលទ្ធផលជាទីពេញចិត្ត នៃបណ្តាប្រទេសសមាជិកអាស៊ានទាំងអស់។ លទ្ធផលដែលសម្រេចបានទាំងនេះ គឺបានមកពីការជជែកពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ដើម្បីរកផលប្រយោជន៍រួមទាំងក្នុងកម្រិតតំបន់ និងក្នុងកម្រិតពិភពលោកទាំងមូលផងដែរ។

បើតាមការបញ្ជាក់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា តាមរយៈ Facebook របស់សម្តេចនៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកានេះ បានឲ្យដឹងថា សមទ្ធិផលសំខាន់មួយ ក្នុងចំណោមសមទ្ធិផលផ្សេងៗទៀត ដែលសម្រេចបានក្នុងកិច្ចប្រជុំ គឺមេដឹកនាំនៃប្រទេសអាស៊ានទាំង១០ បានចុះហត្ថលេខា លើកកិច្ចព្រមព្រៀងការពារសិទ្ធិពលករចំណាកស្រុកអាស៊ាន ឲ្យមានសិទ្ធិសេរីភាពកាន់តែទូលំទូលាយ ក្នុងការស្វែងរកការងារធ្វើ នៅក្នុងចំណោមប្រទេស អាស៊ានទាំង១០ ដោយគ្មានការភិតភ័យអ្វីឡើយ ដែលសព្វថ្ងៃនេះ មានប្រមាណជាង១០លាននាក់ នៅក្នុងប្រទេសតំបន់អាស៊ាន។

សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ទៀតថា «**ប្រទេសអាស៊ានទាំង១០ យើងរួមសុខរួមទុក្ខជាមួយគ្នា និងរីកចម្រើនទៅមុខជាមួយគ្នា ដោយមិនទុកប្រទេសណាឲ្យនៅពីក្រោយឡើយ។ ទន្ទឹមនឹងនោះ ក៏យើងមិនជ្រៀតជ្រែកការងារផ្ទៃក្នុង របស់ប្រទេសណាឡើយ ប៉ុន្តែយើងរួមគ្នាដោះស្រាយបញ្ហានានា ដោយសន្តិវិធីដែលនាំមកនូវវិបុលភាព និងសន្តិភាព**»។ សម្តេចតេជោ ហ៊ុន សែន បន្ថែមទៀតថា កិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ គឺបានបញ្ចប់ ដែលទទួលបាននូវលទ្ធផលជាទីពេញចិត្ត នៃបណ្តាប្រទេសសមាជិកអាស៊ានទាំងអស់។ លទ្ធផលដែលសម្រេចបានទាំង

នេះ គឺបានមកពីការជជែកពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ដើម្បីរកផលប្រយោជន៍រួមទាំងក្នុងកម្រិតតំបន់ និងក្នុងកម្រិតពិភពលោកទាំងមូលផងដែរ។ នៅឆ្នាំ២០១៨ ខាងមុខនេះ កិច្ចប្រជុំកំពូលអាស៊ាន នឹងរៀបចំដោយប្រទេសសិង្ហបុរី។

គួរបញ្ជាក់ថា នៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកានេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ វិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ បន្ទាប់ពីបានមកចូលរួមប្រជុំសំខាន់ៗចំនួន២ គឺ APEC នៅវៀតណាម និងប្រជុំកំពូលអាស៊ានលើកទី៣១ នៅប្រទេសហ្វីលីពីន៕

## ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧
## ប្រសាសន៍សំខាន់ៗ សម្តេចតេជោក្នុងឱកាស អញ្ជើញជួបសំណេះសំណាល កម្មករជាង១ម៉ឺននាក់នៅតំបន់ រោងចក្រ 7NG

https://www.dap-news.com/kh/ ព្រហស្បតិ៍, ១៦ វិច្ឆិកា ២០១៧ 08:22 ដោយ: គៀត មង្គល ID:049

ភ្នំពេញ៖ ខ្ញុំសំណូមពរមួយទៅកាន់ថៅកែ រោងចក្រខ្ញុំសង្ឃឹមថា នឹងទទួលយកសំណូមពររបស់ខ្ញុំ ក្មួយកម្មករខ្លះក្រោកតាំងពីម៉ោង៣ដើម្បីបានជួបពូហ៊ុន សែនខ្ញុំសូមស្នើឲ្យថៅកែរោងចក្រ អនុញ្ញាតឲ្យកម្មករឈប់សម្រាកមួយរសៀលទៀត និងរៀបចំកម្មវិធីរាំញ៉ាក់កែងជើងលេង ។

ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ ដែលទទួលបានការស្វាគមន៍ ពីសំណាក់ក្មួយៗកម្មករយើង ។ ក្មួយមានឃើញពូស្លៀកពាក់ អាវក្រោះប្រឆាំងនឹងគ្រាប់? ពូមិនបានស្លៀកពាក់អាវក្រោះការពារគ្រាប់ ការពារកាំបិតចាក់នោះទេ ពូទុកចិត្តនឹងជឿជាក់លើប្រជាជនកម្ពុជា។ ក្មួយៗពិតជាស្គាល់ហ៊ុនសែនច្បាស់ណាស់ តាមរយៈឪពុកម្តាយនិងជីដូនជីតា របស់ក្មួយក្នុងការចូលរួមចំណែក ស្វែងរកសន្តិភាព ការបង្រួបបង្រួម និងការអភិវឌ្ឍន៍ជាតិ ។ គោលនយោបាយរបស់ ហ៊ុន សែន ឬអាចនិយាយបានថា ចក្ខុវិស័យរបស់គណបក្សប្រជាជនកម្ពុជា គឺប្រែក្លាយអតីតតំបន់សមរភូមិទាំងអស់ ឲ្យក្លាយជាតំបន់ឧស្សាហកម្មនិងការអភិវឌ្ឍន៍។ ថ្ងៃនេះយើងមិនត្រូវបំភ្លេចតំបន់ដំណាប់ នៅព្រៃកតាមាក់និងវិហារសួគ៌នេះទេ។

នៅតំបន់នេះជាតំបន់ប្រយុទ្ធស្រួចស្រាវបំផុត នៅក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥។ ថ្ងៃនេះមិនគួរឲ្យជឿតំបន់នេះអាចក្លាយទៅជាតំបន់រោងចក្រ អភិវឌ្ឍន៍មួយដែលផ្តល់ការងារ ដល់ពលរដ្ឋរាប់ម៉ឺននាក់។ យើងនឹងប្រែក្លាយតំបន់ព្រំដែនទាំងអស់ ជាមួយប្រទេសជិតខាង ឲ្យក្លាយជាតំបន់អភិឌ្ឍន៍ ស្ថេរភាព កិច្ចសហប្រតិបត្តិការ ដែលពោរពេញ ទៅដោយសន្តិភាព។មានចក្ខុវិស័យតែគ្មានការអនុវត្តក៏មិនអាចទៅរួចបានដែរ។ កម្ពុជាយើងធ្លាប់មានមិច២១តែបច្ចុប្បន្ននេះ យើងមិនត្រូវការប្រើប្រាស់មិច២១ ធ្វើសង្គ្រាមទៀតនោះទេ យើងត្រូវការតែកាំភ្លើងបាញ់ទម្លាក់មិច២១បានហើយ ។ យើងមិនត្រូវការធ្វើសង្គ្រាមលើអាកាសនាំឲ្យមានផលប៉ះពាល់នោះទេ។ សមិទ្ធផលរោងចក្រជាច្រើន មិនមែនបានមកពីបាតដៃ បក្សប្រឆាំងនោះទេ គឺបានមកពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ជាពិសេសក្រោមការដឹកនាំ របស់គណបក្សប្រជាជនកម្ពុជា។ ពូសូមអរគុណដែលជីដូនជីតា និងឪពុកម្តាយរបស់ក្មួយព្រមទាំង ក្មួយដែលបានផ្តល់ការគាំទ្របោះឆ្នោតឲ្យពូបាន ធ្វើជានាយករដ្ឋមន្ត្រី។

ក្នុងកិច្ចប្រជុំអាស៊ានក្នុង២៤ម៉ោង យើងធ្វើការ២០ម៉ោងដើម្បី អ្នកណាទៅ គឺដើម្បីជាតិ។ ពូមិនបានដឹកនាំប្រទេសនេះ ពីមានទៅក្រទេ គឺពីក្រទៅមាន។ ពូសូមយកឱកាសនេះអបអរ ជាមួយក្មួយៗដែលសម្រេចបានដំណើរការ ការងារនៅទីនេះ។ ពេលនេះកំពុងអនុវត្តប្រៀវត្ស ១៥៣ដុល្លារអាមេរិក តែនេះវាមិនស្តប់ទេ វានឹងឡើងដល់១៧០ដុល្លារនៅឆ្នាំ២០១៨ខាងមុខនេះ សូមអបអរសាទរ។ ដើម្បីបាន១៧០ដុល្លាររាជរដ្ឋាភិបាល ធ្វើការច្រើនណាស់។ រាជរដ្ឋាភិបាលមិនបានដាក់ទម្ងន់ ទៅលើតែម្ចាស់រោងចក្រនោះទេម្ចាស់ រោងចក្រហ៊ានតែ១៦៥ដុល្លារទេហើយចាប់ពីឆ្នាំ២០១៨ទៅម្ចាស់រោងចក្រត្រូវ វបង់របបថៃទាំងសុខភាព ឲ្យកម្មករទាំងអស់ផងដែរ។ អីចឹងរាជរដ្ឋាភិបាលត្រូវចូលរួមចំណែក បង្កើន៥ដុល្លារសម្រាប់ក្មួយៗពី១៦៥ដុល្លារ ដល់១៧០ដុល្លារនេះមិនមែន បានមកពីការទាមទាររបស់បក្សប្រឆាំងនោះទេ គឺបានមកពីការទាមទារ របស់ហ៊ុនសែនតែម្តង។

មិនគ្រាន់តែនៅក្នុងប្រទេសកម្ពុជាទេ កិច្ចប្រជុំអាស៊ានឆ្នាំនេះ មានចំណុចពិសេសមួយគឺ ការការពារពលករចំណាកស្រុក គឺសំខាន់ខ្លាំងណាស់។ យើងប្រឹងរកទីផ្សារការងារនៅខាងក្រៅដូច្នេះកម្មករយើងដែលកំពុងធ្វើការនៅថៃ និងម៉ាឡេស៊ី ទាំងស្របច្បាប់និង មិនស្របច្បាប់សូមមេត្តារីករាយ។

រាជរដ្ឋាភិបាលខំប្រឹងណាស់ ក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើតឱកាសសម្រាប់ការ វិនិយោគនិងការអភិវឌ្ឍន៍ប្រទេស។ អាវទាំងអស់របស់ពូមិនដែលទិញអាវ ពីបរទេសមកពាក់ទេនៅត្រង់ ចម្លែកបន្តិចពូជាមនុស្សខុសខ្នាត បើទិញពីបរទេសពាក់ទៅតឹងបន្តិច ដោយសារខុសកន្លះលេខ។ កាលពីសម័យសង្គ្រាមគេឃើញពូ នៅសមរភូមិជួរមុខដោះស្រាយបញ្ហា កងទ័ពក្នុងពេលជាមួយគ្នាដែរគេឃើញពូ នៅតុចរចាក្រៅប្រទេសដើម្បីដោះស្រាយ រកសន្តិភាព។ក្រោយអនុវត្តនយោបាយឈ្នះឈ្នះ ហើយគេឃើញពូនៅតាមវាលស្រែជួបជាមួយកសិករ សិស្សនិស្សិតច្រើនជាងដែលខណៈយើងកំពុងអនុវត្ត នយោបាយស្រូវអង្ករ។ យើងបានប្រែក្លាយពីប្រទេសខ្វះខាតស្រូវអង្ករហើយយើងបាននាំអង្កររបស់ ទៅកាន់ក្រៅប្រទេសជាច្រើន។ ពូពិតជាសប្បាយរីករាយ ដែលបានជួបក្មួយៗកម្មករ ពូនឹងបន្តសកម្មភាពបែបនេះទៀត ។

## អាជ្ញាធរខេត្តបន្ទាយមានជ័យស្នើភាគីថៃរួមគ្នាទប់ស្កាត់បទល្មើសតាមព្រំដែនកម្ពុជា-ថៃបន្ថែមទៀត

http://cambodiapolice.com/ 10:20 am 16 វិច្ឆិកា 2017 13

បន្ទាយមានជ័យ៖ អាជ្ញាធរខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា និងខេត្តស្រះកែវ ប្រទេសថៃ រួមមានមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ បានជួបសម្តែងការស្វាគមន៍គ្នា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរួមគ្នា។ ជំនួបនេះធ្វើឡើងកាលពីរសៀលថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅលើស្ពានមិនភាពកម្ពុជា-ថៃ ស្ថិតក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ឯកឧត្តម សួន បវរ អភិបាលខេត្តបន្ទាយមានជ័យបាន អោយដឹងថា អាជ្ញាធរខេត្តបន្ទាយមានជ័យ កម្ពុជានិងអាជ្ញាធរខេត្តស្រះកែវ ប្រទេសថៃ បានជួបសម្តែងការគួសមដើម្បីកិច្ចសហប្រតិបត្តិការអោយបានល្អប្រសើរក្នុងនាមប្រទេសជិតខាងនឹងគ្នា ធ្វើការទំនាក់ទំនងគ្នាទៅវិញទៅមកអោយកាន់តែល្អប្រសើរឡើងថែមទៀត។ ឯកឧត្តមបានបញ្ជាក់ថា នៅក្នុងជំនួបខាងលើ អាជ្ញាធរខេត្តបន្ទាយមានជ័យ បានស្នើសុំអោយភាគីថៃជួយទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ ដែលលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅក្រុងបាងកក និងធ្វើការងារតាមខ្សែបន្ទាត់ព្រំដែន លួចកាប់ឈើ និងបទល្មើសរួមមាន ជួញដូរមនុស្សដោយខុសច្បាប់ បទល្មើសលួចឆ្លងដែនកាប់ឈើគ្រញូង ជួញដូរអាវុធខុសច្បាប់ និងជួញដូរទំនិញគេចពន្ធ ត្រូវទប់ស្កាត់អោយបាន៕

## អន្តរជាតិបារម្ភពីការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជនភៀសខ្លួននៅមីយ៉ាន់ម៉ា

http://ann.com.kh/ ថ្ងៃពុធ, 15 ខែវិច្ឆិកា 2017 4:34 ល្ងាច

អង្គការអន្តរជាតិទទួលបន្ទុកផ្នែកជនភៀសខ្លួនចេញក្រៅប្រទេស នៃអង្គការសហប្រជាជាតិ ឲ្យដឹងកាលពីម្សិលមិញថា ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ កំពុងមានកាន់តែច្រើនឡើង ក្នុងចំណោមជនភៀសខ្លួនរ៉ូហ៊ីងយ៉ា ដែលភៀសខ្លួនគេចពី អំពើហិង្សាក្នុងប្រទេសមីយ៉ាន់ម៉ា។

ទីភ្នាក់ងារថា ខ្លួនទើបបានរកឃើញករណី ដែលបុរស ស្ត្រី និងកុមារ ត្រូវបានគេជ្រើសរើស ឲ្យធ្វើការងារមិនត្រឹមត្រូវ ដែលទទួលបានមកវិញនូវប្រាក់កម្រៃ ក្នុងវិស័យផ្សេងគ្នាជាច្រើន។ ពួកគេត្រូវបានគេរំលោភបំពាន និងកេង យកប្រយោជន៍ ចំណែកស្ត្រី និងក្មេងស្រី ទទួលរងការរំលោភបំពានផ្លូវភេទ ហើយស្ត្រីខ្លះដែលគេសន្យាផ្តល់ឲ្យការងារជាអ្នកជួយបម្រើកិច្ចការផ្ទះ បែរជាធ្លាក់ចូលក្នុងអំពើពេស្យាកម្មទៅវិញ៕

## ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧

# ឧត្តមសេនីយ៍ឯក ហួរ ឡាយ អញ្ជើញបិទវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការរំលោភបំពានលើអនីតិជន

http://cambodiapolice.com/blog/archives/ ម៉ោង 2:16 pm 17 វិច្ឆិកា 2017 13

ភ្នំពេញ ៖ នាព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ មានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងការរំលោភបំពានលើអនីតិជន ក្រោមកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DCI) ក្រសួងមហាផ្ទៃបារាំង ។ ពិធីនេះស្ថិតក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ហួរ ឡាយ អនុប្រធានដ្ឋានកណ្តាលនគរបាលយុត្តិធម៌ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងលោកវរសេនីយ៍ត្រី Olivier lefebvre អនុព័ន្ធសន្តិសុខផ្ទៃក្នុង (វៀតណាម កម្ពុជា ឡាវ ) អមស្ថានទូតបារាំង ប្រចាំទីក្រុងហាណូយ ប្រទេសវៀតណាម ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ហួរ ឡាយ អនុប្រធានដ្ឋានកណ្តាលនគរបាលយុត្តិធម៌ បានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះ មានមេរៀនសំខាន់ៗ និងការអនុវត្តជាក់ស្តែង សម្រាប់កិច្ចការងាររបស់មន្ត្រីនគរបាលយុត្តិធម៌នៅទូទាំងប្រទេស ។ ឯកឧត្តមបន្តថា យើងដឹងច្បាស់ថា បញ្ហារំលោភបំពានផ្លូវភេទ ក៏ដូចជាជួញដូរផ្លូវភេទកុមារ ពាក់ព័ន្ធការងាររំលោភលើអានីតិជននេះ គឺភាគ ច្រើន កើតទៅលើប្រទេសក្រីក្រ និងប្រទេសដែលកំពុងអភិវឌ្ឍក៏កើតច្រើនដែរ ។ ឯកឧត្តមអនុប្រធានដ្ឋានកណ្តាលនគរបាលយុត្តិធម៌ បានផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ដែលទើបបញ្ចប់វគ្គថា ក្នុងនាមយើងជាមន្ត្រីនគរបាលយុត្តិធម៌ គឺជាអ្នកអនុវត្តច្បាប់ ដាច់ខាតយើងត្រូវតែពង្រឹងនូវចំណេះដឹងផ្នែកច្បាប់ជាមូលដ្ឋាន ។ អ្វីដែលនគរបាលយុត្តិធម៌ត្រូវមើលហើយមើលទៀត គឺក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ទើបអាចពង្រីកចំណេះដឹងរបស់យើងបាន ។ មួយវិញទៀត ចេះច្បាប់ហើយ ប៉ុន្តែនៅ សល់អំពីនីតិវិធី មានន័យថា ប្រតិបត្តិការជាក់ស្តែង ដូចដែលយើង បានរៀនកន្លងមកនេះ គឺសុទ្ធតែជាចំណេះយកទៅអនុវត្តជាក់ស្តែង ។ ប៉ុន្តែថ្នាក់ដឹកនាំនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ក៏ដូចជាអគ្គស្នងការនគរបាលជាតិដឹងច្បាស់ណាស់ថា ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសការងារប្រយុទ្ធប្រឆាំងអំពើអណាចារលើកុមារការងារប្រយុទ្ធប្រឆាំងការរំលោភលើអានីតិជននេះ គឺលំបាកណាស់ ៖ ទី១.គឺពិបាកក្នុងការស្វែងរកភស្តុតាង ដើម្បីដាក់បន្ទុកលើជនល្មើស ដូច្នេះទាមទារឲ្យសមត្ថភាពយើងខ្លាំង និង ទី២. ពាក់ព័ន្ធការពង្រឹងនីតិវិធី ពង្រឹងសំណុំរឿងបញ្ជូនទៅតុលាការ ពេលខ្លះសំណុំរឿងដែលយើង ធ្វើហើយបញ្ជូនទៅតុលាការនោះ បើធ្វើមិនស្រួលទៅដល់តុលាការ របូតបាត់ក៏មានដែរ ។ អីចឹងហើយនាយកដ្ឋានកណ្តាលនគរបាល យុត្តិធម៌ មានរៀបចំបើកវគ្គបណ្តុះបណ្តាល ដើម្បីឲ្យមន្ត្រីអនុវត្តច្បាប់ ត្រូវពង្រឹងសំណុំរឿង គឺពង្រឹងភស្តុតាង ពង្រឹងនីតិវិធីទៅតុលាការ គឺជាកិច្ចការសំខាន់ ។ ឯកឧត្តមអនុប្រធានដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ជំនួសមុខឲ្យ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានស្នើសុំដល់លោកវរសេនីយ៍ត្រី Olivier lefebvre អនុព័ន្ធសន្តិសុខផ្ទៃក្នុង (វៀតណាម កម្ពុជា ឡាវ ) អមស្ថានទូតបារាំង ប្រចាំទីក្រុងហាណូយ ប្រទេសវៀតណាម ក៏ដូចជាគ្រូៗបង្គោល សូមឲ្យមានវគ្គបណ្តុះបណ្តាលនេះជាបន្តបន្ទាប់ទៀតផងដែរ ៕ ដោយ ៖ អនុសេនីយ៍ត្រី ខេន ពេជ្រ

## គណៈកម្មការផ្តល់ ភាពស្របច្បាប់ នឹងផ្អាកការិយាល័យ ផ្តល់លិខិតឆ្លងដែន, ធ្វើដំណើរ និងប័ណ្ណពលករខ្មែរទៅធ្វើការនៅបរទេស

https://www.dap-news.com/kh ព្រហស្បតិ៍, ១៦ វិច្ឆិកា ២០១៧ 18:52 ដោយ: ដើមអម្ពិល ID:030

ភ្នំពេញ៖ គណៈកម្មការផ្តល់ភាពស្របច្បាប់ នឹងផ្អាកដំណើរការ ការិយាល័យបើកផ្តល់លិខិតឆ្លងដែន ធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ប្រចាំខេត្តប៉ាធុមថានី ចាប់ពីថ្ងៃទី១៧ ខែវិច្ឆិកាឆ្នាំ២០១៧នេះតទៅ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខៈ ៦៣៧ គ.ផ.ថ

### សេចក្តីជូនដំណឹង

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃជ្រាបថា ការិយាល័យបើកផ្តល់លិខិតឆ្លងដែន (PP)/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ប្រចាំខេត្តប៉ាធុមថានី នឹងផ្អាកដំណើរការ **ចាប់ពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧** នេះតទៅ។ បងប្អូនពលករកម្ពុជាអាចបន្តដាក់ពាក្យស្នើសុំដក លិខិតឆ្លងដែន (PP)/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) នៅការិយាល័យទីក្រុងបាងកក ដែលមានទីតាំងនៅស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក ខេត្តឆាកឈើនសាវ និងខេត្តរ៉ាក់យ៉ង ជាធម្មតា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

បាងកក ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧
**ជ.ប្រធានគណៈកម្មការ**
**អនុប្រធាន**

**ឡុង ឌីម៉ារ៉ា**

**ក្រសួងការងារថៃ ត្រៀមផែនការបន្តការស្នាក់នៅ ដល់ពលករដែលត្រួតសញ្ជាតិមិនទាន់ ក្រោយ 31.03.2018**

http://www.trolldee.com/archives November 16, 2017

កាលពីថ្ងៃព្រហស្បតិ៍ទី16 ខែវិច្ឆិកា ឆ្នាំ2017 អគ្គនាយកដ្ឋានរដ្ឋមន្ត្រីក្រសួងការងារថៃបានផ្តល់បទសម្ភាសន៍ដល់សារព័ត៌មានក្នុងស្រុកថៃ បានដឹងថាក្រសួងការងារថៃ ត្រៀមស្នើច្បាប់ទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអោយក្រសួងមហាផ្ទៃថៃ ពិនិត្យពិចារណាលើច្បាប់ស្នាក់នៅរបស់ពលករចំណាកស្រុក។ បន្ទាប់ពីការត្រួតសញ្ជាតិរជូនពលករខ្មែរ,ឡាវ,ភូមា មានភាពយឺតយ៉ាវមិនទាន់តាមពេលវេលាកំណត់ក្នុងការផ្តល់បទសម្ភាសន៍នេះដែរ លោកអនុរ៉ាត ថុតរ៉ាត បានបញ្ជាក់ផងដែរថា ការដែលពលករបរទេសទាំងបីសញ្ជាតិ បញ្ជាក់អត្តសញ្ញាណយឺតយ៉ាវគឺមិនមែនជាកំហុសរបស់ក្រសួងការងារទេ.. គឺដោយសារតែភ្នាក់ត្រួត សញ្ជាតិរបស់ពលករខ្លួនឯងដែលដំណើរការយឺតយ៉ាវ។ ដូច្នេះក្រសួងការងារថៃបានត្រៀមផែនការនៅក្រោយថ្ងៃ31.03.2018 ដើម្បីជួយបន្តការស្នាក់នៅបណ្តោះអាសន្នដល់ពលករបរទេសដែលបញ្ជាក់អត្តសញ្ញាណមិនទាន់ពេលកំណត់ អ្នកស្នាក់នៅធ្វើការបាន តែត្រូវស្នើរឿងនេះទៅក្រសួងមហាផ្ទៃជាអ្នកសម្រេច។

## ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧

## រាជរដ្ឋាភិបាលធានាអត្ថប្រយោជន៍កម្មករកំពុងធ្វើការនៅក្រៅប្រទេស

https://www.dap-news.com/kh អាទិត្យ, ១៩ វិច្ឆិកា ២០១៧ 10:44 ដោយ: អេង ប៊ូឆេង ID:102

**ភ្នំពេញ ៖** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានអះអាងថា កម្ពុជាកំពុងចរចារជាមួយប្រទេសនានា ដើម្បីធានានូវអត្ថប្រយោជន៍ផ្សេងៗ ដល់កម្មករដែលកំពុងធ្វើការងារ នៅបរទេស ក្នុងនោះរួមទាំងប្រាក់ធានារ៉ាប់រង គ្រោះថ្នាក់ការងារ និងធានារ៉ាប់រងអាយុជីវិតជាដើម ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងក្នុងពិធីជួបសំណេះសំណាលជាមួយ កម្មករ៤,៦២៦នាក់ នៅកោះពេជ្រនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៧ថា "ចំពោះកូនក្មួយដែល កំពុងធ្វើការនៅក្រៅប្រទេស គឺត្រូវដឹងថា រាជរដ្ឋាភិបាលកម្ពុជា កំពុងចរចារជាមួយប្រទេសនានា ដើម្បីធានានូវអត្ថប្រយោជន៍ផ្សេងៗ ដល់ក្មួយៗ ក្នុងនោះគឺរួមទាំងប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ និងធានារ៉ាប់រងអាយុជីវិតជាដើម"។ ទន្ទឹមនឹងនោះដែរ រាជរដ្ឋាភិបាលនឹងសម្រួលឲ្យ សាច់ញាតិក្រុមគ្រួសារ នៅកម្ពុជាមាន សិទ្ធិធ្វើឯកសារមួយចំនួនដូចជា លិខិតថ្កោលទោស និងលិខិតបទដ្ឋានរដ្ឋបាល មួយចំនួនដែលកម្មករ ត្រូវការសម្រាប់ការងារ នៅប្រទេសក្រៅ ប៉ុន្តែមិនអាចធ្វើដំណើរមកកាន់កម្ពុជា ដោយសារជាប់បំពេញការងារ ។

សម្តេចបន្តថា រាជរដ្ឋាភិបាល កំពុងអនុវត្តកិច្ចការទាំងនេះ នៅប្រទេសកូរ៉េខាងត្បូង ហើយក៏កំពុងបន្តចរចារជាមួយ ប្រទេសនានាមួយចំនួនទៀត។ រាជរដ្ឋាភិបាលកំពុង ធ្វើការជាមួយ រដ្ឋាភិបាល និងក្រុមហ៊ុននានា នៅបរទេសឲ្យទទួលស្គាល់នូវរយៈពេល នៃអតីតភាពការងារដែលកម្មករ បានធ្វើការក្នុងក្រុមហ៊ុននោះ ។ សម្តេចបន្ថែមថា ចំនួនឆ្នាំនៃការងារដែលកម្មករបានធ្វើការ ទោះបីនៅទីណាក៏ដោយ នឹងយកមកបូកបញ្ចូល ជាមួយការងារថ្មីសម្រាប់គិតគូ បញ្ចូលទៅក្នុងប្រាក់រឺត្រែត នៅពេលដែលពួកគេដល់អាយុចូលនិវត្តន៍ (គ្រប់អាយុដែលអាចចូលរឺត្រែតបាន) ៕

**ពលករMOU ទាមទារអោយមានការកែសម្រួលច្បាប់ ដើម្បីប្តូរថៅកែថ្មី បានដោយមិនចាំបាច់ចូលលក្ខខ័ណ្ឌ**

http://www.trolldee.com/archives November 18, 2017

នេះគឺបញ្ហាដែលពលករបរទេស ចូលមកធ្វើការនៅប្រទេសថៃតាមរយៈ MOU ចង់ឲ្យរាជរដ្ឋាភិបាលថៃកែសម្រួលច្បាប់ដើម្បីឲ្យពួកអ្នកប្តូរថៅកែថ្មីបានដោយមិនចាំបាច់ចូលលក្ខខ័ណ្ឌ។ នេះគឺវិធីសាស្ត្រចូលមកធ្វើការនៅ

ប្រទេសថៃដោយស្រប់ច្បាប់តាមរយៈ MOU ចំពោះពលករបរទេសតែបញ្ហាជាប់នៅត្រង់ពលករដែលចូលមកធ្វើការតាមរយៈ MOU ហើយគឺមិនអាចប្តូរនិយោជិតថ្មីបានក្នុងរយៈពេល2 ឆ្នាំ លុះត្រាតែមានករណី,ថៅកែស្លាប់បាត់បង់ជីវិត, ក្រុមហ៊ុនក្ស័យធន, ធ្វេី ទារុណកម្ម លើពលករ, បង្ខំឲ្យពលករធ្វើការផ្សេងគ្រោះថ្នាក់។ បញ្ហានេះហើយដែលធ្វើឲ្យពលករបរទេសជួបការលំបាកក្នុងករណីចង់ប្តូរថៅកែថ្មីដោយមិនចូលក្នុងលក្ខខណ្ឌទាំង5 ខាងលើនេះ យ៉ាងណាមិញពលករបរទេសភាគច្រើនស្នើអោយរាជរដ្ឋាភិបាលថៃ កែសម្រួលច្បាប់នេះដើម្បីឲ្យពួកគាត់អាចប្តូរថៅកែក្នុងករណីចាំបាច់។

## សមត្ថកិច្ចថៃចាប់ខ្លួនថៃនិងខ្មែរ១៦នាក់ ពីបទលួចចូលកាប់ឈើគ្រញូង

http://cambodiapolice.com/blog/archives/ ម៉ោង 11:12 am 18 វិច្ឆិកា 2017 14

ប្រទេសថៃ ៖ ជនសង្ស័យចំនួន១៦នាក់ ដែលក្នុងនោះមានពលករខ្មែរចំនួន១៥នាក់ផងនោះ ត្រូវបានកំលាំងចម្រុះថៃធ្វើការចាប់ខ្លួន ព្រមទាំងបានបញ្ជូនទៅឲ្យកម្លាំងជំនាញ ស្រុក វឌ្ឍនាណៈខន ដើម្បីសាកសួរបន្តផងដែរ ខណៈដែលពួកគេទាំងអស់គ្នាបានលបលួចចូលទៅកាន់ និងស្ពាយឈើគ្រញូងជាច្រើនផ្ទាំង ចេញពីតំបន់ព្រៃហាមឃាត់ ។

យោងតាមរបាយការណ៍របស់ភាគីថៃ បានអោយដឹងថា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧វេលាម៉ោង៧ព្រឹក កំលាំងចម្រុះដែលមានក្រុមទាហានឈុតខ្មៅ តម្រួត មន្រ្តីអនុរក្ស តំបន់ ឧទ្យានជាតិ ប៉ាងស៊ីដា និងកំលាំងរដ្ឋបាលព្រៃឈើ សរុបប្រមាណ៣០នាក់បានធ្វើការឡោមព័ទ្ធ និងរុកចូលទៅក្នុងព្រៃ ក្នុងតំបន់ហាមឃាត់ខាងលើ បន្ទាប់ពីទទួលបានព័ត៌មានថា មានមនុស្សជាច្រើននាក់បានលបចូលទៅក្នុងព្រៃ ដើម្បីស្ពាយផ្ទាំងឈើគ្រញូងចេញមកក្រៅប្រគល់ទៅអោយមេឈ្មួញ ។

នៅក្នុងកិច្ចប្រតិបត្តិការចម្រុះនេះ កំលាំងសមត្ថកិច្ចបានឃាត់ខ្លួនមនុស្សសរុបចំនួន១៦នាក់ដែលក្នុងនោះមានជនជាតិថៃម្នាក់ និងជនជាតិខ្មែរចំនួន១៥នាក់ ព្រមទាំងបានដកហូតឈើគ្រញូងបានចំនួន ៤៣ផ្ទាំង កាំភ្លើងកែច្នៃ ចំនួន៦ដើម និងកញ្ចាមួយចំនួន ដែលទីតាំងនៃការឃាត់ខ្លួននេះ ស្ថិតក្នុងតំបន់ម៉ែសិរីចំប៉ា ក្នុងឃុំណងម៉ាកហ្វាយ ស្រុកវឌ្ឍនាណៈខន ខេត្តស្រះកែវ ប្រទេសថៃ ។

ក្រោយពីធ្វើការឃាត់ខ្លួន ព្រមទាំងបានដកហូតនូវវត្ថុតាងមួយចំនួនរួចមក សមត្ថកិច្ចបានបញ្ជូនខ្លួនជនសង្ស័យទាំងអស់ ទៅកាន់ផ្នែករដ្ឋបាលព្រៃឈើ ស្រុកវឌ្ឍនាណៈខនដើម្បីសាកសួរបន្ត រកមេក្លោងដែលនៅពីក្រោយខ្នង ក្នុងការអនុវត្តតាមផ្លូវច្បាប់ ៕

## ក្រសួងការងារ កំណត់ប្រាក់ឈ្នួលជូនកម្មករនេសាទចាប់ពី 1.2000 បាត ឡើងទៅ

http://www.trolldee.com/archives November 18, 2017

ក្រសួងការងារថៃកំណត់ប្រាក់ឈ្នួលជូនកម្មករធ្វើការនេសាទចាប់ពី12000បាត ដោយតំរូវអោយថៅបង់ជូនតាមធានាគា។ កាលពីពេលថ្មីកន្លងទៅនេះក្រសួងការងារថៃ បានប្រកាសកំណត់អោយនិយោជកថៃ ដែលប្រកបអាជីវកម្មនេសាទត្រី ត្រូវបើកប្រាក់ខែជូនកម្មករនេសាទតាមរយៈប្រព័ន្ធធនាគារ ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យប្រាក់ឈ្នួលរបស់ពលករ បន្ទាប់ពីក្រសួងប្រកាសកំណត់ប្រាក់ឈ្នួលជូនកម្មករធ្វើការនេសាទត្រីចាប់ 12.000បាតក្នុងមួយខែ។

## ពលករខ្មែរម្នាក់ស្រវឹងស្រាបោកបរបើករថយន្តក្រឡាប់ធ្លាក់ស្រែ តែសំណាងល្អមិនមានគ្រោះថ្នាក់

http://www.trolldee.com/archives November 18, 2017

កាលពីថ្ងៃព្រហស្បតិ៍ ទី16 ខែវិច្ឆិកា ឆ្នាំ2017 កន្លងទៅមានករណីគ្រោះថ្នាក់ចរាចររថយន្តក្រឡាប់ធ្លាក់ស្រែមួយ បានកើតឡើងនៅត្រង់ចំណុចផ្លូវជាតិសុខុមវិត ស្ថិតក្នុងឃុំ ថាឆាង ស្រុកមឿង ខេត្តចាន់បុរី ។ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា រថយន្តបើកក្រឡាប់ធ្លាក់ស្រែនោះម៉ាក អីស៊ុយស៊ុយ ពាក់ស្លាកលេខ 5510 ចាន់បុរីបើកបរដោយកម្មករខ្មែរម្នាក់ឈ្មោះប៊ុន សនតិកព អាយុ 21ឆ្នាំ ធ្វើការនៅកន្លែងជួសជុលនិងតុបតែងគ្រឿងសៀងរថយន្ត(ធ្វេីម៉ាញ៉េឡាន )នៅក្នុងខេត្តចាន់បុរី។

យោងតាមការបកស្រាយរបស់កម្មករខ្មែរខាងលើ បានប្រាប់អោយដឹងថា ក្រោយពីរូបគេបានផឹកស្រាស្រវឹងស្រឿងៗ បានយករថយន្តដែលភ្ញៀវយកមកជួសជុលនៅកន្លែងធ្វើការ ហើយសាកបើកបរលេងតែមកដល់ត្រង់ចំណុចកើតហេតុជាផ្លូវកោង បានបួងចង្កូតរថយន្តមិនទាន់ធ្វើឲ្យរថយន្តក្រឡាប់ធ្លាក់ផ្លូវចូលក្នុងស្រែម្តង។ បច្ចុប្បន្នកម្មករខ្មែររូបនោះត្រូវ សមត្ថកិច្ចថៃឃាត់ខ្លួនយកទៅកាន់ប៉ុស្តិ៍តម្រួតខេត្តចាន់បុរីដើម្បីត្រួតពិនិត្យជាតិអាកុលនៅក្នុងខ្លួន កសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវ។

## ពលករខ្មែរ ១៥ នាក់ត្រូវតុលាការថៃឃុំខ្លួនពាក់ព័ន្ធនឹងការឆ្លងដែនចូលកាប់ឈើ

http://www.phnompenh-post-news.html Mon, 20 November 2017 យុត សុភចរិយា

**បន្ទាយមានជ័យ:** ប្រជាពលករខ្មែរចំនួន ១៥ នាក់ និងបុរសជនជាតិថៃម្នាក់ ត្រូវបានតុលាការខេត្តស្រះកែវប្រទេសថៃ សម្រេចឃុំខ្លួនពាក់ព័ន្ធនឹងករណីឆ្លងដែនចូលទៅកាប់ឈើគ្រញូងក្នុងតំបន់ព្រៃការពារ និងប្រើប្រាស់អាវុធខុសច្បាប់ បន្ទាប់ពីពួកគេត្រូវបានចាប់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍ដោយកម្លាំងសមត្ថកិច្ចចម្រុះថៃប្រចាំស្រុកវឌ្ឍនាណៈខន។ នេះបើយោងតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកថៃដែលបានផ្សព្វផ្សាយកាលពីម្សិលមិញ។

យោងតាមប្រព័ន្ធផ្សព្វផ្សាយរបស់ Amarin TV Channel 34, TV3 និង TV8 របស់ប្រទេសថៃដែលបានផ្សាយកាលពីម្សិលមិញបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមសមត្ថកិច្ចចម្រុះថៃដែលរួមមាន កម្លាំងយោធាព្រំដែន មន្ត្រីឧទ្យានុរក្ស និងកម្លាំងសមត្ថកិច្ចស្រុកវឌ្ឍនាណៈខន ខេត្តស្រះកែវសរុបជាង ៣០ នាក់បានបើកប្រតិបត្តិការរួមគ្នាក្នុងកិច្ចការពារ និងទប់ស្កាត់បទល្មើសឆ្លងដែន និងព្រៃឈើកាលពីថ្ងៃព្រហស្បតិ៍ទី ១៦ ខែវិច្ឆិកាឆ្នាំ ២០១៧ ដែលឈានទៅដល់ការបង្ក្រាប និងធ្វើការចាប់ជនសង្ស័យចំនួន ១៦ នាក់ ដែលនៅក្នុងនោះ ១៥ នាក់ជាជនជាតិកម្ពុជា និង ម្នាក់ជាជនជាតិថៃរួមទាំងរឹបអូសបានវត្ថុតាងមួយចំនួនទៀតផង។ បណ្ដាញសារព័ត៌មានទាំងនោះក៏បានដកស្រង់សម្ដីរបស់លោកវរសេនីយ៍ទោ Siwatat O Chaiwat ដែលដឹកនាំនៅក្នុងប្រតិបត្តិការនោះមកបញ្ជាក់ថា៖ «ក្រោយការចាប់ខ្លួនក្រុមកម្លាំងសមត្ថកិច្ចចម្រុះបានឆែករកឃើញមានអាវុធកែច្នៃ ៦ ដើម កញ្ឆាក្រៀម ៥ គីឡូក្រាម និង ឈើគ្រញូង ៤៣ ផ្ទាំងដែលមានទម្ងន់សរុប ១៥០០ គីឡូក្រាម»។

ក្រោយពីការចាប់ឃាត់ខ្លួនជនសង្ស័យទាំង ១៦ នាក់ត្រូវបានសមត្ថកិច្ចបញ្ជូនទៅកាន់តុលាការខេត្តស្រះកែវដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់ហើយកាលពីថ្ងៃសៅរ៍។ ពួកគេទាំងនោះត្រូវបានតុលាការចោទប្រកាន់ពីបទ « កាប់បំផ្លាញព្រៃឈើក្នុងតំបន់ការពារ និងប្រើប្រាស់អាវុធខុសច្បាប់» និងបង្គាប់ឲ្យនាំយកទៅឃុំខ្លួនជាបណ្ដោះអាសន្នដើម្បីរង់ចាំការជំនុំជម្រះជាក្រោយ ។

កាលពីពេលថ្មីៗកន្លងទៅនេះ អាជ្ញាធរខេត្តបន្ទាយមានជ័យប្រទេសកម្ពុជា និងអាជ្ញាធរខេត្តស្រះកែវប្រទេសថៃបានបើកកិច្ចប្រជុំមួយស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការគ្នាទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទដើម្បីរក្សាសន្តិភាពនៅតាមបន្ទាត់ព្រំដែននៃប្រទេសទាំង ២។

ជុំវិញករណីនេះលោក ឃួន ជឿន មេបញ្ជាការយោធាវរការពារព្រំដែនលេខ ៥០៣ កាលពីម្សិលមិញបាន ថ្លែងថា ហេតុមកទល់ពេលនេះលោកនៅមិនទាន់ទទួលបានរបាយការណ៍ណាមួយពីភាគីយោធាថៃនៅឡើយទេ។ លោកបានបន្តថា ទោះជាបែបណាព័ត៌មាននោះលោកបានដឹងរួចមកហើយតាមរយៈប្រព័ន្ធផ្សព្វផ្សាយថៃកាលពីថ្ងៃ សៅរ៍។ ស្រដៀងគ្នានេះដែរលោក យ៉ាល់ ប៊ុនពៅ មន្ត្រីទំនាក់ទំនងកិច្ចការព្រំដែនកម្ពុជា-ថៃ ប្រចាំច្រកទ្វារព្រំដែន អន្តរជាតិប៉ោយប៉ែតថ្លែងថាករណីនេះក្រុមការងាររបស់លោកក៏មិនទាន់ទទួលបានរបាយការណ៍ផ្លូវការណាមួយពី ភាគីថៃនោះដែរ។

ដោយឡែក អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃលោក ហ៊ិន សារឿន និងលោក ជុំ សុន្ទរី អ្នក នាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាមិនអាចទំនាក់ទំនងសុំ អធិប្បាយបានទេជុំវិញករណីនេះកាលពីម្សិលមិញ៕

## អាជ្ញាធរថៃដឹកសពពលករខ្មែរម្នាក់ទៀតហើយ ប្រគល់ឲ្យសាច់ញាតិ

http://www.domnoeng-phnompenh-news.html Posted by ដំណឹងភ្នំពេញ on 15/11/2017

បន្ទាយមានជ័យ ៖ ស្ត្រីជាពលករខ្មែរម្នាក់បានស្លាប់នៅមន្ទីរពេទ្យក្នុងខេត្តចាក់ធីនសៅ ប្រទេសថៃ ក្រោយ ឧប្បត្តិហេតុគ្រោះថ្នាក់ចរាចរ រថយន្តថៃកៀរម៉ូតូ ហើយត្រូវបានគេបញ្ជូនសពប្រគល់ឲ្យសាច់ញាតិតាមច្រកទ្វារអន្តរ ជាតិប៉ោយប៉ែត កាលពីម៉ោងជាង០៥ល្ងាច ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។ ជនរងគ្រោះឈ្មោះ ស ចន្ថា អាយុ៣៤ ឆ្នាំ ជាកម្មកររោងចក្រ នៅក្នុងខេត្តកើតហេតុខាងលើ និងមានទីលំនៅភូមិស្ទឹងចាស់ ឃុំគយម៉ែង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

តាមសាច់ញាតិប្រាប់ថា ជនរងគ្រោះជួបឧប្បត្តិហេតុជិះម៉ូតូត្រូវរថយន្តថៃកៀរជួលរបួសធ្ងន់ ហើយបញ្ជូន ទៅព្យាបាលនៅមន្ទីរពេទ្យក្នុងខេត្តកើតហេតុ តាំងពីព្រឹកថ្ងៃទី០៦ ឆ្នាំវិច្ឆិកា ឆ្នាំ២០១៧ ទើបស្លាប់នៅម៉ោងជាង០៤ ទាបភ្លឺព្រឹក ថ្ងៃទី១៣ ខែឆ្នាំដដែល ។ តាមសាច់បញ្ជាក់ថា ជនរងគ្រោះជាមនុស្សកំព្រាទៅរស់នៅប្រទេសថៃតាំងពី ក្មេង ។ សពត្រូវបានសាច់ញាតិដឹកតាមរថយន្តផ្ទាល់ខ្លួនទៅលំនៅដ្ឋាន ដើម្បីធ្វើបុណ្យតាមប្រពៃណី៕

## លីប៊ី ៖ នឹងស៊ើបអង្កេតរឿងការជួញដូរទាសករ

http://www.phnompenh-thmey-news. ចេញផ្សាយ ថ្ងៃទី 20/11/2017

លីប៊ី ៖ រដ្ឋាភិបាលបានប្រកាសកាលពីថ្ងៃអាទិត្យថា ប្រទេសលីប៊ីនឹងស៊ើបអង្កេតការជួញដូរទាសករនៅក្នុង ប្រទេសនេះបន្ទាប់ពីមានការចេញផ្សាយវីដេអូដែលបង្ហាញថា ជនចំណាកស្រុកកំពុងត្រូវបានគេដាក់ដេញថ្លៃ។ ប្រទេសលីប៊ីដែលមានភាពវឹកវរជាយូរមកហើយ គឺជាមជ្ឈមណ្ឌលឆ្លងកាត់ដ៏សំខាន់មួយសម្រាប់ជនអន្តោប្រវេសន៍ ដែលព្យាយាមទៅដល់អឺរ៉ុប ហើយពួកគេជាច្រើននាក់ត្រូវបានរំលោភបំពានយ៉ាងសាហាវនៅក្នុងប្រទេសអាហ្វ្រិក ខាងជើងមួយនេះក្នុងដៃអ្នកជួញដូរនិងអ្នកដទៃទៀត។

បណ្តាញទូរទស្សន៍ CNN របស់អាមេរិកបានចាក់ផ្សាយវីដេអូមួយកាលពីសប្តាហ៍មុននៃការលក់ដេញថ្លៃ ផ្ទាល់ក្នុងប្រទេសលីប៊ីដែលជាកន្លែងបុរសស្បែកខ្មៅត្រូវបានគេបង្ហាញទៅអ្នកទិញអាហ្វ្រិកខាងជើងហើយបានលក់ ក្នុងតម្លៃត្រឹមតែ៤០០ដុល្លារប៉ុណ្ណោះ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយដែលបានបង្ហោះកាលពីថ្ងៃអាទិត្យនៅលើ ទំព័រហ្វេសប៊ុករបស់ការិយាល័យសារព័ត៌មាន GNA បានឲ្យដឹងថា លោកឧបនាយករដ្ឋមន្ត្រី Ahmed Metig បាន និយាយថា រដ្ឋាភិបាលដែលគាំទ្រដោយអង្គការសហប្រជាជាតិរបស់គាត់នឹងស៊ើបអង្កេតការចោទប្រកាន់ទាំងនោះ។ លោក Metig បាននិយាយថា លោកនឹងណែនាំការបង្កើតគណកម្មការមួយក្នុងការស៊ើបអង្កេតរបាយការណ៍ទាំង នេះដើម្បីចាប់ខ្លួននិងនាំអ្នកដែលទទួលខុសត្រូវមកកាត់ទោស។

របាយការណ៍ដាក់ស្តែងរបស់ CNN ដែលបង្ហាញជនចំណាកស្រុកកំពុងត្រូវបានលក់ដេញថ្លៃនៅក្នុងប្រទេសលីប៊ីគឺត្រូវបានចែករំលែកយ៉ាងទូលំទូលាយនៅលើបណ្តាញសង្គមហើយបង្កឲ្យមានកំហឹងនៅអាហ្វ្រិក អឺរ៉ុប និងពិភពលោកទាំងមូល។វីដេអូថតដោយកាមេរ៉ាទូរស័ព្ទបានបង្ហាញពីបុរសម្នាក់ដែល CNN និយាយថាជាជនជាតិនីហ្សេរីយ៉ាក្នុងវ័យ២០ឆ្នាំត្រូវបានដាក់លក់ដើម្បីយកទៅធ្វើកសិកម្ម។ នៅក្នុងរបាយការណ៍របស់ទូរទស្សន៍ CNN បានបង្ហាញថា មនុស្សម្នាក់ដែលត្រូវបានគេស្គាល់ថាជាអ្នកដាក់ដេញថ្លៃគឺអាចត្រូវបានគេឮនិយាយថា "៨០០ ... ៩០០ ... ១,០០០ ... ១,១០០ ..."មុនពេលបុរសពីរនាក់ត្រូវបានគេលក់ដាច់ក្នុងតម្លៃ ១,២០០ ឌីណាលីប៊ី (៨៧៥ ដុល្លារអាមេរិក) ។

យោងតាមប៉ូលិសបារាំងបានឲ្យដឹងថា មនុស្សប្រហែល១,០០០នាក់បានធ្វើដំណើរតាមដងផ្លូវនៅទីក្រុងប៉ារីសកាលពីថ្ងៃសៅរ៍ដើម្បីតវ៉ាប្រឆាំងនឹងទាសភាពនៅក្នុងប្រទេសលីប៊ី។ ការជួបជុំគ្នានេះបាននាំឲ្យមានការប៉ះទង្គិចគ្នារវាងបាតុករនិងកងកម្លាំងសន្តិសុខ។ ជនអន្តោប្រវេសន៍អាហ្វ្រិកមកពីប្រទេសជាច្រើនរួមមានប្រទេសហ្គីណេ សេណេហ្គាល់ ម៉ាលី នីហ្សេរ នីហ្សេរីយ៉ានិងហ្គាំប៊ីគឺបានធ្វើដំណើរប្រកបដោយគ្រោះថ្នាក់ឆ្លងកាត់សមុទ្រខ្សាច់សាហារ៉ាទៅប្រទេសលីប៊ីដោយសង្ឃឹមថានឹងឆ្លងកាត់សមុទ្រមេឌីទែរ៉ាណេឆ្ពោះទៅប្រទេសអ៊ីតាលី៕

## ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧
## រាជរដ្ឋាភិបាលដាក់ចេញវិធានការ ទប់ស្កាត់ ការប្រើអំពើហិង្សាលើកុមារ

https://www.dap-news.com/kh ថ្ងៃច័ន្ទ, ២០ វិច្ឆិកា ២០១៧ 15:02 ដោយ: ធី លីថូ ID:069

ភ្នំពេញ៖ ស្របពេលកើតមានអំពើហិង្សាជារឿយៗ លើកុមារនៅកម្ពុជា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោកស្រី ខៀវ បុរី បានថ្លែងឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីទប់ស្កាត់ ការប្រើប្រាស់អំពើហិង្សាលើកុមារ។

លោកស្រី ខៀវ បុរី បានថ្លែងក្នុងពិធីបើកយុទ្ធនាការ It Takes a World ដើម្បីបញ្ឈប់ អំពើហិង្សាលើកុមារ នៅផ្ទះនិងសាលារៀន ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ថា "រដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន រួមមាន៖ ការអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានយន្តការ កិច្ចសហការថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធានាឲ្យបាននូវសុខុមាលភាពកុមារ និងការការពារ សង្គមចំពោះ កុមារកម្ពុជា"។ លោកស្រីបានបន្តថា ក្រសួងសង្គមកិច្ច និងក្រុមប្រឹក្សាជាតិកម្ពុជា កំពុងដំណើរការអនុវត្តលើការងារ រស់រានមានជីវិតក្នុងការអភិវឌ្ឍ ការការពារ លើកកំពស់សុខុមាលភាព និងការរួមចំណែករបស់កុមារឲ្យបាននូវសិទ្ធិទាំងបួនរបស់ពួកគេផងដែរ។ លោកស្រី ខៀវ បុរី បានឲ្យដឹងទៀតថា ជានិច្ចការសិទ្ធិកុមារភាព របស់ពួកគេ ត្រូវបានគំរាមកំហែង ដោយកង្វះការការពារអំពើហិង្សារបស់ពួកគេ នៅកន្លែង ដែលមានសុវត្ថិភាពបំផុតរបស់ពួកគេ ។ កន្លែងទាំងនោះរួមមាន៖ នៅតាមសាលារៀន និងតាមផ្ទះជាដើម។

រដ្ឋលេខាធិការក្រសួងសង្គមកិច្ចបានបន្ថែមថា សក្ខីភាពប្រវត្តិសាស្ត្រ លុបបំបាត់ ការប្រើប្រាស់ អំពើហិង្សាលើកុមារ ក្លាយជាគោលដៅមួយដ៏សំខាន់ ក្នុងការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយចីរភាព នៅថ្ងៃខាងមុខផងដែរ។ ចំណែកខាងក្រសួងកិច្ចការនារី ក៏បានធ្វើការប្តេជ្ញាចិត្តខ្ពស់ ដើម្បីលុបបំបាត់ការប្រើប្រាស់ អំពើហិង្សាលើកុមារ និងស្ត្រីឲ្យមានប្រសិទ្ធិភាពផងដែរ។ សូមបញ្ជាក់ថា កុមារចំនួន ១,៧ កោដិនាក់ ត្រូវបានរងគ្រោះពីការប្រើប្រាស់អំពើហិង្សា ជារៀងរាល់ឆ្នាំ នៅគ្រប់បណ្តាលប្រទេស និងសហគមន៍។ នៅកម្ពុជា កុមាររងគ្រោះដោយអំពើហិង្សា មានចំនួន ៧៥% (ផ្លូវកាយ និងផ្លូវចិត្ត)។ ៥០% ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ , ២៥% ទទួលរងអំពើហិង្សាផ្លូវចិត្ត និង៥% ទទួលរងអំពើហិង្សាផ្លូវភេទ៕

## ស្ត្រីជាមេខ្យល់២នាក់ដែលមានមុខរបរជួញដូរនារីខ្មែរឲ្យទៅយកប្តីនៅប្រទេសចិន ពីបទលក់ដូរមនុស្សសម្រាប់ឆ្លងដែន

http://www.ariyothom-news.html ( ថ្ងៃទី 20 November 2017 ម៉ោង 3:01 pm )

ក្រចេះ ៖ កាលពីសៀលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ត្រីជាមេខ្យល់២នាក់ដែលមានមុខរបរជួញដូរនារីខ្មែរឲ្យទៅយកប្តីនៅ ប្រទេសចិនដោយខុសច្បាប់នោះ ត្រូវបានតុលាសេម្រេចឃុំខ្លួន នៅពន្ធនាគារខេត្ត ពីបទលក់ដូរមនុស្សសម្រាប់ឆ្លងដែន ។ ការឃុំខ្លួនស្ត្រីមេខ្យល់ធ្វើឡើងក្រោយរយៈពេល៣ថ្ងៃបន្ទាប់ពីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបានចុះទៅចាប់ខ្លួនស្ត្រីសង្ស័យទាំង២នាក់បាន នៅនឹងលំនៅឋានរៀងៗខ្លួន នៅក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ស្ត្រីជាមខ្យល់ទាំងពីរនាក់មួយ – ភីម ខេម៉ា អាយុ៤៥ឆ្នាំ និងម្នាក់ទៀត ដូ ស៊ីណាត អាយុ៤៣ឆ្នាំ ទាំងពីរនាក់ត្រូវបាននគរបាលចាប់ខ្លួនបានក្នុងថ្ងៃតែមួយទី១៦ វិច្ឆិកា ឆ្នាំ២០១៧ ។

ស្ត្រីទាំង២នាក់នេះបានប្រព្រឹត្តសកម្ម ភាពនាំនារីខ្មែរចំនួន២នាក់ឲ្យទៅយកប្តីនៅប្រទេសចិនដោយខុសច្បាប់ តែ ត្រូវបាននគរបាលហាមឃាត់ទាន់ពេលនៅពេលដែលនារីរងគ្រោះទាំងពីរនាក់ត្រូវបាន ក្រុមស្ត្រីមេខ្យល់បញ្ជូនតាមយន្តហោះទៅដល់ប្រទេសវៀតណាម ។ ក្រោយការចាប់ខ្លួនស្ត្រីជាមេខ្យល់ទាំងពីរនាក់បាននគរបាលការិយាល័យជំនាញ កសាងសំណុំរឿង និងចាត់បញ្ជូនទៅតុលាការខេត្ត និងបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្ត ក្រោមដីកាបង្គាប់លោក ឱន ស៊ីវុទ្ធី ប្រធានសាលាដំបូងខេត្ត និងជាចៅក្រមស៊ើបសួរ ៕

## ថៃចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរ២នាក់ ខណៈលួចចូលកាប់ឈើក្រញូង

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 20/11/2017

ខេត្តបន្ទាយមានជ័យ ៖ ពលរដ្ឋខ្មែរចិត្តស្លុយ២នាក់ហានចូលទៅក្នុងទឹកដីថៃលួចកាប់ឈើក្រញូងត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនកាលពីវេលាម៉ោង១១ព្រឹក ថ្ងៃទី១៩ ខែវិច្ឆកា ឆ្នាំ២០១៧ នៅចំណុចឡាក់២៨ ស្ថិតក្នុងភូមិសាស្ត្រព្រំប្រទល់ភូមិដងរ៉ែកឆ្លក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ត្រី ដុំ ចិត្រ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថស្រុកថ្មពួកបានប្រាប់ឲ្យដឹងថាខ្មែរចូលទៅទឹកដីថៃលួចកាប់ឈើក្រញូងនោះមានឈ្មោះ តូ ស្រឿង ប្រុស អាយុ៣៨ឆ្នាំ ២មានឈ្មោះ ស្តើង ស្រើង ប្រុស អាយុ៣៣ឆ្នាំ អ្នកទាំង២ រស់នៅភូមិអំពិល ឃុំអំពិល ស្រុកអំពិល ខេត្តឧត្តមានជ័យ។លោក ដុំ ចិត្ត បានបញ្ជាក់ឲ្យដឹងទៀតថានៅមុនពេលកើតហេតុនោះខ្មែរទាំង២នាក់នោះបាននាំគ្នាលួចចូលទៅទឹកដីថៃដើម្បីលួចកាប់ឈើក្រញូងបានចំនួន៩០កំណាត់ នៅចំណុចឡាក់២៨ទឹកដីថៃ ពេលកំពុងធ្វើសកម្មភាពដឹកជញ្ជូនឈើក្រញូងចេញពីស្រុកថៃដឹកចូលយកមកដីខ្មែរនោះត្រូវបានតម្រួត និងមេព្រៃថៃ ចាប់ឃាត់ខ្លួនរួមទាំងវត្ថុតាងមានឈើគ្រញូងចំនួន៩០កំណាត់យកមកទីស្នាក់ការមេព្រៃដើម្បីសួនាំ។

លោក ដុំ ចិត្រ បានឲ្យដឹងទៀតថាសមត្ថកិច្ចថៃនិងមេព្រៃបានធ្វើការផ្តល់ព័ត៌មានដល់សមត្ថកិច្ចខ្មែរថាជនសង្ស័យទាំង២នាក់នោះក្រោយពីសួរនាំរួចមកបានកសាងសំនុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់ការទៅតាមនិតិវិធីច្បាប់ហើយ៕

## កម្មករចំណាកស្រុក19នាក់ ត្រូវកម្លាំងអាជ្ញាធរថៃឃាត់ខ្លួន

http://www.pheaktraprak.com November 20, 2017

កាលពីថ្ងៃអាទិត្យ ទី19 ខែវិច្ឆិកា ឆ្នាំ2017កន្លង កម្លាំងអាជ្ញាធរមូលដ្ឋាន ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ បានដឹកនាំកម្លាំងចុះឃាត់ខ្លួនពលករចំណាកខុសច្បាប់ ចំនួន19 នាក់ ក្នុងនោះមានបុរស 08នាក់ នារី11នាក់ ខណៈពេលកំពុងលួនតាមបន្ទាលួសក្បែរប្រេកព្រំដែនផ្សារលុងក្លឿរ។ ករណីនេះបានកើតឡើងនៅវេលាម៉ោង05:30នាទីល្ងាចនត្រង់ចំណុចក្រោយផ្សារ(ធេសបានសង)ឃុំខ្លងលឹក ស្រុកអារញ្ញ បន្ទាប់ពីមានកម្មករចំណាកស្រុកខុសច្បាប់ប្រុសស្រី 19នាក់ បាននាំគ្នាឆ្លងដែនខុសច្បាប់ តាមរយៈបន្ទាត់ព្រំដែនថៃ-ខ្មែរ ដើម្បីចូលទៅស្វែងរកការងារធ្វើនៅឯទីក្រុងបាងកកប្រទេសថៃ។

## ថៃប្រកាសសម្រួលឯកសារជូនពលករត្រួតសញ្ជាតិ ឱ្យកាន់តែលឿនជាងមុន

http://www.pheaktraprak.com November 20, 2017

អគ្គនាយករងក្រសួងការងារថៃប្រកាសជួយសម្រួល ឯកសារប័ណ្ណអនុញ្ញាតការងារដល់ពលករខ្មែរ, ភូមា បន្ទាប់ពីបញ្ជាក់អត្តសញ្ញាណរួចរាល់ អោយបានឆាប់រហ័សជាងមុន។ អគ្គនាយករងនៃក្រសួងការងារថៃលោកស្រី កេតវ៉ាត់ សិនអួយ បានប្រកាសប្រាប់សារព័ត៌មានក្នុងស្រុកថៃ កាលពីថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2017 នេះអោយបានដឹងថា ក្រសួងការងាថៃ ត្រៀមជួយសម្រួលឯកសារដល់ពលករកម្ពុជា និងភូមា ដែលបញ្ជាក់អត្តសញ្ញាណនៅការិយាល័យនីមួយៗក្នុងប្រទេសថៃ អោយបានឆាប់រហ័សលឿនជាងរយៈពេលមុន និងពេលឆាប់ៗខាងមុខនេះ។

## ថៃប្រកាសចាប់ ជនអន្តោប្រវេសន៍ឲ្យអស់នៅឆ្នាំ 2018 ខាងមុខនេះ

http://www.pheaktraprak.com November 18, 2017

រាជរដ្ឋាភិបាលថៃ ប្រកាសប្រជុំមន្ត្រីរាជការ ទាហ៊ាន តម្រួត.ទាំងអស់បើកកិច្ចប្រជុំ ស្តីពីបញ្ហាការជួញដូរមនុស្ស និងពលករចំណាកខុសច្បាប់ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ។ ក្នុងកិច្ចប្រជុំលោកនាយករដ្ឋមន្ត្រីបានលើកឡើងពីបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃដោយគ្មានច្បាប់អនុញ្ញាត និងអំពើជួញដូរមនុស្សខុសច្បាប់ នៅដើមឆ្នាំ2018 ខាងមុខនេះ កម្លាំងសមត្ថកិច្ចនិងបើកយុទ្ធនាការបង្រ្កាបជនអន្តោប្រវេសន៍ខុសច្បាប់អោយអស់ពីប្រទេសថៃ។

## ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧
## សម្តេចតេជោ៖ កូនក្មួយដែលកំពុងធ្វើការនៅប្រទេសក្រៅត្រូវរក្សាក្រជាសស្នាមការងារទុកអោយបានល្អ

http://www.nokor-wat-news.html ភ្នំពេញ៖ នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧

ហ្វេសប៊ុកសម្តេចតេជោបានថ្លែងនៅលើបណ្តាញសង្គមហ្វេសប៊ុកយ៉ាងដូច្នេះថា៖ «កូនក្មួយដែលកំពុងធ្វើការនៅប្រទេសក្រៅត្រូវរក្សាក្រជាសស្នាមការងារទុកអោយបានល្អ កូនក្មួយកម្មករដែលកំពុងធ្វើការនៅក្រៅប្រទេសអស់រយៈពេលជាច្រើនឆ្នាំមកហើយ គឺត្រូវថៃរក្សាក្រដាស់ស្នាមនៃកិច្ចសន្យាការងារ ឬសៀវភៅការងារទុកអោយបានល្អ។ នៅពេលដែលកូនក្មួយផុតកិច្ចសន្យាការងារ (ផុតកុងត្រា) នៅទីនោះ ហើយផ្លាស់ទៅធ្វើការនៅកន្លែងផ្សេង ឬ

វិលត្រឡប់មកធ្វើការងាថ្មីនៅប្រទេសកម្ពុជាវិញ គឺកូនក្មួយនៅតែទទួលបានផលប្រយោជន៍អំពីអតីតភាពនៃការងារ ដែលក្មួយបានធ្វើ កន្លងមក។ ផលប្រយោជន៍ពីអតីតភាពនៃការងារនេះ គឺនឹងបូកចូលជាមួយការងារថ្មីនៅពេល ដែលក្មួយៗដល់អាយុចូលរីត្រៃតឈប់សម្រាកពីការងារ គឺក្មួយៗនឹងទទួលបានប្រាក់ចូលនិវត្តន៍(ប្រាក់រីត្រៃត) ពេញតែម្តង»។

## ខេត្តបន្ទាយមានជ័យជាលើកដំបូង បានបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានជូនដល់ប្រជាពលរដ្ឋស្វែងការងារធ្វើ

http://cambodiapolice.com/ ម៉ោង 6:08 pm 21 វិច្ឆិកា 2017 24

ខេត្តបន្ទាយមានជ័យ ៖ ខេត្តបន្ទាយមានជ័យជាលើកដំបូងបានបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានជូនដល់ប្រជាពលរដ្ឋ ដើម្បីស្វែងការងារធ្វើ គ្រាដែលគេមើលឃើញថា ខេត្តបន្ទាយមានជ័យជាខេត្តមួយជាប់ព្រំដែនកម្ពុជា-ថៃ មានប្រជាពលរដ្ឋបានធ្វើចំណាកស្រុកលក់កម្លាំងពលកម្មធ្វើការងារខុសច្បាប់នៅក្នុងប្រទេសថៃ ដែលជាបញ្ហាប្រឈមគ្រោះថ្នាក់ដោយប្រការផ្សេងៗរបស់ប្រជាពលរដ្ឋចំណាកស្រុកខុសច្បាប់នោះផងដែរ។ មជ្ឈមណ្ឌលផ្តល់ព័ត៌មានការងារខេត្តបន្ទាយមានជ័យ មានទីតាំងចំណុចភ្នំជញ្ជាំង សង្កាត់ទឹកថ្លាក្រុងសិរីសោភ័ណ ក្រោមជំនួយកសាងឧបត្ថម្ភថវិកាដោយប្រទេសស៊ុយអែត ធ្វើពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នៅព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ ប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ពេជ សោភ័ណ រដ្ឋលេខាធិការក្រសួងការងារ និងឯកឧត្តម សួន បវរ អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ។

ឯកឧត្តម សួន បវរ បានមានប្រសាសន៍លើកឡើងថា ប្រជាជន ខេត្តបន្ទាយមានជ័យពិតជាមានសេចក្តីរីករាយ ដែលទទួលបាននូវមជ្ឈមណ្ឌលការងារ ដើម្បីឱ្យប្រជាពលរដ្ឋមកទំនាក់ទំនងទទួលបានព័ត៌មាន ដើម្បីស្វែងរកការងារធ្វើក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ទៅតាមជំនាញ និងសមត្ថភាពរបស់ខ្លួន ។ ឯកឧត្តមសង្ឃឹមថា ក្រោយពីបង្កើតមជ្ឈមណ្ឌលនេះហើយ ធ្វើឲ្យប្រជាពលរដ្ឋ ក៏ដូចជាយុវជនមានភាពកាន់តែងាយស្រួល និងបានមានឱកាសចូលមកទទួលយកសេវានេះ។

ឯកឧត្តម ពេជ សោភ័ណ បានមានប្រសាសន៍ថា ក្រសួងការងារមកដល់បច្ចុប្បន្ននេះ បានបង្កើតនូវមជ្ឈមណ្ឌលផ្តល់ព័ត៌មានស្វែងរកការងារធ្វើនៅទូទាំងប្រទេសចំនួន១០មកហើយ ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បាននិងកំពុងដាក់ចេញនូវគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស តាមរយៈការជម្រុញបណ្តុះបណ្តាលប្រជាពលរដ្ឋ ឱ្យចេះជំនាញ និងវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ ដើម្បីរកងារធ្វើទទួលបានប្រាក់ខែខ្ពស់ ។ មានន័យថា ឱ្យប្រជាជនយើងឈប់ប្រើកម្លាំងពលកម្ម ដោយប្រើកម្លាំងបាយសុទ្ធសាធបានប្រាក់ខែទាបនោះ ជំនួសដោយការធ្វើការងារមានជំនាញនោះវិញ។

សូមបញ្ជាក់ថា ខេត្តបន្ទាយមានជ័យ ក្រៅពីមានមជ្ឈមណ្ឌលផ្តល់ព័ត៌មានសម្រាប់ឱ្យប្រជាពលរដ្ឋស្វែងរកការងារធ្វើនោះហើយ ខេត្តបន្ទាយមានជ័យ ក៏មានមជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជនសម្រាប់ស្វែងរកការងារធ្វើនោះផងដែរ ។ មជ្ឈមណ្ឌល វិជ្ជាជីវៈបានបង្កើតឡើងមានរយៈពេល២ឆ្នាំមកហើយ ក្នុងនោះក៏បានបណ្តុះបណ្តាលនូវជំនាញ(IT)កុំព្យូទ័រ ,ជំនាញជួសជុលម៉ាស៊ីនត្រជាក់ ,ជំនាញសំណង់ និងជំនាញអគ្គិសនី ដើម្បីឱ្យយុវជនមានឱកាសស្វែងរកនិងមានការងារធ្វើ៕ សំ វិច្ឆិកា

## ជនគេចប្រវ័ណ្ឌ កម្លាំងកុមារដើរសុំទាន ពីរនាក់ត្រូវឃាត់ខ្លួន

https://www.dap-news.com/kh ថ្ងៃពុធ, ២២ វិច្ឆិកា ២០១៧ 11:05 ដោយ: ព្រឿង វិសាល ID:019

**ភ្នំពេញ៖** ជនសង្ស័យប្រុស-ស្រី២នាក់ត្រូវបានកម្លាំងអាវុធហត្ថ ក្រុងប៉ោយប៉ែត ឃាត់ខ្លួនពីបទជាប់ពាក់ព័ន្ធករណី គេងប្រវ័ណ្ឌកម្លាំង កុមារឱ្យដើរសុំទាន យកប្រាក់ឲ្យខ្លួន កាលពីម៉ោង៧ព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅចំណុចកាស៊ីណូផ្កាយប្រាំ ស្ថិតនៅក្រុងប៉ោយប៉ែត និង រំដោះកុមារ ប្រុស-ស្រី១១នាក់ ។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរយុត្តិធម៌ នៃបញ្ជាការដ្ឋាន កងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ ប្រាប់ឱ្យដឹងថា ជនសង្ស័យ២នាក់ កម្លាំងអាវុធហត្ថ ក្រុងប៉ោយប៉ែត ចាប់ឃាត់ខ្លួន មានឈ្មោះ ១-ឈៀង វណ្ណារ៉ា ភេទប្រុស អាយុ២១ឆ្នាំ គ្មានមុខរបរពិតប្រាកដ ២-តូច គង់ ភេទស្រី អាយុ៤៤ឆ្នាំ គ្មានមុខរបរពិតប្រាកដ ពួកគេទាំង២នាក់ រស់នៅក្រុងប៉ោយប៉ែត ។ ការឈានទៅបង្ក្រាបមុខសញ្ញានេះ ក្រោយកម្លាំងអាវុធហត្ថ បានទទួលព័ត៌មាន ពីប្រជាពលរដ្ឋថា មានឈ្មោះ ឈៀង វណ្ណារ៉ា និងឈ្មោះ តូច គង់ បានធ្វើសកម្មភាព គាបសង្កត់គំរាមកំហែង ឱ្យកុមារអនាថា គ្មានផ្ទះសំបែងត្រឹមត្រូវ ទាំង១៥នាក់ ដើរសុំទានរកប្រាក់ឲ្យខ្លួន ក្នុងម្នាក់ៗយ៉ាងហោចណាស់១ថ្ងៃ ឲ្យបាន៥ម៉ឺនរៀល"។ ក្រោយពីទទួលព័ត៌មាន ភ្លាមលោកមេបញ្ជាការ អាវុធហត្ថខេត្ត ក៏បានបញ្ជាឱ្យកម្លាំងក្រោមឱវាទ ចេញទៅធ្វើការចាប់ឃាត់ខ្លួន ពួកគេទាំង២នាក់ ដើម្បីយកមកសាកសួរ នៅបញ្ជាការដ្ឋាន កងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ។ លោកបានបន្តថា ជនសង្ស័យឈ្មោះ ឈៀង វណ្ណារ៉ា បានឆ្លើយសារភាពថាខ្លួនគេធ្វើសកម្មភាពដាក់កំណត់ ឲ្យក្មេងរកប្រាក់ ឲ្យខ្លួននោះមែនខ្លួនគេ មានកូនចៅ ដែលជាកុមារសរុប១៥នាក់ សម្រាប់ឱ្យដើរសុំទាន រកលុយយកមកឲ្យខ្លួន បានលុយនោះមកគេយកទៅទិញ គ្រឿងញៀនប្រើប្រាស់។ រូបគេធ្លាប់ជាប់នៅមណ្ឌល អប់រំកែប្រែគ្រឿងញៀន ភ្នំបាក់ម្តងរួចហើយ មានរយៈពេល៤ខែផងដែរ។

ជាមួយគ្នានោះដែរ លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាកាកងរាជអាវុធហត្ថ ខេត្តបានបញ្ជាក់ឱ្យដឹងដែរថា "កុមារប្រុស-ស្រីទាំង១១នាក់ បានប្រគល់ឱ្យមណ្ឌល កែប្រែគ្រឿងញៀនភ្នំបាក់ ដើម្បីយកទៅចិញ្ចឹមថែរក្សាបីបាច់ ជាបណ្តោះអាសន្ននោះ សិនព្រោះក្មេងទាំងនេះ គឺជាក្មេងហិតកាវ។ ចំណែកជនសង្ស័យ២នាក់កំពុង កសាងសំណុំរឿងចាប់បញ្ជូន ទៅកាន់តុលាការ ដើម្បីចាត់ការតាមផ្លូវច្បាប់៕

## ឃុំខ្លួនស្ត្រីមេខ្យល់ពីរនាក់ដោយសានាំនារីខ្មែរឲ្យយកប្តីនៅប្រទេសចិន

http://dpnnews.com/ Posted by ដំណឹងភ្នំពេញ on 22/11/2017

ក្រចេះ ៖ ស្ត្រី២រូបត្រូវបានតុលាការខេត្តក្រចេះ សម្រេចឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកាលពីថ្ងៃទី២០ វិច្ឆិកាឆ្នាំ២០១៧ ក្រោមបទចោទអំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន។ ការឃុំខ្លួនស្ត្រីមេខ្យល់ទាំងពីរនាក់នេះបានធ្វើឡើងក្រោយនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអានីតិជនខេត្តចុះទៅចាប់ខ្លួនពួកគេដល់លំនៅឋានរៀងៗខ្លួននៅក្នុងស្រុកឆ្លូងខេត្តក្រចេះបានរយៈពេល៣ថ្ងៃ ។ ស្ត្រីជាជនស្ស័យទាំងពីរនាក់នេះរងពាក្របណ្តឹងថាបានប្រព្រឹត្តសកម្មភាព គឺនាំនារីខ្មែររងគ្រោះ២ នាក់អោយយកប្តីខុសច្បាប់ជាជនជាតិចិន តែក៏ត្រូវបាននគរបាលទប់ស្កាត់ទាន់ពេលវេលានៅព្រលានយន្តហោះ។

លោកវរសេនីយ៍ត្រី ឌុច អ៊ុចនាយរងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតជន បានប្រាប់ឲ្យដឹងថា ស្ត្រីជាមេខ្យល់ទាំងពីរនាក់នេះ១.ឈ្មោះ ភឹម ខេម៉ា អាយុ ៤៥ឆ្នាំ និងទី២2ឈ្មោះ ដូ ស៊ីណាត អាយុ ៤៣ ឆ្នាំ ។ ស្ត្រីសង្ស័យទាំងពីរនាក់នេះរស់នៅឃុំផ្សេងគ្នា នៅក្នុងស្រុកឆ្លូង និតែត្រូវបាននគរបាលចាប់ខ្លួនបាននៅក្នុងថ្ងៃតែមួយ។

## ស្ថានទូតកម្ពុជា នៅម៉ាឡេស៊ី អន្តរាគមជួយពលករ-ពលការិនីខ្មែរ ១៣នាក់

https://www.dap-news.com/kh ថ្ងៃពុធ, ២២ វិច្ឆិកា ២០១៧ 10:19 ដោយ: ដើមអម្ពិល ID:039

**ភ្នំពេញ៖** ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍ របស់ពលករ-ពលការិនីខ្មែរចំនួន ១៣នាក់ ឲ្យបានវិលត្រឡប់មកកម្ពុជាវិញ ។

យោងតាមសេចក្ដីប្រកាស ព័ត៌មានរបស់ក្រសួងការបរទេសខ្មែរ នៅថ្ងៃទី២២ វិច្ឆិកានេះ បានឲ្យដឹងថា ពលករ ពលការិនី បានធ្វើដំណើរតាមរថយន្ត កាត់ប្រទេសថៃទៅ ធ្វើការនៅរោងចក្រប្លាស្ទិក នៅរដ្ឋ Selangor ប្រទេសម៉ាឡេស៊ី កាលពីឆ្នាំ២០១៦ តាមរយៈមេខ្យល់ ។ ដោយចង់ត្រឡប់មកកម្ពុជាវិញ ពួកគេបានស្នើសុំកិច្ចអន្តរាគមន៍ពីស្ថានទូត នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

ជាមួយគ្នានោះដែរ ស្ថានទូតបានចេញលិខិតធ្វើដំណើរ និងសម្របសម្រួលជាមួយ ការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ។ ហើយពលករ-ពលការិនីទាំង ១៣នាក់ បានមកដល់អាកាសយានដ្ឋាន អន្តរជាតិភ្នំពេញដោយសុវត្ថិភាពទាំងអស់គ្នា ៕

## ក្រសួងការងារថៃប្រកាសផ្ដល់លេខរៀងជូនបងប្អូនពលករកម្ពុជា ដែលមិនបានផ្ទៀងផ្ទាត់សញ្ញាតិ

http://www.pheaktraprak.com November 21, 2017

យោងតាមសេចក្ដីប្រកាសរបស់ក្រសួងការងារថៃលេខ 52192 កាលពីថ្ងៃទី20 ខែវិច្ឆិកា ឆ្នាំ2017 នេះ ក្រសួងការងារថៃបានប្រកាសជូនដំណឹងដល់និយោជកថៃ ដែលកំពុងគ្រប់គ្រងពលករកម្ពុជា មិនបានបញ្ជាក់អត្តសញ្ញាណ សូមប្រញាប់ប្រញាល់រួសរាន់ រៀបចំឯកសារដើម្បីទៅស្នើសុំលេខរៀងនៅមន្ទីរការងារថៃទូទាំងខេត្ត-ក្រុងក្នុងប្រទេសថៃដើម្បីយកទៅបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជានៅតាមមណ្ឌលបញ្ជាក់អត្តសញ្ញាណនីមួយៗក្នុងប្រទេសថៃ អាស្រ័យហេតុនេះសូមបងប្អូនពលករកម្ពុជាមេត្តាជ្រាបជាដំណឹង។

## ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧

## កម្លាំងអាវុធហត្ថខេត្តបន្ទាយមានជ័យបញ្ជូនជនសង្ស័យប្រុសស្រី២នាក់ទៅតុលាការខេត្ត បន្ទាប់ពីរកឃើញបង្ខំក្មេងប្រុស ស្រីដើរសុំទាន

http://nokorwatnews.com/ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧

ប៉ោយប៉ែត៖ កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ បញ្ជូនជនសង្ស័យ២នាក់ទៅតុលាការខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ បន្ទាប់ពីកម្លាំងអាវុធហត្ថក្រុងប៉ោយប៉ែតឃាត់ខ្លួនកាលពីវេលាម៉ោង៧ព្រឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅចំណុចភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យដោយរកឃើញថាជនសង្ស័យទាំងពីនាក់បង្ខំក្មេងប្រុស ស្រី១១នាក់ ឲ្យដើរសុំទាន នៅច្រកទ្វារអន្តជាតិប៉ោយប៉ែត។

លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ បានបញ្ជាក់ថា កុមាររងគ្រោះទាំង១១នាក់នោះ បាននិយាយប្រាប់សមត្ថកិច្ចឲ្យដឹងថា ជនសង្ស័យទាំង០២នាក់នេះ បានបង្ខំពួកខ្លួនឲ្យដើរសុំទានដោយបំបែកគ្នាខ្លះដើរសុំទាន នៅក្នុងផ្សាររុងក្លឿ ប្រទេសថៃ ខ្លះនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងខ្លះទៀតនៅក្នុងបរិវេណកាស៊ីណូផងដែរ ហើយជនសង្ស័យបានកំណត់ក្នុង១ថ្ងៃម្នាក់សុំទានឲ្យបានប្រាក់៥ម៉ឺនរៀលទើបឲ្យបាយហូប បើមិនបានតាមកំណត់ពួកគេបង្អត់បាយដល់កុមាររងគ្រោះទាំងនោះ។

លោកបញ្ជាក់ទៀតថា ពេលកុមាររងគ្រោះសុំទានបាន ជនសង្ស័យបានទិញការ៉េឲ្យពួកគេហិតជាប្រចាំហើយដើរដេកតាមសំយ៉ាបផ្ទះរបស់អ្នកស្រុកទៀតផង ។ ក្រោយពីអាវុធហត្ថជំនាញសាកសួរចម្លើយរួចមក ជនសង្ស័យបានឆ្លើយសារភាពថា ពួកគេបានឲ្យកុមាររងគ្រោះទាំងនេះដើរសុំទានជាច្រើនខែមកហើយ។

បច្ចុប្បន្ន កុមាររងគ្រោះទាំង១១នាក់ ត្រូវបានប្រគល់ទៅឲ្យមន្ទីរសង្គមកិច្ចខេត្ត ចំណែកជនសង្ស័យទាំងពីរនាក់ ត្រូវបានអាវុធហត្ថជំនាញកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យកាលពីព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ដើម្បីចាត់ការតាមផ្លូវច្បាប់ ៕ វណ្ណា

## បង្ក្រាបហាងម៉ាស្សាកោសជប់បង្កប់សេវាផ្លូវភេទរំដោះនារីរងគ្រោះ៣នាក់ជាអនីតិជន

http://www.rasmei-kampuchea-news.html November 23, 2017

(ភ្នំពេញ)៖កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្សបានជួយអន្តរាគមន៍ក្នុងការបង្ក្រាបហាងម៉ាស្សាកោសជប់១៦៨ ដែលបង្កប់សេវាផ្លូវភេទដោយរំដោះនារីរងគ្រោះចំនួន៣នាក់ជាអនីតិជន។ការបង្ក្រាបទីតាំងម៉ាស្សាខាងលើនេះបានធ្វើឡើងនៅទីតាំងហាងម៉ាស្សាកោសជប់១៦៨ តាមបណ្តោយផ្លូវ១៨៦២ ស្ថិតនៅភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ខណ្ឌសែនសុខកាលពីវេលាម៉ោង៣រសៀលថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ។ ប្រតិបត្តិការនេះដោយមានការសម្របសម្រួលពី លោក គុជ គឹមឡុង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ និង លោក ឧត្តសេនីយ៍ត្រីចាន់កិតិខុមស្នងការរងនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ស្រ្តីសង្ស័យជាម្ចាស់ទីតាំងខាងលើនេះមានឈ្មោះហុងលាភអាយុ៤៥ឆ្នាំ ភេទស្រីស្នាក់នៅផ្ទះទីតាំងហាងម៉ាស្សាកោសជប់១៦៨ តាមបណ្តោយផ្លូវ១៨៦២ ស្ថិតនៅភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ ។

មន្ត្រីនគរបាល បានឲ្យដឹងថា មុនពេលឈានដល់ការចុះបង្ក្រាបទីតាំងហាងម៉ាស្សានេះ គឺកម្លាំងនគរបាលជំនាញ បានធ្វើការស្រាវជ្រាវដឹងច្បាស់ថា ទីតាំងខាងលើនេះ ដោយដាក់ឃីហោ កោសជប់ ប៉ុន្តែលួចបង្កប់បំរើសេវាផ្លូវភេទ ។ ប្រភពព័ត៌មានពីជនរងគ្រោះ ក៏បានឲ្យដឹងថា ជារៀងរាល់ថ្ងៃទីតាំងហាងបានបើករកស៊ីចាប់ពីម៉ោង០៨ព្រឹកដល់ម៉ោង០២ទាបភ្លឺ ដោយពេលខ្លះមានភ្ញៀវចូលមកម៉ាស្សាតម្លៃ១ម៉ោង១០.០០០រៀល។ភ្ញៀវខ្លះក៏មករួមភេទ ដោយរួមភេទម្តងតម្លៃ២០ដុល្លារទៅ៣០ ដុល្លារ។

បច្ចុប្បន្នស្ត្រីដែលជាម្ចាស់ទីតាំងហាងម៉ាស្សាត្រូវបានកម្លាំងនគរបាលបញ្ជូនទៅការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ដើម្បីឃុំខ្លួនបណ្តោះអាសន្ន ចាត់ការតាមច្បាប់ ។ ចំណែកនារីរងគ្រោះទាំង៣នាក់ត្រូវបានសមត្ថកិច្ច បញ្ជូនទៅមន្ទីរ សង្គមកិច្ច ដើម្បីធ្វើការអប់រំបន្ត ៕S/ដោយៈម៉េងសៃ

## ម.ស.ម.ក នឹងរៀបចំសន្និសីទសារព័ត៌មាន ស្តីពី អាពាហ៍ពិពាហ៍ ស្នំកូននិងការទទួលស្គាល់យេនឌ័រ នៅកម្ពុជា

https://www.dap-news.com/kh ថ្ងៃពុធ, ២២ វិច្ឆិកា ២០១៧ 17:31 ដោយ: ធី លីថូ ID:019

**ភ្នំពេញ៖** មជ្ឈមណ្ឌលសិទ្ធមនុស្សកម្ពុជា (ម.ស.ម.ក ) នឹងរៀបចំសន្និសីទសារព័ត៌មាន ដើម្បីចេញផ្សាយរបាយការណ៍ថ្មី ដែលមានចំណងជើងថា “គ្រួសារវេន្ទធនូកម្ពុជា ៖សិទ្ធអាពាហ៍ពិពាហ៍ ស្នំកូន និងការទទួលស្គាល់យេនឌ័រ នៅប្រទេសកម្ពុជា នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នាផ្ទះមេត្តា ភ្នំពេញ វេលាម៉ោង ៨និង៣០នាទីព្រឹក។

សន្និសីទមានគោលបំណងបង្ហាញ ភស្តុជាក់ស្តែងទាក់ទង និងស្ថានភាពពិតរបស់ស្ត្រី បុរសស្រលាញ់បុរសដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និងអ្នកដែល មិនទាន់បានកំណត់អត្តសញ្ញាណ (អ្នក

ស្រលាញ់ភេទដូចគ្នា) ក្នុងកម្ពុជាដែលបាន ជាប់ពាក់ព័ន្ធនិងសិទ្ធអាពាហ៍ពិពាហ៍ ស្ទុំកូន និងការទទួលស្គាល់ យេន ឌ័រ ហើយនិងការផ្តល់ អានុសាសន៍យ៉ាងច្បាស់ សម្រាប់ការដោះស្រាយបញ្ហា ដែលបាន រកឃើញ៕

## រដ្ឋាភិបាល រៀបចំគោលការណ៍សោធននិវត្តសម្រាប់ពលករចំណាកស្រុក

https://thmeythmey.com/ ថ្ងៃទី22, Nov 2017 , 8:39 pm ដោយ: ថ្មីៗ

ភ្នំពេញ៖ រដ្ឋាភិបាល កំពុងរៀបចំគោលការណ៍ប្រាក់សោធននិវត្ត សម្រាប់ពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ដើម្បីឲ្យពួកគេទទួលបានអត្ថប្រយោជន៍ ក្រោយពីអស់លទ្ធភាពបំពេញការងារ នាពេលអនាគត។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា គោលការណ៍សោធនិវត្ត ត្រូវបានរដ្ឋាភិបាល កំពុងសហការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដើម្បីរៀបចំលើគោលការណ៍រួមនេះ។ បើតាមសម្តេច ហ៊ុន សែន ក្រៅពីគោលការណ៍ប្រាក់សោធននិវត្តនេះ រដ្ឋាភិបាលក៏កំពុងសហការរៀបចំដោះស្រាយបញ្ហាសម្រាប់ពលករចំណាកស្រុកចំនួន៤ចំណុចទៀតផងដែរ។

## សម្តេចតេជោ ហ៊ុន សែន៖ រាជរដ្ឋាភិបាល កំពុងធ្វើការដើម្បីឱ្យពលករខ្មែរនៅប្រទេសថៃ ទទួលបានអត្ថប្រយោជន៍ ដូចកម្មករក្នុងស្រុកពេលត្រឡប់មកវិញ

http://freshnewsasia.com/ 2017-11-22

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ បានប្រកាសថា រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការងារជាច្រើនដើម្បីឱ្យពលករខ្មែរនៅប្រទេសថៃទទួលបានអត្ថប្រយោជន៍ផ្សេងៗ ដូចកម្មករក្នុងស្រុកដែរ ក្រោយពេលដែលពួកគេត្រឡប់មកកម្ពុជាវិញ។

ការប្រកាសរបស់សម្តេចតេជោ ហ៊ុន សែន បានធ្វើឡើង នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករ និយោជិតសរុប ១៣,៥៦៥នាក់ មកពីរោងចក្រចំនួន ២៥ស្ថិតក្នុងតំបន់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលកំពុងធ្វើការងារ៥ ដើម្បីការងារ និងលើកកម្ពស់ពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ជាពិសេសពលករធ្វើការនៅប្រទេសថៃ ដោយក្នុងនោះរួមមានការផ្តល់ អត្ថប្រយោជន៍ពេលទៅធ្វើការនៅក្រៅប្រទេស និងត្រឡប់មកវិញ។ នៅក្រៅប្រទេស រាជរដ្ឋាភិបាល បានបង្កើតមជ្ឈមណ្ឌលផ្តល់លិខិតធ្វើដំណើរ និងលិខិតឆ្លងដែន រួមទាំងសម្របសម្រួលធ្វើយ៉ាងណាឱ្យពលករដែលមិនទាន់ស្របច្បាប់ឱ្យស្របច្បាប់ ហើយពលករដែលស្របច្បាប់ហើយកាន់តែងាយស្រួលថែមទៀត។ សម្តេចតេជោ បានបញ្ជាក់ថា ពេលត្រឡប់មកវិញ បើពលករទាំងនោះក៏អាចធ្វើការនៅក្នុងប្រទេស ដែលមានរោងចក្រសហគ្រាស នៅកម្ពុជា ទទួលស្គាល់ថា ពួកគាត់ គឺជាអ្នកជំនាញមកពីក្រៅប្រទេសផងដែរ។

សូមបញ្ជាក់ថា រហូតដល់ពេលនេះ ពលករ-ពលការិនី និងកម្មសិក្សាការីខ្មែរ ដែលកំពុងបម្រើការនៅក្រៅប្រទេសមានចំនួន១លាន៥ម៉ឺននាក់ ក្នុងនោះពលករខ្មែរនៅប្រទេសថៃមានជាង១លាននាក់ ក្រៅនេះមាននៅប្រទេសកូរ៉េខាងត្បូង ម៉ាឡេស៊ី ជប៉ុន សិង្ហបុរី ហើយនាពេលខាងមុខ រាជរដ្ឋាភិបាលកម្ពុជា នឹងបញ្ជូនពលកររបស់ខ្លួនបន្ថែមទៅតំបន់រដ្ឋបាលពិសេសហុងកុង និងតំបន់មជ្ឈិមបូព៌ាជាដើម៕

## ILO នឹងត្រួតពិនិត្យដំណើរការអនុវត្តកិច្ចព្រមព្រៀងពលករចំណាកស្រុកអាស៊ានឆ្នាំក្រោយ

https://thmeythmey.com/ 22, Nov 2017 , 9:59 pm ដោយ: ថ្មីៗ

អង្គការពលកម្មអន្តរជាតិ (ILO) បានបញ្ជាក់ថា នៅឆ្នាំក្រោយនេះខ្លួននឹងចាប់ផ្តើមពិនិត្យការអនុវត្ត កិច្ចព្រមព្រៀងរួមរបស់អាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិពលករចំណាកស្រុក ដែលទើបចុះហត្ថលេខាកាលពីសប្តាហ៍មុន កិច្ចព្រមព្រៀងថ្មីនេះមានគោលដៅជួយពង្រឹងការការពារសិទ្ធិពលករនៅក្នុងតំបន់នៅពេលខាងមុខ។ កិច្ចព្រមព្រៀងរួមរបស់អាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិពលករចំណាកស្រុក (The ASEAN Consensus on the Protection and Promotion of the Rights of Migrant Workers) ត្រូវបានចុះហត្ថលេខាដោយប្រមុខរដ្ឋប្រមុខរដ្ឋាភិបាលអាស៊ានកាលពីថ្ងៃ១៤ វិច្ឆិកាកន្លងទៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១ នៅហ្វីលីពីន។ វាជាសមិទ្ធផលសំខាន់ក្នុងខួបលើកទី ៥០ ឆ្នាំ នៃការបង្កើតអាស៊ាន។ ដោយសារកិច្ចព្រមព្រៀងការពារពលករអាស៊ាននេះគ្មានអនុភាពគតិយុត្តិ រដ្ឋហត្ថលេខីមានទំនួលខុសត្រូវក្នុងការបង្កើតផែនការសកម្មភាព និងអនុវត្តតាមកិច្ចព្រមព្រៀងឲ្យស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួនដែរ។ ពាក់ព័ន្ធបញ្ហានេះ អង្គការពលកម្មអន្តរជាតិ អះអាងថាខ្លួននឹងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងនៅក្នុងរដ្ឋអាស៊ានទាំងដប់ផងដែរនៅឆ្នាំ ២០១៨។

យោងតាមសារព័ត៌មាន Manila Bulletin លោក Nilim Baruah អ្នកជំនាញជាន់ខ្ពស់ទទួលបន្ទុកផ្នែកពលករនៃអង្គការពលកម្មអន្តរជាតិបានលើកឡើងថា កិច្ចព្រមព្រៀងនឹងក្លាយជាបញ្ហាសំខាន់មួយដែលនឹងត្រូវពិភាក្សានៅក្នុងវេទិកាអាស៊ានស្តីពីពលករចំណាកស្រុកដែលត្រូវរៀបចំឡើងនៅត្រីមាសទីបួនឆ្នាំក្រោយ។ មន្ត្រីរូបនេះបានអះអាងថា អង្គការពលកម្មអន្តរជាតិនឹងពិនិត្យមើលថាតើកិច្ចព្រមព្រៀងរួមថ្មីនេះវាអនុលោមតាមបទបញ្ញត្តិដែលមានកំណត់ក្នុងសេចក្តីថ្លែងការណ៍ស្តីពីការការពារ និងលើកស្ទួយសិទ្ធិពលករចំណាកស្រុកដែលបង្កើតឡើងកាលពីឆ្នាំ ២០០៧ នៅក្រុងសេប៊ូ ប្រទេសហ្វីលីពីន។ ហើយលោករំពឹងថា បណ្តារដ្ឋអាស៊ាននឹងចាប់ផ្តើមអនុម័តផែនការសកម្មភាពដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឲ្យមានប្រសិទ្ធភាពផងដែរ។

«កិច្ចព្រមព្រៀងនេះមិនមានអនុភាពចាប់បង្ខំឡើយ ដូច្នេះហើយវាពឹងផ្អែកលើផែនការសកម្មភាពរបស់អាស៊ានដែលត្រូវអនុម័តឡើងនៅពេលខាងមុខ។ ខ្ញុំសង្ឃឹមថា កិច្ចព្រមព្រៀងនេះក៏នឹងបង្កើតស្តង់ដារួមក្នុងការការពារពលករចំណាកស្រុកក្នុងតំបន់អាស៊ានដែរ»។ លោកNilim Baruah បានសង្កត់ធ្ងន់ដូច្នេះ៕

## អំឡុងខែតុលាឆ្នាំ២០១៧អ្នកដំណើរដែលចេញចូលកម្ពុជា-ថៃតាមច្រកទ្វារអន្តជាតិនិងច្រកទ្វារតំបន់មានចំនួន៧១៧.៣៩២នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ម៉ោង ១៣:៤២ ប៊ុន ធឿន

បន្ទាយមានជ័យ ៖ អំឡុងខែតុលា ឆ្នាំ២០១៧ អ្នកដំណើរដែលចេញចូលកម្ពុជា-ថៃតាមច្រកទ្វារអន្តជាតិប៉ោយប៉ែត និងច្រកទ្វារតំបន់ម៉ាឡៃ និងច្រកតំបន់បឹងត្រកួនមានសរុបចំនួន៧១៧.៣៩២នាក់ ។ ដោយយោងតាមតួលេខប្រចាំខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតមានអ្នកដំណើរចេញចូលកម្ពុជា-ថៃមានចំនួន៦៩២.៦១៦នាក់ ស្រី៣៤៨.៣២៦នាក់ និងប្រុស៣៤៤.២៩០នាក់ ក្នុងនោះមានសញ្ជាតិខ្មែរចំនួន ៦០២.០២៨នាក់ ស្រី៣០៤.៣៧៣នាក់ មានសញ្ជាតិបរទេសចំនួន៩០.៥៨៨នាក់ ស្រី៤៣.៩៥៨នាក់ ភ្ញៀវបរទេសចរបរទេសចំនួន៧៧.៣៣៨នាក់ ។

មានពលករចេញចូលទៅធ្វើការនៅបរទេសមានចំនួន១២.២៩១នាក់តាមរយៈ៣៦ក្រុមហ៊ុន និងពលរដ្ឋថៃចូលមកលេងកាស៊ីណូមានចំនួន៣៦.៥៧២នាក់ ស្រី២១.០០២នាក់ និងថៃចេញមានចំនួន៣៦.៣៣២នាក់

ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់អាជ្ញាធរថៃចាប់បញ្ជូនមកមាន៨៦លើកស្មើ ៣.៥៣៨នាក់ ស្រី១.១៥៧នាក់ មានកុមារ៣៨៧នាក់ ។

ដោយឡែកនៅប្រកទ្វារតំបន់ព្រំដែនម៉ាឡៃស្រុកម៉ាឡៃ អ្នកដំណើរឆ្លងកាត់ចេញចូលកម្ពុជា-ថៃមានចំនួន ២២.០៥៥នាក់ ស្រី១៣.០៧៧នាក់ កុមារ៨៤៩នាក់ ក្នុងនោះមានសញ្ជាតិខ្មែរចំនួន២១.៤៤៩នាក់ ស្រី ១២.៨៤៧នាក់ សញ្ជាតិបរទេសមានថៃចំនួន៦០៦នាក់ ស្រី២៣០នាក់ និងមធ្យោបាយចេញចូលចំនួន៣២៣គ្រឿង និងមនុស្ស១.៤២៥នាក់ ស្រី៧៧៣នាក់ ។ ប្រកទ្វារតំបន់ព្រំដែនបឹងស្រុកថ្មពួកអ្នកដំណើរចេញចូលកម្ពុជា-ថៃមានចំនួន២.៧២១នាក់ កុមារ១៦៥នាក់ ប្រជាពលរដ្ឋថៃចូលមកកម្ពុជាចំនួន១.១០១នាក់ ស្រី២០១នាក់កុមារ ១១នាក់ ៕

## ថៃត្រៀមប្រកាសបើកច្រកអន្តរជាតិគីឡូ១៣ ក្នុងពេលឆាប់ៗនេះ

http://cambodiapolice.com/ ម៉ោង 2:31 pm 23 វិច្ឆិកា 2017 4

បាត់ដំបង ៖ ច្រកតំបន់គីឡូ១៣ ឬច្រកតំបន់ភ្នំដី ដែលស្ថិតក្នុងស្រុកសំពៅលូនខេត្តបាត់ដំបង ទល់នឹងស្រុកខ្លុងហាត ខេត្តស្រះកែវ និងត្រូវប្រកាសជាផ្លូវការ ដើម្បីបង្កើតជាច្រកអន្តរជាតិវិញ នាពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីភាគីថៃបានធ្វើការ ផ្អាកការប្រកាសម្តងរួចមកហើយ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ កន្លងទៅថ្មីៗនេះ ។

កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក ប្រាក់យុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃបានបើកកិច្ចប្រជុំគណរដ្ឋមន្ត្រី ដោយបានបញ្ចូលបញ្ហានៃការបង្កើតច្រកអន្តរជាតិខៅឌិន ( ច្រកគីឡូ១៣ ) ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនោះផងដែរ ព្រមទាំងបានលើកឡើងថា ច្រកតំបន់មួយនេះ គឺមានកំណើនសេដ្ឋកិច្ចយ៉ាងល្អប្រសើរផងដែរ ក្នុងការប្រែក្លាយពីច្រកតំបន់អោយទៅជាច្រកអន្តរជាតិទី២ សម្រាប់ខេត្តស្រះកែវ ប្រទេសថៃ ។

នៅក្នុងកិច្ចប្រជុំនោះផងដែរ គេក៏បានយល់ស្របតាមការអនុម័តរបស់រដ្ឋសភា ដែលបានសម្រេចលើបញ្ហាមួយចំនួនដូចជា ១. សម្រេចឯកភាព បើកច្រកភ្នំដី គីឡូ១៣ ឲ្យទៅជាច្រកអន្តរជាតិ ដោយប្រគល់នាទីទៅក្រសួងមហាផ្ទៃ ក្នុងការជូនដំណឹងទៅកាន់ អង្គភាពពាក់ព័ន្ធទាំងអស់ ២. ក្នុងករណីចាំបាច់ត្រូវកសាងអ្វីមួយ នៅត្រង់ចំណុចច្រកទ្វារព្រំដែន ត្រូវទំនាក់ទំនងទៅក្រសួងការពារជាតិ និងក្រសួងការបរទេស ដើម្បីពិនិត្យរួមគ្នាមុននឹងដំណើរការ ។

ក្រោយកិច្ចប្រជុំ គេសង្កេតឃើញថា គណៈរដ្ឋមន្ត្រីបានដាក់ផែនការទៅក្រសួងការងារនិងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវពិនិត្យរួមគ្នាលើកិច្ចការមួយចំនួនដូចជា ការរំលោភលើកិច្ចការព្រំដែន ការដឹកទំនិញខុសច្បាប់ឆ្លងដែន និងការលបឆ្លងដែនរបស់ពលករចំណាកស្រុក ។

តាមការសិក្សាសម្រាប់ច្រកតំបន់គីឡូ១៣ ( ច្រកខៅឌិន ឬ ច្រកភ្នំដី ) នាឆ្នាំ២០១៦កន្លងទៅ គេសង្កេតឃើញអត្រាឆ្លងដែនទៅវិញ ទៅមក រវាងប្រជាពលរដ្ឋកម្ពុជា ថៃគឺមានចំនួនដូចតទៅ ៖ ពលរដ្ឋថៃ ឆ្លងមកកម្ពុជាមានចំនួន ១ ១៥៦ នាក់ រីឯពលរដ្ឋកម្ពុជា ដែលឆ្លងទៅប្រទេសថៃមានចំនួន ១ ០៥៦ ៧៧៥ នាក់ ។

ចំពោះតម្លៃទំនិញដែលនាំឆ្លងកាត់លើខ្សែបន្ទាត់ព្រំដែនទៅវិញ ទៅមក នាឆ្នាំកន្លងទៅគឺ ទំនិញដែលនាំពីកម្ពុជា ទៅថៃ មានចំនួន ៣ ៥៨៧ លានបាត ដោយឡែកទំនិញដែលនាំចេញពីថៃ មកកម្ពុជា តាមច្រកនេះមាន

ចំនួន ២ ៩៨៤ លានបាត ហើយការដែលភាគីថៃត្រៀមបង្កើតច្រកនេះអោយទៅជាច្រកអន្តរជាតិ ដោយសារតែទំហំស្ពានបេតុងដែលឆ្លងកាត់អូរព្រំដែន គឺទទឹងមានប្រវែង ៩ ម៉ែត្រ និងបណ្តោយប្រវែង ៥១ ម៉ែត្រ ។

បច្ចុប្បន្ន នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ មានច្រកអន្តរជាតិចំនួន ៦ ហើយគឺនៅខេត្តស៊ីសាកេត ខេត្តសុរិន្ទ ខេត្តស្រះកែវ ខេត្តត្រាត និងខេត្តច័ន្ទបុរី មានព្រកន្លែងព្រមទាំងមានច្រកតំបន់សរុបចំនួន១០កន្លែងផងដែរ ៕

## អគ្គលេខាធិការ UN អំពាវនាវឲ្យមានការស៊ើបអង្កេតលើរបាយការណ៍ស្តីពីការជួញដូរមនុស្សធ្វើជាទាសករនៅក្នុងប្រទេសលីប៊ី

http://bayontv.com.kh/ 22/11/2017

លីប៊ី៖ អគ្គលេខាធិការអង្គការសហប្រជាជាតិលោក Antonio Guterres កាលពីថ្ងៃចន្ទម្សិលមិញបាននិយាយថា លោកតក់ស្លុតចំពោះរបាយការណ៍មួយ និយាយពីជនអន្តោប្រវេសន៍អាហ្វ្រិកស្បែកខ្មៅ កំពុងត្រូវគេលក់ដូរធ្វើជាទាសករក្នុងប្រទេសលីប៊ី។ការធ្វើសេចក្តីអត្ថាធិប្បាយរបស់លោកកើតមាន ក្រោយការផ្សព្វផ្សាយរូបភាពវីដេអូដោយស្ថានីយទូរទស្សន៍ CNN អំពីអ្វីដែលគេនិយាយថា ជាការលក់ដេញថ្លៃលើក្រុមបុរសៗ ឲ្យទៅអតិថិជនលីប៊ីធ្វើជាកម្មករកសិកម្ម និងលក់ដូរក្នុងម្នាក់ៗមានតម្លៃ $400 ដែលធ្វើឲ្យគេនឹកឃើញដល់ជំនួញទាសករអន្តរសាហារ៉ាកាលពីច្រើនសតវត្សកន្លងទៅ។ ថ្លែងនៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិលោក ហ្គូទើរ៉េស លើកឡើងថា លោកបានស្នើឲ្យមានការស៊ើបអង្កេតមួយ ដោយក្រុមអាជ្ញាធរដែលមានសមត្ថភាព ព្រមទាំងគណៈកម្មាធិការនានារបស់អង្គការសហប្រជាជាតិផងដែរ ដោយបន្ថែមថា ទាសករភាពគ្មាននៅកន្លែងណាមួយក្នុងពិភពលោកយើងឡើយ ហើយការជួញដូរទាំងនេះគឺស្ថិតនៅក្នុងចំណោម សកម្មភាពរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុត និងអាចឈានទៅរកអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ប្រទេសលីប៊ីបានក្លាយជាទីតាំងនៃបណ្តាប្រទេសនៅអឺរ៉ុប ដែលខំរឹតត្បិតលើចំនួនជនអន្តោប្រវេសន៍មកពីតំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិកឆ្លងកាត់សមុទ្រមេឌីទែរ៉ានេ។ ប្រទេសអ៊ីតាលីបានដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់សហភាពអឺរ៉ុប ដើម្បីបញ្ឈប់ការធ្វើដំណើរតាមសមុទ្រដោយការផ្តល់ថវិកា, សម្ភារៈ និងការបណ្តុះបណ្តាលដល់ឆ្មាំព្រំដែនលីប៊ី និងឆ្មាំសមុទ្រ និងជំរុញឲ្យមានកិច្ចព្រមព្រៀងជាមួយក្រុមការងារមូលដ្ឋាននានា ក្នុងការគ្រប់គ្រងការធ្វើដំណើរតាមផ្លូវគោកក្នុងប្រទេស ដែលនៅតែគ្មានច្បាប់ទម្លាប់ត្រឹមត្រូវ បន្ទាប់ពីការស្លាប់របស់មេដឹកនាំ មូអាម៉ាហ្គា ដាហ្វីក្នុងឆ្នាំ២០១១។ ជនអន្តោប្រវេសន៍ត្រូវបានគេចាប់ដាក់ក្នុងមណ្ឌលឃុំឃាំងនានា ក្នុងប្រទេសអាហ្វ្រិកខាងជើងមួយនេះ ដែលក្រុមឃ្លាំមើលសិទ្ធិមនុស្សបានធ្វើការប្រៀបធៀបទៅនឹងជំរំប្រមូលផ្តុំ៕ អត្ថបទ៖ សុខមាន

## អាមេរិកដាក់ទោស ឧក្រិដ្ឋជួញដូរមនុស្សម្នាក់ ឲ្យជាប់គុកយូរបំផុត មិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ៤៧២ឆ្នាំ

https://www.dap-news.com/kh ព្រហស្បតិ៍, ២៣ វិច្ឆិកា ២០១៧ 11:59 ប្រែសម្រួល: ស៊ុន លី ID:049

Los Angeles: ទីភ្នាក់ងារចិនស៊ិនហួចេញផ្សាយ នៅថ្ងៃព្រហស្បតិ៍ទី២៣ ខែវិច្ឆិកានេះ បានឲ្យដឹងថាជនជាប់ចោទម្នាក់ អំពីបទជួញដូរមនុស្សនៅ សហរដ្ឋអាមេរិកត្រូវបានតុលាការ នៃរដ្ឋ Colorado បានសម្រេចកាត់

ទោសឲ្យជាប់គុករហូតទៅ ដល់៤៧២ឆ្នាំកាលពី ថ្ងៃអង្គារម្សិលមិញ គឺជាការដាក់ទោសដែលមានរយៈពេល វែងបំផុតមិនធ្លាប់មាន នៅក្នុងប្រវត្តិសាស្ត្រ របស់ប្រទេសនេះឡើយ។

បុរសដែលមានឈ្មោះថា Brock Franklin អាយុ៣១ឆ្នាំត្រូវបានគេជឿជាក់ថា គឺជាមេដឹកនាំក្រុមជួញដូរគ្រឿងញៀន ដ៏ល្បីនៅអាមេរិកដោយក្នុងនោះខ្លួន ត្រូវបានរងប្រកាន់ទោសទណ្ឌសរុប ទៅដល់៣០ករណី គិតត្រឹមខែមិនាកន្លងមកដោយរួមមាន ទាំងការចាប់ជំរិតផងនិងការប្រព្រឹត្ត អំពើហិង្សាផ្លូវភេទផង។

មេធាវីជនជាប់ចោទបានធ្វើការស្នើសុំតុលាការ ក្នុងការជាប់ទោសតែត្រឹមរយៈពេល៩៦ឆ្នាំឲ្យ បុរស Franklin ប៉ុន្តែតុលាការបានបន្ថែមរយៈពេលដល់ ទៅ៣៧៦ឆ្នាំពីលើការស្នើសុំនេះដែល ជាសំណើរផ្ទាល់ពីក្រុមជនរងគ្រោះ ដែលជាក្មេងស្រី៣នាក់ និងស្ត្រី៥នាក់ដែលមានវត្តមា នៅក្នុងតុលាការផងនោះ៕

## ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

## តុលាការបន្ទាយមានជ័យឃុំខ្លួនមនុស្ស២នាក់ ពាក់ព័ន្ធរឿង ធ្វើអាជីកម្មលើកុមារ ជាង១០នាក់

http://ann.com.kh/ ថ្ងៃព្រហស្បតិ៍, 23 ខែវិច្ឆិកា 2017 3:20 ល្ងាច

**បន្ទាយមានជ័យ៖** យោងតាមការឱ្យដឹងរបស់លោក សុខ កែវបណ្ឌិត អ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ តាមរយៈ Telegram នៅរសៀល ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ ថា លោក មុយ សុភក្រ ជាចៅក្រមស៊ើបសួរ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ម្សិលមិញ បានចេញដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន ជនត្រូវចោទប្រុសស្រី ២នាក់ ជាបណ្តោះអាសន្ន ពាក់ព័ន្ធករណីបង្ខំឱ្យកុមារដើរសុំទាន ជាថ្នូរនឹងការហិត។ លោក សុក កែវបណ្ឌិត បញ្ជាក់ថា លោកស្រី ឆេង ហាក់ង៉ិង តំណាងអយ្យការបានចោទប្រកាន់លើជនត្រូវចោទ ទី១.ឈ្មោះ ឈៀង វណ្ណារ៉ា ភេទប្រុស អាយុ ២១ឆ្នាំ ស្នាក់នៅភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងទី២. ឈ្មោះ ចូច គង់ ភេទស្រី អាយុ៤៤ឆ្នាំ ស្នាក់នៅភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ពីបទជ្រើសរើសមិនស្របច្បាប់ សម្រាប់ការកេងប្រវ័ញ្ចន៍ យោងតាមមាត្រា១២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

គួររំលឹកថា ជនត្រូវចោទទាំង២នាក់ខាងលើត្រូវបានសមត្ថកិច្ចឃាត់ខ្លួនកាលពីល្ងាច ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅត្រង់ចំណុចកាស៊ីណូផ្កាយ៥ ស្ថិតក្នុងភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ការឃាត់ខ្លួនបានធ្វើឡើងក្រោយពីសមត្ថកិច្ចជំនាញ បានរកឃើញថា ជនត្រូវចោទទាំង២នាក់ខាងលើ បានបង្ខំឲ្យកុមារា កុមារីរងគ្រោះចំនួន ១១នាក់ ដើរសុំទាន នៅក្នុងផ្សាររុងក្លឿ ក្នុងប្រទេសថៃ ច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងនៅក្នុងបរិវេណកាស៊ីណូ ដោយកំណត់ក្នុង១ថ្ងៃ ម្នាក់សុំទានឲ្យបានប្រាក់៥ម៉ឺនរៀល ទើបឲ្យបាយហូប និងការហិត បើមិនដូច្នោះទេ នឹងបង្អត់បាយដល់កុមាររងគ្រោះទាំងអស់នោះ៕

## បញ្ជូនខ្លួនស្រីម្ចាស់ហាងម៉ាស្សាបន្ទប់សេវាផ្លូវភេទ ទៅតុលាការ

http://ann.com.kh/ ថ្ងៃសុក្រ, 24 ខែវិច្ឆិកា 2017 10:01 ព្រឹក

**រាជធានីភ្នំពេញ៖** កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅព្រឹកថ្ងៃទី២៤ ខែវិច្ឆកា ឆ្នាំ២០១៧នេះ បានបញ្ជូនខ្លួនស្ត្រីសង្ស័យម្នាក់ ទៅតុលាការក្រុងភ្នំពេញ ពាក់ព័ន្ធករណីបើកហាងម៉ា

ស្បាបង្កប់សេវាផ្លូវភេទខុសច្បាប់។ យោងតាមសមត្ថកិច្ច ស្ត្រីសង្ស័យមានឈ្មោះ ហុង លាភ អាយុ៤៥ឆ្នាំ ស្នាក់នៅហាងម៉ាស្សាកោសជប់យីហោ ១៦៨ តាមបណ្តោយផ្លូវ១៨៦២ ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

គួររំលឹកថា សមត្ថកិច្ចបានបង្រ្កាប ទីតាំងហាងម៉ាស្សាកោសជប់ យីហោ ១៦៨ នៅបណ្តោយផ្លូវ១៨៦២ ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំង ធ្នង់ខណ្ឌសែនសុខ កាលពីរសៀលថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០១៧ ក្រោយពីស្រាវជ្រាវឃើញថា ហាងម៉ាស្សាមួយនេះ បានបង្កប់សេវាកម្មផ្លូវភេទ។ ក្នុងការចុះបង្រ្កាបនោះ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីសង្ស័យជាម្ចាស់ហាងឈ្មោះ ហុង លាភ និងស្ត្រីម៉ាស្សា មួយចំនួន យកទៅអប់រំ៕

## រដ្ឋមន្ត្រី អ៊ិត សំហេង ស្នើជប៉ុនទទួលកម្មសិក្សាការីខ្មែរបន្ថែម ខណៈជប៉ុនត្រូវការអ្នកថែទាំមនុស្សចាស់ ក្នុងមួយឆ្នាំ២០-៣០ម៉ឺននាក់

http://freshnewsasia.com/ 2017-11-23

**(ភ្នំពេញ)៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើភាគីជប៉ុនទទួលកម្មសិក្សាការីខ្មែរបន្ថែមទៀត ខណៈចំនួនប្រជាជនវ័យចំណាស់ក្នុងប្រទេសនេះ កំពុងមានកើនឡើងខ្ពស់ ហើយត្រូវការអ្នកថែទាំមនុស្សចាស់ក្នុងមួយឆ្នាំៗពី ២០-៣០ម៉ឺននាក់។ ការស្នើបែបនេះរបស់លោករដ្ឋមន្ត្រី អ៊ិត សំហេង ធ្វើឡើងក្នុងជំនួបពិភាក្សាការងារពាក់ព័ន្ធនឹងការបញ្ជូនកម្មសិក្សាការីទៅបម្រើការងារ លើវិស័យសេវាកម្មថែទាំមនុស្សចាស់ នៅប្រទេសជប៉ុន ជាមួយលោក CHIBA Shinya ប្រធានសហជីពជនជានមនុស្សអន្តរជាតិ នៅទីស្តីការក្រសួងការងារ នាព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧។

លោក CHIBA Shinya បានលើកឡើងថា គោលបំណងរបស់គណៈប្រតិភូជប៉ុនមកកម្ពុជាក្នុងពេលនេះ គឺដើម្បីពិភាក្សាពីការបញ្ជូនកម្មសិក្សាការីកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុន លើវិស័យសេវាកម្មថែទាំមនុស្សចាស់ ដោយកន្លងកម្ពុជាបញ្ជូនតែកម្មសិក្សាការី ដែលបម្រើការងារក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យសំណង់ប៉ុណ្ណោះ ដូច្នេះលោកសូមឲ្យមានការគាំទ្រ ពីលោករដ្ឋមន្ត្រី ដើម្បីជំរុញការងារនេះឲ្យទទួលបានជោគជ័យ។ លោក CHIBA បានបន្តថា បច្ចុប្បន្នប្រទេសជប៉ុនមានប្រជាជនវ័យចំណាស់ច្រើន ដូច្នេះកម្លាំងពលកម្មក៏មានការថយចុះ ទើបរដ្ឋាភិបាលជប៉ុនរៀបចំបង្កើតច្បាប់ថ្មី ដើម្បីទទួលកម្មសិក្សាការីផ្នែកថែទាំមនុស្សចាស់ទៅធ្វើការនៅជប៉ុន ហើយរាជរដ្ឋាភិបាលជប៉ុនបានយកចិត្តទុកដាក់ និងចាត់ទុកថាជារឿងសំខាន់ចំពោះបញ្ហានេះ ក្នុងនោះរាជរដ្ឋាភិបាលជប៉ុនត្រូវការកម្មសិក្សាការីពីបរទេសពី ២០-៣០ម៉ឺននាក់ ក្នុងមួយឆ្នាំ ដើម្បីបម្រើការងារលើវិស័យថែទាំមនុស្សចាស់នេះ។ លោកបន្ថែមទៀតថា សហជីពរបស់លោកមានក្រុមហ៊ុនជាដៃគូច្រើន ដូច្នេះសហជីពរបស់លោកត្រូវការកម្មសិក្សាការីទៅបម្រើការងារនៅជប៉ុនចំនួន ២ទៅ៣ម៉ឺននាក់។ ប្រការនេះហើយ ទើបលោកមកធ្វើការសិក្សានៅកម្ពុជា ដើម្បីស្វែងរកដៃគូសហការ និងសុំការគាំទ្រពីក្រសួងការងារ ដើម្បីជំរុញការងារនេះឲ្យបានជោគជ័យ។

បន្ទាប់ពីការលើកឡើងរបស់ភាគីជប៉ុន លោករដ្ឋមន្ត្រី អ៊ិត សំហេង បច្ចុប្បន្នជប៉ុនបានទទួលកម្មសិក្សាការីកម្ពុជាទៅបម្រើការងារ នៅប្រទេសខ្លួនមានជាង ៥ពាន់នាក់ ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសំណង់។ លោករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា កន្លងមកកម្ពុជា ជប៉ុនមានតែកិច្ចព្រមព្រៀងតែលើវិស័យកសិកម្ម ឧស្សាហកម្ម និងសំណង់ប៉ុណ្ណោះ ហើយលោកក៏ចង់ឲ្យមានកិច្ចសហការលើវិស័យសេវាកម្មថែទាំមនុស្សចាស់ ពីសំណាក់រាជរដ្ឋាភិបាលជប៉ុន ដើម្បីផ្តល់ភាពស្របច្បាប់ និងគិតគូរពីសុខទុក្ខរបស់កម្មសិក្សាការីកម្ពុជា ដូច្នេះហើយលោករដ្ឋមន្ត្រីបានជំរុញឲ្យភាគីជប៉ុន បង្កើនការទទួលកម្មសិក្សាការីពីកម្ពុជាបន្ថែម ពិសេសវិស័យថែទាំមនុស្សចាស់នេះតែម្តង។

លោក អ៊ិត សំហេង បានបន្តថា ដើម្បីឲ្យកិច្ចសហប្រតិបត្តិការដំណើរការទៅបាន ខាងសហជីពធនធានមនុស្សអន្តរជាតិត្រូវមានការណែនាំតម្រង់ទិស និងបណ្តុះបណ្តាលពីភាគីជប៉ុនមុន និងបញ្ជូនកម្មសិក្សាការីទៅបម្រើការងារ ហើយសហជីពត្រូវបង្កើតភ្នាក់ងារដើម្បីណែនាំ និងត្រូវចុះបញ្ជីនៅក្រសួងការងារជាមុនសិន៕

## ជប៉ុនគ្រោងទទួលយក ពលករ កម្ពុជាទៅបម្រើមនុស្សចាស់នៅជប៉ុន

http://www.rasmeinews.com/ November 24, 2017

(ភ្នំពេញ)៖ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរួមជាមួយនឹងប្រធានសហជីពធនធានមនុស្សអន្តរជាតិមកពីប្រទេសជប៉ុន បានបើកកិច្ចពិភាក្សារួមគ្នាមួយ ដើម្បីធ្វើការបញ្ជូនពលករកម្ពុជាទៅបម្រើលើវិស័យសេវាកម្មថែទាំមនុស្សចាស់នៅប្រទេសជប៉ុននាថ្ងៃខាងមុខ។

ថ្លែងបញ្ជាក់ក្រោយបញ្ចប់ជំនួបជាមួយលោក CHIBA Shinya ប្រធានសហជីពធនធានមនុស្សអន្តរជាតិមកពីប្រទេសជប៉ុន កាលពីថ្ងៃទី២៣ខែវិច្ឆិកាកន្លងមក លោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានលើកឡើងថាបច្ចុប្បន្នកម្ពុជា-ជប៉ុន កំពុងតែស្ថិតនៅក្នុងដំណាក់កាលទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ថ្នាក់ដឹកនាំប្រទេសទាំងពីរ បានផ្លាស់ប្តូរដំណើរទស្សនៈកិច្ចទៅវិញទៅមក ដែលនេះជាការរឹតចំណងមិត្តភាពរបស់ប្រទេសទាំងពីរឲ្យកាន់តែរឹងមាំ។ លើសពីនេះទៀតមានអ្នកវិនិយោគជប៉ុនបានចូលមកវិនិយោគនៅកម្ពុជាជាបន្តបន្ទាប់ ហើយក្នុងនោះកំណើនទេសចរណ៍ជប៉ុនមកកម្ពុជាក៏កាន់តែមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

លោករដ្ឋមន្ត្រីបញ្ជាក់បន្ថែមថា ចំពោះប្រទេសជប៉ុនដែលមានបំណងមកស្វែងរកពលករកម្ពុជាក្នុងការបម្រើលើសេវាថែទាំមនុស្សចាស់នេះ លោកស្វាគមន៍និងសង្ឃឹមថាកិច្ចពិភាក្សានេះនឹងសម្រេចនៅថ្ងៃខាងមុខ។ជាមួយគ្នានេះលោកក៏ចង់ឃើញកំណើន ប្រជាពលរដ្ឋកម្ពុជាទៅធ្វើការងារនៅជប៉ុន ច្រើនជាងបច្ចុប្បន្នផងដែរ។ ក្នុងចំណោមប្រទេសដែលបានបញ្ជូនកម្មសិក្សាការីទៅបម្រើការងារនៅជប៉ុនទាំង១៧ កម្ពុជាឈរលេខរៀងទី៦ ហើយលោកក៏ចង់ឃើញលេខរៀងតិចជាងនេះ។

ជាមួយគ្នានេះលោករដ្ឋមន្ត្រីបានបញ្ជាក់ទាក់ទិននឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីនាកន្លងមកដែរ កម្ពុជា ជប៉ុនមានតែកិច្ចព្រមព្រៀងតែលើវិស័យកសិកម្ម ឧស្សាហកម្ម និងសំណង់ប៉ុណ្ណោះ ហើយលោកក៏ចង់ឲ្យមានកិច្ចសហការលើវិស័យសេវាកម្មថែទាំមនុស្សចាស់ពីសំណាក់រាជរដ្ឋាភិបាលជប៉ុន ដើម្បីផ្តល់ភាពស្របច្បាប់និងគិតគូពីសុខទុក្ខរបស់កម្មសិក្សាការីកម្ពុជា។ លើសពីនោះទៀត ខាងសហជីពធនធានមនុស្សអន្តរជាតិ ត្រូវមានការណែនាំ តម្រង់ទិសនិងបណ្តុះបណ្តាលពីភាគីជប៉ុនមុននិងបញ្ជូនកម្មសិក្សាការីទៅបម្រើការងារ ហើយសហជីពត្រូវបង្កើតភ្នាក់ងារដើម្បីណែនាំ និងត្រូវចុះបញ្ជីនៅក្រសួងការងារជាមុនសិន៕ដោយ៖*វេប៉ូ/sn*

## ឈប់ព្រួយបារម្ភទៅ ក្រសួងការងារថៃ ប្រកាសផ្តល់លេខរៀងសារថ្មី និងបន្តពេលវេលាចំនួន3 ខែតទៅមុខទៀតករណីត្រួតសញ្ញាតិមិនទាន់ពេលកំណត់.!

http://www.pheaktraprak.com November 24, 2017

យោងតាមសេចក្តីថ្លែងការណ៍របស់អគ្គនាយកដ្ឋាននៃក្រសួងការងារថៃ លោក ចារីន ចាក់ក្រុះផា អគ្គនាយកនៃក្រសួងការងារថៃ បានមានប្រសាសន៍ក្រោយកិច្ចប្រជុំពិភាក្សាការងាររបស់ក្រសួងការងារថៃ កាលពីថ្ងៃទី 22 ខែវិច្ឆិកា ឆ្នាំ2017 ម្សិលមិញនេះថា ក្រសួងការងារថៃ និងរៀបចំបន្តរយៈពេលបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជា ចំនួន3ខែបន្ថែមទៀតក្នុងករណីពលករកម្ពុជា ដែលឈ្មោះថ្មីមានលិខិតបញ្ជាក់ចេញពីក្រសួងការងារថៃ

ហើយទៅបញ្ជាក់អត្តសញ្ញាណមិនទាន់ពេលកំណត់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2017ខាងមុខនេះ ។ ដោយក្រសួងការងារថៃបានរៀបចំពេលវេលាចំនួន 3ខែតទៅទៀតគឺចាប់ពីថ្ងៃ(01.01.2018- 31.03.2018) ដើម្បីឲ្យពលករកម្ពុជាទាំងអស់បានត្រួតសញ្ជាតិទាន់ពេលវេលា។

ក្នុងបញ្ហានេះដែរក្រសួងបានលើកឡើងអំពីបញ្ហានានាដែលកើតមានឡើងពេលកន្លងមក ដោយសារតែមានឧបសគ្គក្នុងកិច្ចការមួយចំនួនទើបធ្វើមានការរាំងស្ទះដល់ការបញ្ជាក់អត្តសញ្ញាណរបស់ពលករ ដូច្នេះក្រសួងការងារនិងរៀបចំផែនការនិងចុះជួយសម្រួលលេខរៀងដល់ពលករអោយគ្រប់គ្រាន់ទាន់ពេលវេលាដែលបានកំណត់។

## ពលករកម្ពុជាចំនួន 20នាក់ ធ្វើដំណើរចុះទៅប៉ាស្ព័រការងារ MOU នៅជាយដែន ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួន

http://www.pheaktraprak.com November 24, 2017

កាលពីថ្មីៗកន្លងទៅនេះ មានពលករខ្មែរចំនួន 20នាក់ បានធ្វើការនៅក្នុងខេត្តរ៉ាក់យ៉ង ក្នុងប្រទេសថៃ បានធ្វើដំណើរទៅទទួលប៉ាស្ព័រMOU នៅឯខាងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជាយើង តែត្រូវកម្លាំងសមត្ថកិច្ចថៃនៅប្រចាំតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ឃាត់ខ្លួនបន្ទាប់ពីពលករខ្មែរទាំងអស់នោះគ្មានឯកសារបញ្ជាក់ដល់កម្លាំងសមត្ថកិច្ចថៃ។

យោងតាមប្រភពព័ត៌មានថៃបានឱ្យដឹងថា ពលករខ្មែរទាំងអស់ធ្វើការនៅក្នុងសណ្ឋាគារមួយក្នុងខេត្តរ៉ាក់យ៉ង ហើយបានជួលក្រុហ៊ុនរត់ការធ្វើប៉ាស្ព័រការងារប្រភេទ mou អស់រយៈពេលជាច្រើនខែមកហើយ ក្រោយមកក្រុមហ៊ុនបានទូរស័ព្ទហៅអោយមកទទួលប៉ាស្ព័រនៅខាងក្រុងប៉ោយប៉ែត។ ដោយពួកគាត់ទាំងអស់គ្នាបានដំណើរតាមរថយន្ត មកចុះនៅខាងជាយដែនខ្មែរ-ថៃស្ថិតនៅត្រង់ក្រោយបរិវេណផ្សារលុងក្លឿ ស្រុកអារញ្ញប្រមាណជាង 500ម៉ែត ហើយចុះដើរបន្តតាមរយៈច្រកព្រំដែនធម្មជាតិ ដោយមានអ្នកមកចាំទទួល តែក៏ត្រូវកម្លាំងសមត្ថកិច្ចថៃមកប្រទះឃើញរួចឃាត់ខ្លួនយកទៅធ្វើការសាកសួរតែម្តង។

## ប្រកាសតឿនពលករកម្ពុជា ប្រយ័ត្នចាញ់បោកជនខិលខូច កុហករឿងធ្វើប័ណ្ណស៊ីជម្ពូ

http://www.pheaktraprak.com November 23, 2017

ថ្ងៃនេះខ្ញុំសូមជូនដំណឹងដល់បងប្អូនពលករកម្ពុជា ដែលកំពុងធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ សូមប្រញាប់វិលត្រឡប់ទៅប្រទេសរបស់យើងវិញជាបន្ទាន់ ដើម្បីធ្វើឯកសារចូលមកដោយស្របច្បាប់តាមរយៈ MOU និងនីតិវិធីផ្សេងៗដែលច្បាប់បានកំណត់។

សូមបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់កុំជឿរតាមសម្តីរបស់បុគ្គលណាសោះ.! ដែលនិយាយថាប្រទេសថៃនិងបើកធ្វើប័ណ្ណស៊ីជម្ពូ, ប៉ាស្ព័រ ជូនកម្មករខុសច្បាប់នៅពេលឆាប់ខាងមុខទៀតនេះឱ្យសោះ។ ព្រោះរាជរដ្ឋាភិបាលថៃ បានចេញសេចក្តីប្រកាសច្បាស់លាស់ណាស់ ថានឹងឈប់ផ្តល់ការស្នាក់នៅឬធ្វើឯកសារផ្សេងៗដូចជាប័ណ្ណស៊ីជម្ពូ,ប៉ាស្ព័រ ជូនពលករចំណាកខុសច្បាប់ក្នុងប្រទេសថៃ ទៀតហើយចាប់ពីថ្ងៃទី 07 ខែសីហា ឆ្នាំ2017 កន្លងមក ដូច្នេះសូមបងប្អូនកុំជឿតាមបុគ្គលណាដែលកំពុងភូតកុហកបងប្អូនអោយសោះ។

រាជរដ្ឋាភិបាលថៃ មាននយោបាយអោយកម្មករចំណាកស្រុកខុសច្បាប់ទាំងអស់ ត្រូវវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ហើយធ្វើដំណើរចូលមកធ្វើការនៅប្រទេសថៃ តាមរយៈ MOU ដែលទីតាំងធ្វើឯកសារនាំចូលពលករនៅតាមច្រកអន្តរជាតិនានា ដែលរាជរដ្ឋាភិបាលថៃ និងរាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយគ្នាកន្លងមកតែប៉ុណ្ណោះ។ ដូច្នេះសូមបងប្អូនប្រជាពលរដ្ឋកកម្ពុជាកុំចំណាកខុសច្បាប់ចូលមកធ្វើការខុសច្បាប់ នៅក្នុងប្រទេសថៃជាដាច់ខាត។ ប្រែសម្រួលដោយ:ដំណឹងពលករឆ្លងដែន

## ជនជាតិវៀតណាម 2នាក់ ត្រូវកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃចាប់ខ្លួន

http://www.pheaktraprak.com November 23, 2017

កាលពីថ្ងៃព្រហស្បតិ៍ទី23 ខែវិច្ឆិកា ឆ្នាំ2017 ព្រឹកមិញនេះកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃ ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិថៃ-ឡាវ ស្ថិតនៅខេត្ត ណងខាយ ប្រទេសថៃ បានធ្វើការឃាត់ខ្លួនជនជាតិវៀតណាម ខុសច្បាប់ចំនួន2 នាក់ បន្ទាប់ពីស្នាក់នៅក្នុងប្រទេសថៃ ហួសពេលទិដ្ឋាការវីសារកំណត់។

យោងតាមប្រភពព័ត៌មានពីភ្នាក់ងារ បានអោយដឹងថា ជនជាតិវៀតណាមទាំងពីរនាក់ដែលត្រូវកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃឃាត់ខ្លួននោះទី1.មានឈ្មោះធូ ដឹក ដឹយ ភេទប្រុស អាយុ22ឆ្នាំ សញ្ជាតិវៀតណាម កាន់លិខិតឆ្លងដែនទេសចរណ៍ ស្នាក់នៅក្នុងប្រទេសថៃ ហួសទិដ្ឋាការវីសារបានកំណត់ចំនួន 895 ថ្ងៃ ទី2.ឈ្មោះ ណាងគឿង ប៉ាំង ភេទប្រុស អាយុ21ឆ្នាំ សញ្ជាតិវៀតណាម កាន់លិខិតឆ្លងដែនទេសចរណ៍ ស្នាក់នៅក្នុងប្រទេសថៃ ហួសទិដ្ឋាការវីសារ បានកំណត់ចំនួន615 ថ្ងៃ ។

តាមការបញ្ជាក់របស់សមត្ថកិច្ចអន្តោប្រវេសន៍ថៃ បានមានប្រសាសន៍ថាជនជាតិវៀតណាមទាំងពីរនាក់លបលួចធ្វើការខុសច្បាប់នៅក្នុងខេត្តភូកេត តែនាពេលកន្លងមកកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃបានចុះបង្ក្រាបជនអន្តោប្រវេសន៍ខុសច្បាប់នៅខេត្តភូកេតយ៉ាងសកម្ម ធ្វើឲ្យជនជាតិវៀតណាមទាំងពីរនាក់ភ័យខ្លាច បានជួលឱ្យជនជាតិថៃ នាំចាកចេញពីខេត្តភូកេតទៅប្រទេសវៀតណាមវិញ ដោយធ្វើដំណើរតាមរយៈច្រកព្រំដែនអន្តរជាតិថៃ-ឡាវ ដោយមានជនជាតិថៃទាំងពីរប្តីប្រពន្ធជាអ្នកបើកបររថយន្តសុ ីឈ្នួលដឹក នាំអោយឆ្លងដែនទៅខាងឡាវ តែក៏ត្រូវកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃប្រចាំច្រកទ្វារព្រំដែនថៃ-ឡាវឆែកឆេររកឃើញខណៈពេលកំពុងអង្គុយក្នុងរថយន្តនៅត្រង់ចំណុចស្ពានព្រំដែនថៃ-ឡាវ ។

ក្រោយការឃាត់ខ្លួនជនជាតិថៃទាំងពីរនាក់បានសារភាពថាពួកគេបានសុ ីឈ្នួលដឹកជនជាតិវៀតណាមខុសច្បាប់ទាំងពីរនាក់ មកពីខេត្តភូកេតទៅខាងប្រទេសឡាវ ដោយគិតឈ្នួលក្នុងម្នាក់មនុស្សម្នាក់តំលៃ3000បាតក្រោយការសាកសួរសម្ថកិច្ចថៃបានធ្វើការចោទប្រកាន់ជាតិវៀតណាមទាំងពីរនាក់ពីស្នាក់នៅក្នុងប្រទេសថៃដោយគ្មានច្បាប់អនុញ្ញាត រួចកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## អាជ្ញាធរកូរ៉េខាងត្បូង ឃាត់ខ្លួនជនជាតិថៃចំណាកខុសច្បាប់ជិត50នាក់ ប្រលានយន្តហោះ

http://www.pheaktraprak.com November 23, 2017

យោងតាមប្រភពព័ត៌មានពីប្រទេសថៃ បានអោយដឹងថា កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ប្រទេសកូរ៉េខាងត្បូងបានធ្វើការឃាត់ខ្លួនជនជាតិថៃ ប្រុសស្រីចំណាកស្រុកខុសច្បាប់ចំនួនជិត50នាក់ នៅត្រង់បរិវេណអាកាសយានដ្ឋានអន្តរជាតិទីក្រុងសូប្រទេសកូរ៉េ បន្ទាប់ពីអាជ្ញាធរកូរ៉េស្រាវជ្រាវដឹងថាជនជាតិថៃទាំងនោះបានធ្វើដំណើរទៅស្វែងរកការងារធ្វើនៅក្នុងប្រទេសកូរ៉េ។ ដោយមិនមែនមកទេសចរណ៍ដូចភ្ញៀវបរទេសដ៏ទៃឡើយ ករណីនេះបានកើតឡើងកាលពីថ្មីកន្លងទៅនេះ។ ជនជាតិថៃមួយចំនួននិយមចំណាកស្រុកទៅស្វែងរកការងារធ្វើនៅឯប្រទេសកូរ៉េព្រោះនៅទីនោះធ្វើការបានប្រាក់ខែខ្ពស់ជាងប្រទេសថៃ ហើយការងារដែលជនជាតិថៃធ្វើនៅប្រទេសកូរ៉េនោះគឺការងារម៉ាស្សានិងធ្វើសរសៃ។

## រថយន្តបុករថយន្តផ្ទុះឆេះ ស្លាប់ពលករសរុប១៣នាក់ នៅប្រទេសថៃ

http://cambodiapolice.com/ ម៉ោង 1:08 pm 24 វិច្ឆិកា 2017 7

ប្រទេសថៃ ៖ ពលករដែលមានទិសដៅទៅធ្វើការនៅទីក្រុងបាងកកចំនួន១៣នាក់ រួមជាមួយនឹងអ្នកបើកបរម្នាក់ ដែលជាជនជាតិថៃ ត្រូវបានស្លាប់ព្រមទាំងឆេះខ្លោចសឹងមើលលែងយល់ ខណៈដែលអ្នកបើកបររូបនេះ

បានប្រើប្រាស់ល្បឿនលឿនក្នុងពេលយប់ងងឹតហើយជ្រុលទៅបុកនឹងរថយន្តធុនធ្ងន់ ដោយសារបាត់បង់ភាពជាម្ចាស់ការ ហើយត្រូវរថយន្តផ្ទុះឆេះឡើងតែម្តង ។

យោងតាមរបាយការណ៍របស់ថៃដែលយើងទទួលបានគឺ ករណីគ្រោះថ្នាក់ចរាចរណ៍នេះបានកើតឡើងកាលពីវេលាម៉ោង២និង៣០នាទីរំលងអាធ្រាត្រ ឈានចូលថ្ងៃទី ២៤ខែវិច្ឆិកា ឆ្នាំ២០១៧ លើកំណាត់ផ្លូវអេឈៀត្រង់បង្គោលគីឡូម៉ែត្រលេខ ៩០+៦០០ក្នុងខេត្ត សិង្ហបុរី ប្រទេសថៃ រវាងរថយន្តសាំយ៉ុង ពាក់ស្លាកលេខ បាងកក ៣៣~៣២៤១ជាមួយនឹងរថយន្តធុនដឹកជញ្ជូនកង់១០ ម៉ាក មីតស៊ុយប៊ីស៊ីពណ៌ស ពាក់ស្លាកលេខនគរសុវណ្ណ ៨១~៧៤០៧ ដែលបើកបរក្នុងទិសដៅស្របគ្នា ។

តាមការអេះអាងពីឈ្មោះ សុនថន ហ្វាក់ថង ភេទប្រុស អាយុ៥៥ឆ្នាំ រស់នៅខេត្តនគរសុវណ្ណ និងជាអ្នកបើកបររថយន្តធំផងនោះ បានរៀបរាប់ថា នៅមុនពេលកើតហេតុគឺខ្លួនបានបើករថយន្តដឹកអង្ករ ចេញពីខេត្តនគរសុវណ្ណ ឆ្ពោះទៅខេត្តសារៈបុរី លុះទៅដល់ត្រង់ចំណុចកើតហេតុខាងលើស្រាប់តែឃើញរថយន្តសាំយ៉ុងមួយគ្រឿងនេះ បានបើកមកយ៉ាងលឿន ហើយបុកគូទរថយន្តរបស់លោកពីក្រោយយ៉ាងពេញទំហឹង រួចក៏ជ្រុលទៅមុខប្រហែល១០ម៉ែត្រ ក៏បានផ្ទុះឆេះអណ្តាតភ្លើងយ៉ាងសន្ធោសន្ធៅតែម្តង ដោយលោកបានត្រឹមតែទូរស័ព្ទរាយការណ៍ទៅសមត្ថកិច្ចតម្រួតអោយជួយអន្តរាគមន៍តែប៉ុណ្ណោះ ។

នៅក្នុងអណ្តាតភ្លើងដ៏សន្ធោសន្ធៅនេះ គ្មានអ្នកណាម្នាក់អាចចូលទៅជួយជនរងគ្រោះនៅក្នុងរថយន្តបានឡើយ រហូតធ្វើអោយមនុស្សទាំងអស់នៅក្នុងរថយន្ត ឆេះក្រៀមខ្លោចសឹងតែមើលមិនដឹងថាជាមនុស្សប្រុស ឬស្រីហើយមានវ័យប្រហែលប៉ុន្មានឡើយ ប៉ុន្តែក្រោយពេលសមត្ថកិច្ចថៃ ចុះទៅត្រួតពិនិត្យ ព្រមទាំងបានប្រើប្រាស់ឧបករណ៍ កាត់ជញ្ជាំងរថយន្តដើម្បីទាញយកសពចេញពីក្នុងរថយន្ត ដោយសរុបមានចំនួន១៤នាក់។

សមត្ថកិច្ចបានអះអាងថា រថយន្តនេះគឺអ្នកបើកបរជាជនជាតិថៃ ដោយបានដឹកពលករជាជនជាតិភូមាសរុបចំនួន១៣នាក់ ចេញពីស្រុកម៉ែសត ខេត្តតាក ឆ្ពោះទៅកាន់ទីក្រុងបាងកក ដើម្បីរកការងារធ្វើ ហើយក៏បានជួបនឹងគ្រោះថ្នាក់បែបនេះ ដោយបច្ចុប្បន្នសមត្ថកិច្ចបានបញ្ជូនសពទាំងអស់ទៅកាន់អង្គភាពជំនាញដើម្បីពិនិត្យ D M A ក្នុងការវិភាគរកអត្តសញ្ញាណ ក្នុងការបញ្ជូនទៅអោយក្រុមគ្រួសាររៀងៗខ្លួន ៕

## ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧

## លោកស្រី ម៉ែន សំអន ជួបសំណេះសំណាលផ្តល់ការលើកទឹកចិត្តដល់កម្មករ កម្មការិនីចំនួន ១.០១៧នាក់ នៅខេត្តផាថុមថានី ប្រទេសថៃ

http://nokorwatnews.com/ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៧

បាងកកៈ ឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី ចំនួន ១.០១៧នាក់ ដែលកំពុងធ្វើការនៅរោងចក្រផលិតសាច់មាន់ឈ្មោះ Centaco group នៅខេត្តឈុនបុរី ប្រទេសថៃ នាព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៧។

ថ្លែងក្នុងឱកាសនោះ លោកស្រី ក៏បាននាំយកនូវការផ្តាំផ្ញើ និងសាកសួរសុខទុក្ខពីសំណាក់ ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងបានផ្តល់កម្លាំងចិត្តឲ្យកម្មករពលករខ្មែរទាំងអស់ប្រឹងប្រែងធ្វើការងារ កាន់តែសកម្មថែមទៀត ដើម្បីទទួលបានប្រាក់ខែខ្ពស់ និងទទួលការពេញចិត្តពីថៅកែរោងចក្រ។ ការមកជួបសំណេះសំណាលនេះ ពិតជា

គូសបញ្ជាក់ពីការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន សម្តេចតេជោ ហ៊ុន សែន ជាប្រមុខ ដែលជានិច្ចកាលតែងតែ មានមនោសញ្ចេតនាជិតស្និទ្ធជាមួយប្រជាជន និងជាមួយពលករ

។ ជាក់ស្តែង ដូចជាពេលនេះ ទោះជាបងប្អូនមកធ្វើការនៅប្រទេសថៃ ឆ្ងាយពីស្រុកកំណើតក្តី ក៏សម្តេចនៅតែគិតគូរ និងបានចាត់តាំងខ្ញុំ និងក្រុមការងារមួយចំនួនទៀត ដូចជាលោក អ៊ិត សំហេង លោក ហ៊ុន ម៉ានី លោក ហ៊ុន ម៉ាណែត និងលោក ព្រុំ សុខា ជាតំណាងមកជួបសំណេះសំណាលជាមួយប្អូនៗ ដើម្បីសាកសួរសុខទុក្ខ និងចែករំលែកព័ត៌មាន និងជួយដោះស្រាយបញ្ហាផ្សេងៗដែលប្អូនៗជួបប្រទះ។ លោកស្រី បានបន្តទៀតថា បច្ចុប្បន្ន រាជរដ្ឋាភិបាលបានផ្តល់លិខិតឆ្លងដែនជូនពលករយើង ដោយមិនគិតថ្លៃ និងបានរៀបចំ គណៈកម្មាការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដើម្បីដោះស្រាយការលំបាកនានា ជាពិសេសជួយសម្រួលឱ្យប្អូនៗពលករយើងរស់នៅ និងធ្វើការដោយស្របច្បាប់ និងដោយមានកិត្តិយស រួចផុតពីការរំលោភ ជិះជាន់ កេងប្រវ័ញ្ច និងហានិភ័យផ្សេងៗ។

មុននឹងបញ្ចប់ពិធីសំណេះសំណាលនេះ លោកស្រីឧបនាយករដ្ឋមន្ត្រី បានផ្តាំផ្ញើដល់ពលករខ្មែរទាំងនោះ ត្រូវគោរពច្បាប់ប្រទេសថៃ។ ដាច់ខាតមិនត្រូវប្រព្រឹត្តិបទល្មើស ដូចជាអំពើហឹង្សា គ្រឿងញៀន។ ល។ ហើយកុំជឿតាមការញុះញង់របស់អតីតគណបក្សប្រឆាំងដែលមានបំណង បំផ្លាញសន្តិភាព និងរារាំងដល់ការអភិវឌ្ឍន៍ប្រទេស។ ចំណែកឯថៅកែក្រុមហ៊ុន សូមបន្តទទួលពលករខ្មែរបន្ថែមទៀត និងសូមអាណិតស្រឡាញ់ពលករខ្មែរដូចពលករថៃ និងស្ថានទូត ស្ថានអគ្គកុងស៊ុលកម្ពុជា សូមបន្តការយកចិត្តទុកដាក់តាមដាន និងជួយដោះស្រាយរាល់បញ្ហានានារបស់ពលករខ្មែរ ស្របតាមច្បាប់អន្តរជាតិ ច្បាប់ប្រទេសថៃ និងស្មារតីនៃ MOU ដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានចុះហត្ថលេខា៕ សំរិត

## អភិបាលរងខេត្តបន្តដាក់វិធានការដល់កម្លាំងឈរជើងតាមបន្ទាត់ព្រំដែនទប់ស្កាត់ពលករចំណាកស្រុកព្រោះរយៈពេល១០ខែឆ្នាំ២០១៧ទប់ស្កាត់បានចំនួន៧៥៦នាក់

http://cambodiapolice.com/ ម៉ោង 10:47 pm 26 វិច្ឆិកា 2017

បន្ទាយមានជ័យ ៖ អភិបាលរងខេត្តនៅបន្តដាក់វិធានការដល់កម្លាំងឈរជើងតាមបន្ទាត់ព្រំដែនទប់ស្កាត់ពលករចំណាក់ស្រុកព្រោះរយៈពេល១០ខែ ឆ្នាំ២០១៧ ទប់ស្កាត់បានចំនួន៧៥៦នាក់ ដែលលើកឡើងកិច្ចប្រជុំលទ្ធផលការងារកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ។ លោកស្រី ប៉ុក ណាឌី អភិបាលរងខេត្តបន្ទាយមានជ័យមានប្រសាសន៍ថា៖កិច្ចប្រជុំលទ្ធផលការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបន្ទាយមានជ័យរយៈពេល១០ខែ ក្នុងឆ្នាំ២០១៧នេះគឺកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានសហការកម្លាំងនគរបាលឈរជើងតាមបន្ទាត់ព្រំដែនធ្វើការទប់ស្កាត់ពលករខ្មែរចំណាក់ស្រុកខុសច្បាប់ដែលទៅរកការងារធ្វើដោយខុសច្បាប់នៅប្រទេសថៃ។

លោកស្រីបានបញ្ជាក់ថា៖ ពលករចំណាក់ស្រុកខុសច្បាប់ដែលត្រូវទប់ស្កាត់តាមច្រករបៀងខុសច្បាប់តាមបន្ទាត់ព្រំដែនរយៈពេល១០ខែឆ្នាំ២០១៧នេះមានចំនួន២៦លើកសរុបចំនួន៧៥៦នាក់ ស្រី២៧១នាក់ កុមារ៥០នាក់មកពីចំនួន១៦ខេត្ត។ ហើយត្រូវបានអប់រំណែនាំដល់ពលករចំណាក់ស្រុកមានការយល់ដឹងពីសុវត្តិភាពរបស់ខ្លួនដែលឆ្លងដែនទៅរកការងារធ្វើដោយខុសច្បាប់ប្រឈមគ្រោះ។ លោកស្រី ប៉ុក ណាឌី បានមានប្រសាសន៍ដាក់វិធានការដល់កម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវតែទប់ស្កាតពលករចំណាក់ស្រុកខុសច្បាប់អោយបានព្រោះថាកំណើនពលករចំណាកស្រុកខុសច្បាប់រយៈពេល១០ខែ ក្នុងឆ្នាំ២០១៧នេះ ឃាត់ធ្វើការអប់រំបានសរុបចំនួន៧៥៦នាក់ ស្រី២៧១នាក់ កុមារ៥០នាក់៕ ដោយ៖ចន្ទ្រា

## ពលរដ្ឋជាង៣០នាក់ប្តឹងស្រ្តីម្នាក់ពីបទឆបោកថាអាចធានាទៅជប៉ុន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ម៉ោង ១៤:០៣ ប៊ុង ឆដា

ខេត្តកណ្តាល ៖ កាលពីព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ពលរដ្ឋជាង៣០នាក់ មកពីស្រុកកៀនស្វាយ បានមកដាក់ពាក្យបណ្តឹងទៅលើស្រ្តីឆបោកម្នាក់ឈ្មោះ អៀត សារឹម ដែលបានឆបោកប្រាក់ពួកគាត់ ថាធានាទៅធ្វើពលករនៅប្រទេសជប៉ុន ចូលសាលាដំបូងខេត្តកណ្តាល ដើម្បីសុំឲ្យតុលាការមេត្តាជួយដោះស្រាយតាមនីតិវិធី ។

ពលរដ្ឋជាច្រើនបានប្រាប់ឲ្យដឹងថា ពួកគាត់ត្រូវបានស្រ្តីឈ្មោះ អៀត សារឹម បានឆបោកពួកគាត់ ដោយលួងលោមថា បើចង់ទៅធ្វើការនៅប្រទេសជប៉ុនបានប្រាប់ខែច្រើន ចាំខ្លួនធានាយកទៅ ឲ្យតែប្រគល់ប្រាក់ឲ្យខ្លួនម្នាក់ ១,០០០ ទៅ២០០០ដុល្លារ បានទៅហើយ ។ តែអ្វីដែលពួកគាត់ខំទុកចិត្តនោះ គឺបានត្រឹមតែត្រូវស្រ្តីឆបោក អៀត សារឹម យកលុយពីពួកគាត់យកទៅចាយអស់ពោល គឺលុយក៏អស់ មនុស្សក៏អត់បានទៅ ។ ពលរដ្ឋបានប្រាប់បន្ថែមទៀតថា ពួកគាត់មកដាក់ពាក្យបណ្តឹង គឺសូមឲ្យតុលាការមេត្តាជួយដោះស្រាយតាមច្បាប់លើបុគ្គលឆបោកខាងលើ ។ បច្ចុប្បន្នស្រ្តីឆបោកឈ្មោះ អៀត សារឹម កំពុងជាប់ឃុំឃាំងនៅពន្ធនាគារខេត្តកណ្តាល ៕

## ពលករខ្មែរ៤នាក់ស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅខេត្តច័ន្ទបុរី ទឹកដីថៃ

http://nokorwatnews.com/ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៧

ប៉ោយប៉ែត៖ ពលករខ្មែរ៤នាក់ បានស្លាប់ភ្លាមៗនៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយ ក្នុងចំណោមពលករសរុប៥នាក់ ខណៈដែលពួកគេទាំងអស់គ្នាបានធ្វើដំណើរតាមរយៈថយន្តតាក់ស៊ី ហើយបានរេចង្កូតធ្លាក់ចេញពីផ្លូវទៅបុកនឹងដើមឈើយ៉ាងពេញទំហឹងរួចមក ។

តាមសេចក្តីរាយការណ៍បានបញ្ជាក់ថា ករណីនេះ បានកើតឡើងនៅព្រលប់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងឃុំខៅវង់កុត ស្រុកកែងហាងម៉ែវ ខេត្តច័ន្ទបុរី ប្រទេសថៃ ដោយបង្កឡើងដោយរថយន្តតាក់ស៊ីមួយគ្រឿង បើកបរដោយជនជាតិថៃ ព្រមទាំងមានដឹកពលករខ្មែរសរុប៥ នាក់ផង ក្នុងគោលបំណងទៅធ្វើការនៅក្នុងទីក្រុងបាងកក ។ សាក្សីបាននិយាយថា នៅមុនពេលកើតហេតុ គេសង្កេតឃើញរថយន្តតាក់ស៊ី ខាងលើ បានបើកបរក្នុងល្បឿនយ៉ាងលឿន លុះទៅដល់ត្រង់ចំណុចកើតហេតុខាងលើ ស្រាប់តែរថយន្តនេះ បានរេចង្កូតធ្លាក់ចេញពីផ្លូវ ទៅបុកនឹងគល់ឈើមួយដើម បណ្តាលឲ្យអ្នកដំណើរនៅក្នុងរថយន្ត ខ្ទាតចេញពាសវាល ពាសកាល ដោយឡែកអ្នកបើកបររថយន្តដែលជាជនជាតិថៃ មានឈ្មោះ ឡាំកួន កែវយ៉ៃ ភេទប្រុស អាយុ៤៣ឆ្នាំ រស់នៅឃុំបានដុង ស្រុកបានដុង ខេត្តអ៊ុដនថានី គៀបជាប់នៅក្នុងរថយន្តស្លាប់យ៉ាងអាណោចអាធ័មជាទីបំផុត ។

ក្រោយពេលតម្រួតថៃចុះពិនិត្យទីតាំងកើតហេតុ ទើបដឹងថា អ្នកដំណើរទាំង៥នាក់ គឺជាពលករខ្មែរ ដោយ៤នាក់ ត្រូវស្លាប់ ប្រុស២នាក់ ស្រី២នាក់ និងបុរសម្នាក់ រងរបួសជាទម្ងន់ នៅក្នុងនោះដែរ តម្រួតថៃក៏បានរកឃើញនារីម្នាក់ មានជាប់អត្តសញ្ញាណប័ណ្ណខ្មែរ នៅនឹងខ្លួនដែលមានឈ្មោះ សឿន សីន ភេទស្រី អាយុ១៩ឆ្នាំ រស់នៅភូមិដូនអែម ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ។ បច្ចុប្បន្នក្រុមតម្រួតថៃ កំពុងស្រាវជ្រាវរកអត្តសញ្ញាណអ្នកស្លាប់ផ្សេងទៀត ដើម្បីរៀបចំ ឯកសារបញ្ជូនសព មកកាន់ស្រុកកំណើតវិញ ដើម្បីប្រគល់ឲ្យក្រុមគ្រួសាររៀបចំធ្វើបុណ្យតាមប្រពៃណី ៕ វណ្ណា

## ចាប់ខ្លួនពលករ 4 នាក់ ពីបទកាន់លិខិតឆ្លងដែនក្លែងក្លាយ

http://www.pheaktraprak.com November 27, 2017

កាលពីថ្ងៃអាទិត្យទី26 ខែវិច្ឆិកា ឆ្នាំ2017 កន្លងទៅថ្មីនេះ កម្លាំងអាជ្ញាធរថៃប្រចាំផ្សារលុងភឿស្រុកអារញ្ញខេត្តស្រះកែវ ធ្វើការឃាត់ខ្លួនពលករខ្មែរចំណាកស្រុកចំនួន4 នាក់ ខណៈពេលកំពុងឡើងធ្វើដំណើរចេញពីផ្សារ

លុងក្លៀរទៅទីក្រុងបាងកក។ យោងតាមប្រភពព័ត៌មានរបស់ថៃ បានចុះផ្សាយឱ្យដឹងថា ពលករចំណាកស្រុកកម្ពុជាចំនួន4នាក់ ត្រូវបានកម្លាំងទាហានឈុតខ្មៅប្រចាំកងពលលេខ1201 សហការជាមួយតម្រួតអន្តោប្រវេសន៍ស្រុកអារញ្ញ ធ្វើការឃាត់ខ្លួន បន្ទាប់ពីទាហានថៃត្រួតពិនិត្យលិខិតឆ្លងដែន របស់ពលករទាំង4 នាក់ ដឹងថាជាលិខិតឆ្លងដែនក្លែងក្លាយ។

ពលករខ្មែរទាំង4 នាក់ត្រូវទាហានថៃចាប់ខ្លួននោះរួមមាន 1 ឈ្មោះយាង ឈៀង ភេទប្រុស អាយុ24ឆ្នាំ សញ្ជាតិខ្មែរ 2 ឈ្មោះហុន សារិត ភេទប្រុស អាយុ20ឆ្នាំ សញ្ជាតិខ្មែរ 3 ឈ្មោះ សារឿន ចំរើន ភេទប្រុស អាយុ30ឆ្នាំ សញ្ជាតិខ្មែរ 4 ឈ្មោះយាងឈឿង ភេទស្រី អាយុ30ឆ្នាំ សញ្ជាតិខ្មែរ អ្នកទាំងគ្នារស់នៅក្នុងខេត្តកំពង់ចាម ប្រទេសកម្ពុជា។ តាមចម្លើយសារភាពពលករខ្មែរទាំងអស់បានប្រាប់ពួកគាត់ធ្វើដំណើរមកពីស្រុកកំណើត ហើយឆ្លងដែនតាមរយៈច្រកព្រំដែនធម្មជាតិ ដោយមានអ្នកនាំផ្លូវចូលខាងថៃ ដោយបង់ផ្លូវម្នាក់2000បាត ដើម្បីទៅស្វែងរកការងារធ្វេ ីនៅទីក្រុងបាងកក ប្រទេសថៃ ។

បច្ចុប្បន្នពលករខ្មែរទាំង4នាក់ ត្រូវតម្រួតអន្តោប្រវេសន៍ថៃ បញ្ជូនទៅធ្វេ ីការសាកសួរ និងចោទប្រកាន់ពីបទកាន់លិខិតឆ្លងដែនក្លែងក្លាយ និងឆ្លងដែនចូលមកប្រទេសថៃដោយខុសច្បាប់។

## ពលករខ្មែរកំពុងខុសច្បាប់ក្នុងប្រទេសថៃ ចាប់ផ្តើមងាករកសេវាកម្មធ្វើប៉ាស្ព័រMOU

http://www.pheaktraprak.com November 25, 2017

ពលករខ្មែរកំពុងធ្វើការខុសច្បាប់នៅប្រទេសថៃ កំពុងងាករកសេវាកម្មធរើប៉ាស្ព័រ MOU វិញម្តងបន្ទាប់ពីរាជរដ្ឋាភិបាលថៃ ប្រកាសឈប់ធ្វើឯកសារអោយអ្នកខុសច្បាប់ទៀត។ បងប្អូនពលករកម្ពុជាមួយចំនួនធំដែលកំពុងធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ អស់រយៈពេលជាច្រើនខែច្រើនឆ្នាំមកហើយនោះ ឥឡូវនេះបានសម្រេចចិត្តនាំគ្នាទៅជួលក្រុមហ៊ុនផ្សេងនៅក្នុងប្រទេសថៃ អោយដើរឿងធ្វើប៉ាស្ព័រការងារដែលពលករភាគច្រើនហៅថា (ប៉ាស្ព័រ MOU) វិញម្តងទោះបីជាប៉ាស្ព័រនោះមានតំលៃខ្ពស់យ៉ាងណាក៏ដោយ។

ការដែលបងប្អូនពលករខ្មែរខុសច្បាប់ងាកទៅរកសេវាកម្មធ្វើប៉ាស្ព័រ MOU នោះ គឺបន្ទាប់ពីរាជរដ្ឋាភិបាលថៃបានប្រកាសជាផ្លូវការថាប្រទេសថៃឈប់បើកធ្វើប័ណ្ណស៊ីជម្ពូ ឬប៉ាស្ព័រការងារជូនដល់អ្នកដែលខុសច្បាប់ទៀតហើយពោលគឺតំរូវអោយអ្នកដែលខុសច្បាប់ត្រូវវិលត្រឡប់ទៅដើរឿងធ្វើប៉ាស្ព័រការងារMOUពីប្រទេសរបស់ខ្លួនឡើងមកធ្វើការវិញ។ បច្ចុប្បន្នប៉ាស្ព័រMOU មានតំលៃចាប់ពី18.500បាត រហូតដល់27.000បាត អាស្រ័យទៅលើជួលក្រុមហ៊ុននីមួយៗដែលគេទាពីពួកគាត់។ ហើយក្នុងដំណាក់កាលដែលកំពុងដើររឿងធ្វើប៉ាស្ព័រ MOU នោះ ពួកគាត់ត្រូវធ្វើការនៅប្រទេសថៃបែបលួចលាក់ព្រោះការធ្វើប៉ាស្ព័រMOUនេះ មានរយៈពេលចាប់ពី45ថ្ងៃ-60ថ្ងៃ ដូច្នេះគាត់តែងតែចង់ឲ្យរាជរដ្ឋាភិបាលជួយកាត់បន្ថយពេលដែលដើររឿងធ្វើប៉ាស្ព័រMOU នោះអោយមានរយៈខ្លីជាងមុនដើម្បីកុំឱ្យពួកគាត់ភ័យព្រួយនៅពេលមានសមត្ថកិច្ចថៃមកធ្វើការត្រួតពិនិត្យ។

## យោធាកម្ពុជា-ថៃ សន្យារួមគ្នាទប់ស្កាត់ ការលួចឆ្លងដែនកាប់ឈើ និងបទល្មើសតាមព្រំដែន

https://www.dap-news.com/kh/ អាទិត្យ, ២៦ វិច្ឆិកា ២០១៧ 10:32 ដោយ: ដើមអម្ពិល ID:019

**ឧត្តរមានជ័យ៖** យោធាកម្ពុជា ដឹកនាំដោយលោកអនុសេនីយ៍ទោ ហ៊ុន ប៊ី នាយរងប៉ុស្តិ៍ជាំ និងលោក អនុសេនីយ៍ត្រី សុខ ឈឿយ មេបញ្ជាការកងល្បាតទី២ រួមទាំងនគរបាលប៉ុស្តិ៍ភ្នំត្បាល់ កាលពីថ្ងៃ ទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៧ បានជួបជាមួយយោធាថៃ ដែលដឹកនាំដោយ លោក អនុសេនីយ៍ឯក សាន់ទិ វ៉ន្លោះថងគូន មេបញ្ជាការកងរយ ២៣០២ ឈុនខ្មៅថៃ ពិភាក្សាពីបញ្ហាលួច ឆ្លងដែនខុសច្បាប់ ចូលទៅកាប់ឈើ និងរួមគ្នាទប់ស្កាត់បទ

ល្មើស តាមបន្ទាន់ព្រំដែន នៃប្រទេសទាំងពីរ ។ ជាលទ្ធផលនៃជំនួប ភាគីទាំងពីរ បានសម្រេចរួមគ្នាទប់ស្កាត់ ការឆ្លងដែនកាប់ឈើ និងបទល្មើសផ្សេងៗ នៅតាមខ្សែបន្ទាត់ព្រំដែន, ឯកភាពឲ្យមានការប្រកួតកីឡា រវាងទាហានកម្ពុជា និងទាហានថៃ នៅថ្ងៃទី១៥រៀងរាល់ខែ ៕

## ពលករខ្មែរម្នាក់ត្រូវគេចាក់ស្លាប់ដោយសាររឿងរាំងជាន់ជើងគេ

http://www.pheaktraprak.com November 25, 2017

កាលពីវេលាម៉ោងប្រមាណ11:30នាទីយប់ នាថ្ងៃសុក្រទី24 ខែវិច្ឆិកា ឆ្នាំ2017នេះ មានករណីពលករខ្មែរឈ្មោះ នួន ម៉ៃ អាយុ23ឆ្នាំ សញ្ជាតិខ្មែរ ធ្វើការសំណង់ ត្រូវក្រុមស្ទាវថៃចាក់និងកាំបិតបណ្តាលឱ្យស្លាប់ភ្លាមៗ និង 2 នាក់ទៀតរងរបួស។ ហេតុការណ៍នេះបានកើតឡើងនៅត្រង់ចំណុចផ្សារណាត់ ក្បែរកន្លែងជួសជុលរថយន្ត70 (តាឡាតអ៊ីខាងរត់សាយ70) ស្ថិតនៅភូមិ4 ឃុំថាសាយ ស្រុកមឿងខេត្តនុនថាក់បុរី ប្រទេសថៃ ។

យោងតាមប្រភពព័ត៌មានពីបុរសឈ្មោះសា មិត្តអាយុ43 ឆ្នាំសញ្ជាតិខ្មែរ ជាមិត្តរួមការងារជាមួយគ្នាប្រាប់ថា មុនកើតហេតុកម្មករខ្មែររូបនោះបានចូលរាំងក្នុងកម្មវិធីប្រគំខនសឺតមួយ ហើយបារាំងជាន់ជើងស្ទាវម្នាក់នៅកន្លែងរាំង រួចចេញមកខាង ហើយក្រុមស្ទាវបានស្រែជាក់ពលករខ្មែររូបនោះថា (មិនអីទេជួមគ្នានៅក្រៅ) ក្រោយមកក្រុមស្ទាវនោះបានលើកគ្នាចូលទៅវ៉ៃក្រុមពលករខ្មែរបណ្តាលឲ្យមានអ្នកស្លាប់និងរបួសដូចហេតុការណ៍ខាងលើនេះ។ ក្រោយពេលកើតហេតុសមត្ថកិច្ចថៃបានចុះទៅដល់កន្លែងកើតហេតុ ហើយកំពុងធ្វើការត្រួតពិនិត្យ សាកសពអ្នកស្លាប់ និងកំពុងស្រាវជ្រាវរកជនដៃដល់យកមកផ្តន្ទាទោសតាមច្បាប់។

## សមត្ថកិច្ចថៃ បើកប្រតិបត្តិការណ៍ឆ្មក់ត្រួតពិនិត្យឯកសារធ្វើការកម្មករនេសាទត្រី, ការពារសមុទ្រ

http://www.pheaktraprak.com November 25, 2017

កាលពីថ្ងៃពុធ ទី22 ខែវិច្ឆិកា ឆ្នាំ2017 កន្លងទៅផុតទៅថ្មីៗនេះ អាជ្ញាធរក្រសួងការងារថៃ ប្រចាំខេត្តរ៉ាក់ណង ប្រទេសថៃ បានរួមសហការជាមួយកម្លាំងអាជ្ញាធមូលដ្ឋាន,តម្រួត, ទាហានជើងទឹក ក្នុងតំបន់សមុទ្ររ៉ាក់ណង។ បានបើកកិច្ចប្រតិបត្តិការណ៍ឆ្មក់ចុះត្រួតពិនិត្យឯកសារធ្វើការរបស់ពលករនេសាទត្រីនៅទូកនេសាទ ស្ថិតក្នុងតំបន់សមុទ្រអាដាម៉ាណ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សនិងពលករចំណាកស្រុកខុសច្បាប់។ ក្នុងកិច្ចសហប្រតិបត្តិការនេះកម្លាំងសមត្ថកិច្ចថៃ បានធ្វើការត្រួតពិនិត្យទូកនេសាទត្រីចំនួន 4គ្រឿង ព្រមទាំងត្រួតពិនិត្យឯកសារធ្វើការកម្មករធ្វើការនេសាទត្រីនៅលើទូកចំនួន 34នាក់ ទាំងអស់គ្នាមានលិខិត អនុញ្ញាតធ្វើការយ៉ាងត្រឹមត្រូវស្រប ច្បាប់តាមច្បាប់ការងាររបស់ប្រទេសថៃ។

## រថយន្តឈ្នួលដឹកពលករខ្មែរទៅធ្វើប៉ាស្ព័រនៅខេត្តសង់ក្លា ជួបគ្រោះថ្នាក់ចរាចរ

http://www.pheaktraprak.com November 26, 2017

រថយន្តឈ្នួលដឹកពលករកម្ពុជាទៅបញ្ជាក់អត្តសញ្ញាណ ធ្វើប៉ាស្ព័រនៅខេត្តសង់ក្លា ជួបគ្រោះថ្នាក់ចរាចរតាមផ្លូវបណ្តាលឱ្យពលករខ្មែរចំនួន13នាក់ភ័យព្រលឹងនៅចុងសក់ បន្ទាប់ពីបើកបុកគូទរថយន្តដឹកទំនិញសិបឡ។ ករណីគ្រោះថ្នាក់ចរាចរនេះកើតឡើងកាលពីព្រឹកថ្ងៃសៅរ៍ទី25 ខែវិច្ឆិកា ឆ្នាំ2017 នៅត្រង់ចំណុចផ្លូវបំបែកជាបួន ស្ថិតក្នុងស្រុកហាត់យ៉ៃ ខេត្តសុងក្លា យោងតាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា ពលករកម្ពុជាដែលជិះក្នុងរថយន្តប្រមាណ13នាក់ មិនបានរងរបួសអ្វីឡើយគ្រាន់តែមានអាការៈភ័យស្លន់ស្លោតែប៉ុណ្ណោះ។

## តម្រួតទេសចរណ៍ថៃ ស្ទាក់ចាប់ពលករកម្ពុជាគ្មានឯកសារចំនួន39នាក់

http://www.pheaktraprak.com November 27, 2017

ពលករកម្ពុជាគ្មានឯកសារចំនួន39នាក់ ត្រូវកម្លាំងសមត្ថកិច្ចតម្រួតទេសចរណ៍ឃាត់ខ្លួន បន្ទាប់ពីធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតវិញ។ កាលពីថ្ងៃ26 ខែវិច្ឆិកា ឆ្នាំ2017កន្លងទៅនេះ សមត្ថកិច្ចតម្រួតទេសចរណ៍ ប្រចាំ

ខេត្តស្រះកែវ ប្រទេសថៃ បព្រឹត្តិបត្រការណ៍ប្រដេញស្ទាក់ចាប់រថយន្តឈ្នួលចំនួន2 គ្រឿង បន្ទាប់ពីលួចដឹកពលករខ្មែរគ្មានឯកសារវិលត្រឡប់ទៅជាយដែនកម្ពុជា-ថៃ។

យោងតាមប្រភពព័ត៌មានពីថៃបានចុះផ្សាយកាលពីថ្ងៃសៅរ៍ទី26 ខែវិច្ឆិកា ឆ្នាំ2017នេះ អោយបានដឹងថា កម្លាំងសមត្ថកិច្ចតម្រួតទេសចរណ៍ខេត្តស្រះកែវ បើកកិច្ចព្រឹត្តិការណ៍ដេញស្ទាក់ចាប់រថយន្តឈ្នួលពីរគ្រឿងនៅត្រង់ចំណុចផ្លូវជាតិ(ខៅសិនសន)ខេត្តស្រះកែវ ក្នុងកិច្ចព្រឹត្តិបត្រការណ៍នោះ កម្លាំងសមត្ថកិច្ចថៃ ឃាត់បានរថយន្តតូរីសម៉ាកToyota comener ពណ៌សចំនួនពីរគ្រឿង ព្រមទាំងឆែកឆេរកឃើញពលករខ្មែរគ្មានឯកសារចំនួន 39នាក់នៅក្នុងរថយន្តទាំងពីរគ្រឿង ចំណែកអ្នកបើកបររថយន្តខាងលើបានរត់គេចខ្លួនផុត។ ប្រភពពីពលករដែលធ្វើដំណើរតាមរថយន្តឈ្នួលទាំងពីរគ្រឿងបានសារភាពប្រាប់ថា ពួកគេទាំងអស់គ្នាធ្វើការនៅទីក្រុងបាងកកប្រទេសថៃ ហើយធ្វើដំណើរវិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ដោយឡើយងជិះរថយន្តឈ្នួលនៅម្តុំបេន(ប្រាំមសង)ក្នុងតំលៃមនុស្សម្នាក់15.00បាត-17.00បាត ។

បច្ចុប្បន្នពលករខ្មែរទាំងអស់ត្រូវកម្លាំងសមត្ថកិច្ចទេសចរណ៍ថៃធ្វើការសាកសួររួច ប្រគល់ជូនតម្រួតអន្តោប្រវេសន៍ខេត្តស្រះកែវដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ដឹងទេ តើមានពលករកម្ពុជាប៉ុន្មាននាក់ កំពុងធ្វើការនៅកូរ៉េ?

http://kleykley.sabay.com.kh/article/ សុក្រ, 24 វិច្ឆិកា 2017 10:53

លោក ហ្ស៊ីម បូយ្យុន អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសុវត្ថិភាពសាធារណរដ្ឋកូរ៉េ បានថ្លែងបញ្ជាក់ថា យុវជនយុវនារីកម្ពុជា ប្រមាណ ៤៣០០០នាក់ កំពុងធ្វើការនៅកូរ៉េ ដោយតស៊ូ និងទាំងបែកញើស ក្នុងវិស័យជាច្រើនក្នុងសង្គមសាធារណរដ្ឋកូរ៉េ។ លោកលើកឡើងដូច្នេះក្នុងជំនួបជាមួយសម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅព្រឹកថ្ងៃទី២៤វិច្ឆិកា។ លោកឲ្យដឹងថា តាំងពីឆ្នាំ១៩៩៧មក ទំនាក់ទំនងរវាងកម្ពុជា និងកូរ៉េ មានការរីកចម្រើនគួរឲ្យកត់សម្គាល់លើវិស័យជាច្រើនដូចជា វិស័យព័ត៌មានវិទ្យា ទេសចរណ៍ និងវិស័យជាច្រើន។ លោក ហ្ស៊ីម បូយ្យុន បានមានប្រសាសន៍ថា នៅក្នុងសហគមន៍អន្តរជាតិប្រទេសកូរ៉េធ្លាប់គាំទ្រយ៉ាងសកម្មឲ្យកម្ពុជាចូលជាសមាជិកយូណេស្កូ។ លើសពីនេះ ថ្នាក់ដឹកនាំទាំង២ កំពុងតែកសាងចំណងមិត្តភាពទៅវិញទៅមកដោយមានឱកាសជាច្រើនក្នុងកិច្ចប្រជុំអាស៊ានបូក៣ និងកិច្ចប្រជុំអាស៊ាន-កូរ៉េ ផងដែរ៕ អត្ថបទ៖ សោភា

## ផ្តន្ទាទោសដាក់គុកជិត៥០០ឆ្នាំ ពាក់ព័ន្ធបទល្មើសជួញដូរផ្លូវភេទ

http://www.yobminh.com/ November 25, 2017

អ្នកទោសជួញដូរផ្លូវភេទកុមារពីរដ្ឋ Colorado សហរដ្ឋអាមេរិកត្រូវបានកាត់ទោសឱ្យជាប់គុក ៤៧២ ឆ្នាំកាលពីដែលជាការកាត់ទោសរយៈពេលវែងបំផុតសម្រាប់ករណីជួញដូរមនុស្សនៅក្នុងប្រវត្តិសាស្ត្ររបស់សហរដ្ឋអាមេរិក។ Brock Franklin អាយុ ៣១ ឆ្នាំ ត្រូវបានគេចាត់ទុកថាជាមេដឹកនាំនៃការជួញដូរមនុស្ស ហើយត្រូវគេរកឃើញថាមានពិរុទ្ធភាពពីបទចោទប្រកាន់ចំនួន ៣០ ករណីក្នុង ចំណោម ៣៤ ករណីប្រឆាំងនឹងរូបលោក កាលពីខែមីនា ក្នុងនោះរួមទាំងការឃាត់ខ្លួនពេស្យាចារកុមារ ការ ចាប់រំលោភផ្លូវភេទនិងចាប់ជំរិត ។

ទូរទស្សន៍ KDVR ក្នុងស្រុក បានរាយការណ៍ថា ការចោទប្រកាន់បានបង្ហាញថាប្រៀងគិន បានជ្រើសរើសក្មេងស្រីនិងស្ត្រីក្មេងៗ ហើយបង្ខំពួកគេឱ្យធ្វើពេស្យាចារ ។ មានការរំលោភបំពានលើរាងកាយប្រសិនបើពួកគេមិនសហការដើម្បីលក់សេវាកម្មរបស់ពួកគេតាមអ៊ីនធឺណិត។

មេធាវីការពារក្ដីបានស្នើសុំឱ្យមានការកាត់ទោសអប្បបរមា 96 ឆ្នាំដល់លោកហ្វ្រែងគ្លីន ប៉ុន្ដែចៅក្រមបានបញ្ជូនគាត់ទៅរយៈពេល ៣៧៦ ឆ្នាំទៀ តបតាមសំណើរបស់ជនរងគ្រោះ។ ក្មេងស្រី ០៣នាក់និងស្ត្រី ០៥នាក់បានសហការជាមួយព្រះរាជអាជ្ញាក្នុងករណីនេះ។

យោងតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក Janet Drake តំណាងឱ្យការិយាល័យអគ្គមេបញ្ជាការនៃរដ្ឋ Colorado បាននិយាយថាការកាត់ទោសរយៈពេល ៤០០ ឆ្នាំ ជាការបញ្ជូនសារដ៏ខ្លាំងក្លាមួយនៅទូទាំងប្រទេសថា យើងនឹងមិនអត់ឱនចំពោះអំពើហិង្សាបែបនេះចំពោះស្ត្រីនិង ប្រជាជនងាយរងគ្រោះ ” ៕

## ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧

## សូមអបអរសាទរ! យុវតីកម្ពុជាជាប់ជ័យលាភីលេខ១ ក្នុងការប្រកួតប្រជែងវីដេអូ ស្តីពីការប្រឆាំងការជួញដូរមនុស្ស ក្នុងក្របខ័ណ្ឌអាស៊ាន

http://www.freshnewsasia.com/ 2017-11-29

**(ភ្នំពេញ)៖** វីដេអូភាគខ្លីរបស់យុវតីវ័យក្មេងកម្ពុជាម្នាក់ បានទទួលជ័យលាភីលេខ១ ក្នុងការប្រកួតប្រជែងក្របខ័ណ្ឌ១០ប្រទេស ក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ ក្រោមប្រធានបទ «អាស៊ានប្រឆាំងការជួញដូរមនុស្ស មិនមែនសម្រាប់លក់»។ ការទទួលបានជ័យលាភីលេខ១នេះ ត្រូវបានប្រកាស នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងបូហូល ប្រទេសហ្វីលីពីន។

ពិធីអបអរសាទរស្នាដៃវីដេអូខ្លីរបស់យុវតីកម្ពុជា ដែលទទួលបានជ័យលាភីនេះនៅកម្ពុជា ត្រូវបានធ្វើឡើងនៅសាកលវិទ្យាល័យភ្នំពេញ នាព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ ដោយមានការចូលរួមពីសំណាក់ លោក កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងសិស្សនិស្សិតចូលរួម យ៉ាងច្រើនកុះករផងដែរ។ កម្មវិធីមាននេះមានគោលបំណងលើកស្ទួយស្នាដៃរបស់យុវជនខ្មែរជំនាន់ក្រោយ ដែលមានទទួលជ័យលាភីថ្នាក់លេខ១ក្នុងតំបន់អាស៊ានក្នុងការប្រកួតវីដេអូខ្លី។ ជាពិសេសមានគោលបំណងលើកកម្ពស់ស្នាដៃយុវជន អំពីកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការប្រយុទ្ធប្រឆាំការជួញដូរមនុស្ស ដែលអនុលោមតាមសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន និងអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

វីដេអូរបស់កម្ពុជា ដែលមានចំណងជើងថា «សុបិនអាក្រក់» បានទទួលជ័យលាភីលេខ១ នេះជាស្នាដៃរបស់កញ្ញា ឈន សុខលីន និងក្រុមការងារ។ សុបិនអាក្រក់ គូសបញ្ជាក់ពីការបញ្ជ្រាបការយល់ដឹងពីការជួញដូរមនុស្ស កិច្ចខិតខំនិងការប្តេជ្ញារបស់កម្ពុជា ក៏ដូចជាអាស៊ានក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស និងការលើកទឹកចិត្តដល់ជនរងគ្រោះមានការតស៊ូ និងជីវិតឡើងវិញ៕

## ២ឆ្នាំកន្លងទៅ បទល្មើសឆ្លងដែន ខុសច្បាប់គ្រប់ប្រភេទ តាមព្រំដែនកម្ពុជា និងវៀតណាម បង្ក្រាបបាន៣៧ករណី

http://www.cen.com.kh/archives/ November 29, 2017

ភ្នំពេញ ៖ អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនវៀតណាម បានឯកភាពខ្ពស់លើបណ្តាវិធានការដែលបានលើកឡើងនានា និងឯកភាព បន្តចុះហត្ថលេខា លើកំណត់ហេតុធ្វើការងារ ដើម្បីអនុវត្តនាឆ្នាំ២០១៨ ខាងមុខ ពិសេសលើករណីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ និង

អំពើភេរវកម្ម ខណៈក្នុងអំឡុង ២ឆ្នាំកន្លងទៅនេះ បទល្មើសកើតឡើងតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម មានចំនួន ៣៩ករណី បង្ក្រាបបានចំនួន ៣៧ករណី ចាប់ខ្លួនជនសង្ស័យសរុបចំនួន ៤៩នាក់។

នាល្ងាចថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការការពារសន្តិសុខព្រំដែនកម្ពុជា-វៀតណាម ក្រោមអធិបតីភាពលោក នាយឧត្តមសេនីយ៍ ជាំ វុទ្ធី អគ្គស្នងការរងនគរបាលជាតិ និងលោក ឧត្តមសេនីយ៍ទោ ហ័ង សួនចៀន មេបញ្ជាការកងទ័ពការពារព្រំដែនវៀតណាម ។ លោកឧត្តមសេនីយ៍ទោ ហ័ង សួនចៀន មេបញ្ជាការកងទ័ពការពារព្រំដែនវៀតណាម បានមានប្រសាសន៍ថា កន្លងមកអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា បានសហការគ្នាល្អលើកិច្ចការពារសន្តិសុខតាមបន្ទាត់ព្រំដែននៃប្រទេសទាំងពីរ ជាពិសេសបានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋទាំងសង្ខាងក្នុងការផ្លាស់ប្តូរទំនិញពាណិជ្ជកម្ម ដែលធ្វើឲ្យប្រជាពលរដ្ឋមានជីវភាពធូរជាប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ លោក ឧត្តមសេនីយ៍ទោ ហ័ង សួនចៀន ក៏បានសំណូមពរដល់អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា បន្តកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបន្ទាត់ព្រំដែននៃប្រទេសទាំងពីរឲ្យបានល្អថែមទៀត ពិសេសទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ និងអំពើភេរវកម្ម ។

ក្នុងឱកាសនោះដែរ លោក នាយឧត្តមសេនីយ៍ ជាំ វុទ្ធី អគ្គស្នងការរងនគរបាលជាតិ មានប្រសាសន៍ថា អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា នៅតែបន្តបង្កើនកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបន្ទាត់ព្រំដែនជាមួយបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនវៀតណាម ឲ្យកាន់តែល្អថែមទៀត ដើម្បីឲ្យព្រំដែននៃប្រទេសទាំងពីររក្សាបាននូវសាមគ្គីភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ។ លោកបញ្ជាក់ប្រាប់ភាគីវៀតណាមបន្តថា "អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា នឹងរួមសហការគ្នាក្នុងការទប់ស្កាត់បទឧក្រិដ្ឋឆ្លងដែន ដូចជាការជួញដូរ និងចរាចរណ៍គ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បទល្មើសព្រហ្មទណ្ឌ បទល្មើសសេដ្ឋកិច្ច ការលួចជ្រៀតចូលឆ្លងដែនខុសច្បាប់ ដែលសកម្មភាពទាំងអស់នេះ នៅតែបន្តកើតឡើងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គមក៏ដូចជានៅតាមតំបន់ព្រំដែននៃប្រទេសទាំងពីរផងដែរ" ។

ក្នុងឱកាសនេះដែរ លោក នាយឧត្តមសេនីយ៍ ជាំ វុទ្ធី ក៏បានស្នើសុំភាគីវៀតណាមយោគយល់ចំពោះការខកខានប្រជុំកាលពីឆ្នាំ២០១៦ ហើយត្រូវពន្យារពេលរហូតមកដល់ពេលនេះ គឺអាស្រ័យដោយសារពេលនោះកម្ពុជាមានការមមាញឹកក្នុងការត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ដែលកិច្ចការទាំងនោះតម្រូវឲ្យកងកម្លាំងរបស់យើងត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សំដៅធានាឲ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសុវត្ថិភាព ។ ជាការពិតណាស់រយៈពេល ២ឆ្នាំកន្លងទៅ សន្តិភាពនៅតាមតំបន់ព្រំដែន នៃប្រទេសទាំងពីរបាននិងកំពុងបន្តនិរន្តរភាព ក្រោមបរិយាកាសដ៏ល្អប្រសើរ ដោយធានាបាននូវស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ ដែលសមិទ្ធិផលដ៏ថ្លៃថ្លា គឺជាសក្ខីភាពឆ្លុះបញ្ចាំងអំពីភាពរីកចម្រើនឥតឈប់ឈរ និងកាន់តែរឹងមាំជាលំដាប់នៃចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងការពារព្រំដែន នៃប្រទេសទាំងពីរ ។

សូមជម្រាបថា ក្នុងអំឡុង ២ឆ្នាំកន្លងទៅនេះ បទល្មើសកើតឡើងតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម មានចំនួន ៣៩ករណី បង្ក្រាបបានចំនួន ៣៧ករណី ចាប់ខ្លួនជនសង្ស័យសរុបចំនួន ៤៩នាក់ (ជនជាតិខ្មែរ ៩នាក់ និងជនជាតិវៀតណាម ៤០នាក់) និងនៅសល់ ២ករណីទៀតកំពុងស្រាវជ្រាវ គឺករណីចោរកម្ម លួចម៉ូតូរបស់ពលរដ្ឋខ្មែរ និងលួចទូកពីវៀតណាមមកខ្មែរ ៕ ដោយៈបញ្ញាស័ក្តិ

## ក្មេងស្រីជនភៀសខ្លួនរ៉ូហ៊ីងយ៉ា ត្រូវបានគេបង្ខំឲ្យបម្រើ សេវាកម្មផ្លូវភេទ នៅបង់ក្លាដេស

https://www.dap-news.com/kh/ អង្គារ, ២៨ វិច្ឆិកា ២០១៧ 22:04 ដោយ: ម៉ៅ បុប្ផាមករា ID:030

BBC៖ ទូរទស្សន៍ BBC បានផ្សព្វផ្សាយព័ត៌មាន ឲ្យដឹងនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ថា ក្មេងស្រីដែលជាជនភៀសខ្លួនជនជាតិរ៉ូហ៊ីងយ៉ា ត្រូវបានគេដឹងថា មានក្រុមអ្នកជួញដូរ មនុស្សបានបង្ខំឲ្យក្មេងស្រីលក់ខ្លួនដើម្បីបម្រើសេវាកម្មផ្លូវភេទ នៅក្នុងប្រទេសបង់ក្លាដេស ។ នៅក្នុងខ្សែវីដេអូខ្លីមួយបានបង្ហាញថា ក្មេងស្រីម្នាក់ដែលមានអាយុ១៧ឆ្នាំជាជនជាតិរ៉ូហ៊ីងយ៉ា ត្រូវបានគេនាំទៅស្នាក់នៅក្នុងសណ្ឋាគារមួយ និងផ្តល់អាហារហូបចុក រួចបង្ខំឲ្យរូបនាងរួមភេទជាមួយបុរសៗ នៅក្នុងប្រទេសបង់ក្លាដេស ។

ក្មេងស្រីដែលជាជនរងគ្រោះបានរៀបរាប់អំពីទុក្ខលំបាកថា នាងត្រូវបានធ្វើទារុណកម្មលើខ្លួន បើសិនជាមិនធ្វើតាមការបញ្ជារបស់ពួកគេទេនោះ ។ ករណីនេះមិនទាន់មានការស៊ើបអង្កេតពីក្រុមសមត្ថកិច្ចច្បាស់លាស់នៅឡើយទេ តែតាមរយៈខ្សែវីដេអូរបស់ទូរទស្សន៍ BBC ដែលបានថតពីសកម្មភាព និងការរៀបរាប់របស់ជនរងគ្រោះតែប៉ុណ្ណោះ ហើយភស្តុតាងជាក់លាក់មិនទាន់បានទម្លាយច្បាស់នោះទេ ៕

## បារាំងស្នើឲ្យក្រុមប្រឹក្សាសន្តិសុខប្រជុំដោះស្រាយបញ្ហាជួញដូរមនុស្សជាទាសករនៅលីប៊ី

https://www.thmeythmey.com/ 28, Nov 2017 , 8:39 pm ដោយ: សៅ ផលនិស្ស័យ

បារាំងស្នើឲ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជួបប្រជុំពិភាក្សាគ្នាពីបញ្ហាជួញដូរពលករនៅលីប៊ី និងបង្ខំឲ្យពួកគេធ្វើជាទាសករផងនោះ ។ បារាំងស្នើទៅក្រុមប្រឹក្សានេះបន្ទាប់ពីមានព័ត៌មាន ពាក់ព័ន្ធការជួញដូរជនអន្តោប្រវេសន៍ដូចសត្វធាតុនៅក្នុងប្រទេសលីប៊ី។ ក្រោយមានការបញ្ចេញរបាយការណ៍ស្តីការជួញដូរមនុស្សនៅលីប៊ី បណ្តាប្រទេសនានាជាពិសេសប្រទេសមហាអំណាច បានស្នើឲ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិកោះប្រជុំដើម្បីដាក់ចេញចំណាត់ការមួយ។ បើតាមទីភ្នាក់ងារព័ត៌មាន Xinhua នៅថ្ងៃចន្ទបារាំង បានស្នើឲ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបើកកិច្ចប្រជុំមួយដើម្បីពិភាក្សាពីបញ្ហាជួញដូរមនុស្ស និងទាសភាពនៅលីប៊ីនេះនៅថ្ងៃពុធទី ២៩ ខែវិច្ឆិកានេះ។

ឯកអគ្គរដ្ឋទូតបារាំងប្រចាំអង្គការសហប្រជាជាតិ Francois Delattre ដែលជាអ្នកស្នើឲ្យមានកិច្ចប្រជុំនេះ បានប្រាប់អ្នកសារព័ត៌មាននៅថ្ងៃចន្ទកន្លងទៅថា គោលដៅចម្បងនៃកិច្ចប្រជុំនេះគឺបង្ហាញឲ្យគ្រប់គ្នាដឹងពីសោនាដកម្មដែលកើតឡើង និងដើម្បីបង្ហាញជំហររួមរបស់ក្រុមប្រឹក្សាក្នុងការប្រឆាំងរាល់ការជួញដូរមនុស្សធ្វើជាទាសករនៅសម័យកាលបច្ចុប្បន្ននេះ។ «យើងត្រូវស្វែងរកជំហររឹងមាំមួយដោយនិយាយថា ទេ ចំពោះរាល់ស្ថានភាពមិនអាចទទួលយកបាន។ ប៉ុន្តែយើងត្រូវស្វែងរកដំណោះស្រាយរយៈពេលខ្លី និងរយៈពេលវែងដើម្បីបញ្ចប់បញ្ហានេះ»។ នេះជាការលើកឡើងរបស់តំណាងបារាំងប្រចាំអង្គការសហប្រជាជាតិ។ បើតាមបេសកជនរូបនេះ បារាំងក៏នឹងបន្តសហការជាមួយសមាជិកក្រុមប្រឹក្សាសន្តិសុខដើម្បីធានាថា ដំណោះស្រាយចំពោះបញ្ហានេះនឹងមានប្រសិទ្ធភាពខ្ពស់ផងដែរ។ ពាក់ព័ន្ធការរៀបចំកិច្ចប្រជុំនេះ ប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ Sebastiano Cardi បានលើកឡើងថា កិច្ចប្រជុំនេះនឹងក្លាយជាកិច្ចប្រជុំសំខាន់មួយដើម្បីដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ន។

ក្រៅពីមានការពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបញ្ហាជួញដូរមនុស្ស និងទាសភាពនេះនឹងត្រូវយកទៅពិភាក្សាក្នុងកិច្ចប្រជុំកំពូលអឺរ៉ុបអាហ្វ្រិកដែលរៀបចំឡើងនៅថ្ងៃពុធ ដល់ថ្ងៃព្រហស្បតិ៍ នៅទីក្រុង Abidjan ប្រទេសកូឌីវ័រ។ កាលពីសប្តាហ៍មុនអគ្គលេខាធិការអង្គការសហប្រជាជាតិលោក Antonio

Guterres បានចេញមុខប្រតិកម្ម និងបង្ហាញក្ដីបារម្ភចំពោះការជួញដូរមនុស្សឲ្យធ្វើជាទាសករនៅក្នុងប្រទេសលីប៊ីផងដែរ។ លោកក៏បានស្នើឲ្យបណ្ដាភាគីពាក់ព័ន្ធដាក់ចំណាត់ការដោះស្រាយបញ្ហាប្រឈមនេះផងដែរ។

សូមបញ្ជាក់ថា ប្រជាជនលើពិភពលោកតក់ស្លុត និងខឹងសម្បារខ្លាំង ក្រោយបានឃើញរបាយការណ៍ពាក់ព័ន្ធការជួញដូរជនទេសន្តប្រវេសន៍នៅក្នុងប្រទេសលីប៊ីរបស់អង្គការអន្តរជាតិទេសន្តប្រវេសន៍។ ក្រៅពីរបាយការណ៍នេះ គេក៏ឃើញមានការចុះផ្សាយនិងខ្សែអាត់វីដេអូស្ដីពីការដេញថ្លៃទាសករនៅលីប៊ី ក្នុងសារព័ត៌មាន CNN ផងដែរកន្លងមក៕

## ប្រមុខ UN ព្រួយបារម្ភខ្លាំង ក្រោយទទួលរបាយការណ៍ពីការជួញដូរពលករអាហ្វ្រិកដូចទាសករ

https://www.thmeythmey.com/ 26, Nov 2017 , 9:19 pm ដោយ: ឌី ណារី

ប្រមុខអង្គការសហប្រជាជាតិ លោក António Guterres បានសម្ដែងការតក់ស្លុតខ្លាំង ក្រោយទទួលបានរបាយការណ៍ និងវីដេអូស្ដីពីការជួញដូរពលករអាហ្វ្រិកដូចទាសករនៅក្នុងប្រទេសលីប៊ី។ ប្រមុខស្ថាប័នអន្តរជាតិរូបនេះ ក៏បានទទូចឲ្យអាជ្ញាធរពាក់ព័ន្ធចាត់វិធានបន្ទាន់ដើម្បីស៊ើបអង្កេតពីស្ថានភាពជាក់ស្ដែង និងនាំជនល្មើសមកកាត់ទោស ។ «ទាសភាព មិនត្រូវឲ្យមានទៀតឡើយនៅក្នុងពិភពលោករបស់យើង ហើយអំពើទាំងនេះ គឺជាការបំពានសិទ្ធិមនុស្សមួយដ៏ធ្ងន់ធ្ងរបំផុត និងថែមទាំងអាចចាត់ទុកជាបទល្មើសប្រឆាំងមនុស្សជាតិទៀតផង»។ នេះគឺជាសេចក្ដីថ្លែងការណ៍របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ Guterres ប្រតិកម្មទៅនឹងរបាយការណ៍ជួញដូរពលករនៅលីប៊ី ក្នុងសន្និសីទសារព័ត៌មាននៅដើមសប្ដាហ៍នេះ ។

លោកអគ្គលេខាធិការ ដែលធ្លាប់បម្រើការក្នុងវិស័យសិទ្ធិមនុស្សជាច្រើនឆ្នាំហើយនោះ បានបន្តទៀតថា លោក បានស្នើឲ្យតួអង្គពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិបន្តការងារជាបន្ទាន់ និងសកម្មបំផុតលើបញ្ហានេះ ។ ជាមួយគ្នានេះ ប្រមុខអង្គការសហប្រជាជាតិរូបនេះ ក៏បានទទូចឲ្យប្រទេសទាំងអស់អនុវត្តឲ្យបានខ្ជាប់ខ្ជួននូវអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីបទល្មើសឆ្លងប្រទេសដោយមានការរៀបចំ និងពិធីសារបន្ថែមស្ដីពីការជួញដូរមនុស្ស ។ លោកថែមទាំងបានទទូចសហគមន៍អន្តរជាតិរួមដៃគ្នាប្រយុទ្ធប្រឆាំងនឹងអំពើឃោរឃៅនេះផងដែរ ។

យោងតាមវីដេអូ ដែលចុះផ្សាយដោយសារព័ត៌មាន CNN វាមានការដេញថ្លៃលើបុរសជាច្រើននាក់ពីនៅលីប៊ី ដើម្បីយកពួកគេទៅធ្វើការជាកម្មករនៅកសិដ្ឋានក្នុងតម្លៃ៤០០ ដុល្លារ ហើយវីដេអូនេះក៏បានធ្វើឲ្យសាធារណជន និងសហគមន៍អន្តរជាតិផ្ទុះកំហឹង និងថ្កោលទោសខ្លាំងដែរ ។ យ៉ាងណាក៏ដោយ ជុំវិញបញ្ហានេះ រដ្ឋាភិបាលលីប៊ី ក៏បានអះអាងដែរថា លីប៊ីកំពុងតែបើកការស៊ើបអង្កេត និងរង់ចាំលទ្ធផលដើម្បីនាំយកជនល្មើសមកកាន់ទោសតាមផ្លូវច្បាប់ ៕

## ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

## អនុសាសន៍ ៥ចំណុច របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់បងប្អូនពលករដែល កំពុងធ្វើការនៅក្រៅប្រទេស ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok November 28 at 2:08pm ·

ទី១. រាជរដ្ឋាភិបាលបានអនុវត្តសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការការពារ និងលើកកម្ពស់ សិទ្ធិពលករទេសន្តប្រវេសន៍ បាននឹងកំពុងខិតខំជួយពលករ ដែលធ្វើការនៅបរទេស ដើម្បីធានា បាននូវផលប្រយោជន៍ស្របច្បាប់ ជួយផ្ដល់ភាពស្របច្បាប់ដល់ពលករដែលមិនទាន់ស្របច្បាប់។

ទី២. រាជរដ្ឋាភិបាលសហការជាមួយប្រទេសជាដៃគូទទួលស្គាល់ជំនាញទៅវិញទៅមក ដូចជា កម្ពុជា ថៃ បានទទួលស្គាល់ជំនាញផ្នែកសំណង់ ជាងកំបោរ និងបណ្ដាញអគ្គីសនី។

ទី៣. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្ដាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យរបបសន្តិសុខសង្គម ។ ពលករស្របច្បាប់នៅគ្រប់ប្រទេសនៅពេលមានគ្រោះថ្នាក់ដល់ ជីវិត ទទួលបានសំណងតាមច្បាប់។ ពលករទាំងអស់អាចផ្ទេរប្រាក់ជានារ៉ាប់រងសង្គម គ្រោះថ្នាក់ការងារ និងប្រាក់ជានារ៉ាប់រងសុខភាពមកក្រុមគ្រួសារពលករនៅស្រុកកំណើត។

ទី៤. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្ដាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធន៍និវត្ត ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់វិភាគទាន បេឡាសន្តិសុខសង្គមពីប្រទេសមួយ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានគិតប្រាក់សោធននិវត្តន៍ ហើយផលប្រយោជន៍ទាំងនោះពលករនឹងទទួលបាននៅឆ្នាំ២០១៩។

ទី៥. រាជរដ្ឋាភិបាលកំពុងសម្រួលបែបបទជូនពលករនៅបរទេស អាចផ្ទេរសិទ្ធិជូនគ្រួសារ នៅក្នុងប្រទេសធ្វើជាតំណាង ដើម្បីស្នើសុំលិខិតថ្កោលទោស លិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន ដោយពុំចាំបាច់ឲ្យសាមីខ្លួនវិលត្រលប់មកស្រុកកំណើតវិញ។ ដោយឡែកសម្រាប់ពលករធ្វើការនៅប្រទេសថៃត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាម ច្បាប់ដើម ដើម្បីបំពេញបែបបទស្របច្បាប់។

**លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី ចំនួន ១.០១៧ នាក់ ដែលកំពុងធ្វើការនៅរោងចក្រផលិតសាច់មាន់ Centaco group នៅខេត្តផាថុមថានី ប្រទេសថៃ**

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok November 26 at 8:11pm •

លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អមដោយគណៈប្រតិភូមកពីកម្ពុជា ព្រមទាំងទីប្រឹក្សានយោបាយ និងទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ បានជួបសំណេះសំណាលជាមួយកម្មករ កម្មការិនី ចំនួន ១.០១៧ នាក់ ដែលកំពុងធ្វើការនៅរោងចក្រផលិតសាច់មាន់ Centaco group នៅខេត្តផាថុមថានី ប្រទេសថៃ។

ថ្លែងក្នុងឱកាសនោះ លោកជំទាវក៏បានពាំនាំនូវការផ្ដាំផ្ញើរ និងសាកសួរសុខទុក្ខពីសំណាក់ ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងបានផ្តល់កម្លាំងចិត្តឲ្យកម្មករពលករខ្មែរទាំងអស់ប្រឹងប្រែងធ្វើការងារ កាន់តែសកម្មថែមទៀតដើម្បីទទួលបានប្រាក់ខែខ្ពស់និងទទួលការពេញចិត្តពីថៅកែរោងចក្រ។ ការមកជួបសំណេះសំណាលនេះ ពិតជាគួសបញ្ជាក់ពីការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្ដេចតេជោ ហ៊ុន សែន ជាប្រមុខដែលជានិច្ចកាលតែងតែ មានមនោសញ្ចេតនាជិតស្និទ្ធជាមួយប្រជាជន និងជាមួយពលករ ។ ជាក់ស្ដែង ដូចជាពេលនេះ ទោះជាបងប្អូនមកធ្វើការនៅប្រទេសថៃ ឆ្ងាយពីស្រុកកំណើតក្ដី ក៏សម្ដេចនៅតែគិតគូរ និងបានចាត់តាំងខ្ញុំ និងឯកឧត្តមមួយចំនួនទៀត ដូចជា ឯកឧត្តមអ៊ិត សំហេង ឯកឧត្តម ហ៊ុន ម៉ានី ឯកឧត្តម ហ៊ុន ម៉ាណែត និងឯកឧត្តម ព្រុំ សុខា ជាតំណាងមកជួបសំណេះសំណាលជាមួយប្អូនៗ ដើម្បីសាកសួរសុខទុក្ខ និងចែករំលែកព័ត៌មាន និងជួយដោះស្រាយបញ្ហាផ្សេងៗដែលប្អូនៗជួបប្រទះ។

បច្ចុប្បន្នរាជរដ្ឋាភិបាលបានផ្តល់លិខិតឆ្លងដែនជូនពលករយើង នៅប្រទេសថៃតែម្ដង ដោយមិនចាំបាច់ធ្វើដំណើរត្រឡប់ទៅកម្ពុជា និងបានរៀបចំគណៈកម្មាការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ ដើម្បីដោះស្រាយការលំបាកនានា ជាពិសេសជួយសម្រួលឱ្យប្អូនៗពលករយើងរស់នៅនិងធ្វើការដោយស្របច្បាប់ និងដោយមានកិត្តិយស រួចផុតពីការរំលោភ ជិះជាន់ កេងប្រវ័ញ្ច និងហានិភ័យផ្សេងៗ។ ឆ្លៀតក្នុងឱកាសនោះផងដែរលោកជំទាវក៏បានពាំនាំនូវអនុសាសន៍ ៥ចំណុច របស់សម្ដេចអគ្គមហាសេនាបីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជូនដល់បងប្អូនពលករដែល កំពុងធ្វើការនៅក្រៅប្រទេសនេះផងដែរ ៖

ទី១. រាជរដ្ឋាភិបាលបានអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងលើកកម្ពស់ សិទ្ធិពលករទេសន្តប្រវេសន៍ បាននឹងកំពុងខិតខំជួយពលករ ដែលធ្វើការនៅបរទេស ដើម្បីជានា បាននូវផលប្រយោជន៍ស្របច្បាប់ ជួយផ្តល់ភាពស្របច្បាប់ដល់ពលករដែលមិនទាន់ស្របច្បាប់។

ទី២. រាជរដ្ឋាភិបាលសហការជាមួយប្រទេសជាដៃគូរទទួលស្គាល់ជំនាញទៅវិញទៅមក ដូចជា កម្ពុជា ថៃ បានទទួលស្គាល់ជំនាញផ្នែកសំណង់ ជាងកំបោរ និងបណ្តាញអគ្គិសនី។

ទី៣. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យរបបសន្តិសុខសង្គម ។ ពលករស្របច្បាប់នៅគ្រប់ប្រទេសនៅពេលមានគ្រោះថ្នាក់ដល់ ជីវិត ទទួលបានសំណងតាមច្បាប់។ ពលករទាំងអស់អាចផ្ទេរប្រាក់ជានារ៉ាប់រងសង្គម គ្រោះថ្នាក់ការងារ និងប្រាក់ជានារ៉ាប់រងសុខភាពមកក្រុមគ្រួសារពលករនៅស្រុកកំណើត។

ទី៤. រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធន៍និវត្ត ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់វិភាគទាន បេឡាសន្តិសុខសង្គមពីប្រទេសមួយ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានគិតប្រាក់សោធននិវត្តន៍ ហើយផលប្រយោជន៍ទាំងនោះពលករនឹងទទួលបាននៅឆ្នាំ២០១៩។

ទី៥. រាជរដ្ឋាភិបាលកំពុងសម្រួលបែបបទជូនពលករនៅបរទេស អាចផ្ទេរសិទ្ធិជូនគ្រួសារ នៅក្នុងប្រទេសធ្វើជាតំណាង ដើម្បីស្នើសុំលិខិតថ្កោលទោស លិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន ដោយពុំចាំបាច់ឲ្យសាមីខ្លួនវិលត្រលប់មកស្រុកកំណើតវិញ។ ដោយឡែកសម្រាប់ពលករធ្វើការនៅប្រទសថៃត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាម ច្បាប់ដើម ដើម្បីបំពេញបែបបទស្របច្បាប់។

ជាទីបញ្ចប់លោកជំទាវបានផ្តាំផ្ញើរដូចតទៅ: សូមប្អូនៗដែលជាលករខ្មែរ រស់នៅ ធ្វើការងារ ត្រូវគោរពច្បាប់ប្រទេសថៃ។ ដាច់ខាតមិនត្រូវប្រព្រឹត្តិបទល្មើស ដូចជាអំពើហឹង្សា គ្រឿងញៀនជា ។ ល។ ហើយកុំជឿតាមការញ៉ោះញ៉ង់របស់គណបក្សប្រឆាំងដែលមានបំណង បំផ្លាញសន្តិភាព និងរារាំងដល់ការអវឌ្ឍនប្រទេស។ ចំណែកឯថៅកែក្រុមហ៊ុន សូមបន្តទទួលពលករខ្មែរបន្ថែមទៀត និងសូមអាណិតស្រឡាញ់ពលករខ្មែរដូចពលករថៃ និងស្ថានទូតស្ថានអគ្គកុងស៊ុលកម្ពុជា សូមបន្តការយកចិត្តទុកដាក់តាមដាន និងជួយដោះស្រាយរាល់បញ្ហានានារបស់ពលករខ្មែរស្របតាមច្បាប់អន្តរជាតិ ច្បាប់ប្រទេសថៃ និងស្មារតីនៃ MOU ដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានចុះហត្ថលេខា៕

## ភាពយន្តឯកសារស្តីពីបញ្ហា ចំណាកស្រុក និងការតស៊ូ ៨រឿងនឹងត្រូវចាក់បញ្ចាំង នៅថ្ងៃទី១ ធ្នូ

https://www.dap-news.com/kh/ ព្រហស្បតិ៍, ៣០ វិច្ឆិកា ២០១៧ 11:15 ដោយ: ដើមអម្ពិល ID:049

**ភ្នំពេញ៖**ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (DMC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រុមនិស្សិតផ្នែក គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ជំនាន់ទី១៤ នឹងសម្ពោធចាក់បញ្ចាំង កម្រងវីដេអូឯកសារខ្លី នៃគម្រោង៣ (Project Three) ចំនួន៨រឿង ដែល ផ្តោតទៅលើ ជីវិតតស៊ូនិងក្តីសង្ឃឹមរបស់បុគ្គល មានទេពកោសល្យ តំបន់ទេសចរណ៍ ដែលមិនសូវទទួលបាន ការផ្តោត អារម្មណ៍ បញ្ហាចំណាកស្រុក និងការចងចាំរបស់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃសុក្រ ទី ១ ខែធ្នូ ឆ្នាំ ២០១៧ ខាងមុខនេះក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចាប់ពីវេលាម៉ោង ១៧:៣០ ល្ងាចតទៅ ។

ក្រោមការឧបត្ថម្ភពីទីភ្នាក់ងារ អភិវឌ្ឍអាល្លឺម៉ង់(GIZ)និងសេវាកម្មស៊ីវិល សន្តិភាពអ៊ឺរ៉ុប(ZFD) ភាពយន្តឯកសារខ្លីចំនួន៨ ត្រូវបានផលិតឡើង ដោយក្រុមនិស្សិតឆ្នាំទី៣ នៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគម

ន៍។វីដេអូឯកសារខ្លីទាំងនេះ មានសក្តានុពលក្នុងការរំលេចសារ ដែលភ្ជាប់មកនូវជាមួយដំណោះស្រាយ ទៅនឹងបញ្ហាដែលកើតមានក្នុងពេល បរិបទសង្គម កម្ពុជាមានការប្រែប្រួល ដ៏ឆាប់រហ័ស។

ក្រុមនិស្សិតជាផលិតករខ្សែភាពយន្ត ខ្លីទាំង៨នេះ សង្ឃឹមយ៉ាងមុតមាំថា ខ្សែភាពយន្តឯកសារខ្លីទាំង៨រឿងនេះ នឹងចូលរួម ជាផ្នែកមួយ ក្នុងការចង្អុលបង្ហាញនូវសំណុំរឿងដែលមិនសូវទទួលបានការអើពើ និងបោះជំហានទៅរកដំណោះស្រាយ ដ៏សមស្របដើម្បីការវិវឌ្ឍទៅមុខ ប្រកបដោយភាពសុខ ដុមរមនានៃកម្ពុជា។

## ពលករខ្មែរជាង៨០នាក់ ត្រូវតម្រួតថៃចាប់ឃាត់ខ្លួន ខណៈកំពុងកាប់ឈើគ្រញូង

http://www.arey-news.com/archives/ (ថ្ងៃទី 30 November 2017 ម៉ោង 8:30 am)

**ថៃ:** យោងតាមការផ្សាយរបស់ស្ថានីយទូរទស្សន៍ប៉ុស្តិ៍លេខ៨ថៃ បានឲ្យដឹងថា កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ មានការស្ទាក់ចាប់ពលករខ្មែរ ដែលបានលបលួចចូលទៅកាប់ឈើគ្រញូងក្នុងតំបន់ឧទ្យានជាតិ ថាប់ឡានស្ថិតនៅចំណុចណងបូស ក្នុងភូមិ២០ ឃុំគូសក្រាក់ឆាយ ស្រុកខនបុរី ខេត្តនគររាជសីមា ប្រទេសថៃ។

ពលករខ្មែរជាច្រើននាក់ ត្រូវបានក្រុមតម្រួតថៃ សហការជាមួយនឹងកម្លាំងជំនាញធ្វើការឡោមព័ទ្ធចាប់ខ្លួនបានជាបន្តបន្ទាប់ ខណៈពួកគេប្រមាណជាង១០០នាក់ ត្រូវបានមេក្លោងខ្មែរ ថៃ ដឹកនាំឆ្លងដែរ និងលបលួចចូលទៅកាន់ឈើគ្រញូងក្នុងតំបន់ហាមឃាត់។ សមត្ថកិច្ចថៃបានធ្វើការ ឃាត់ខ្លួនជនជាតិខ្មែរបានចំនួន៣៩នាក់ ព្រមទាំងបានដកហូតឈើគ្រញូងជាច្រើនដុំផងដែរ ដោយវត្ថុតាងទាំងនេះ ត្រូវបានបញ្ជូនទៅកាន់អង្គភាពជំនាញ នៃខេត្តស្រះកែវ ប្រទេសថៃ ហើយកម្លាំងចម្រុះថៃ ដែលមានតម្រួត រដ្ឋបាលព្រៃឈើ នឹងក្រុមអភិរក្សព្រៃឈើក្នុងតំបន់ឧទ្យានជាតិ។ លុះនៅយប់ថ្ងៃទី២៨ ខែឆ្នាំដដែល កម្លាំងចម្រុះថៃ បានធ្វើការរុករក និងឈានដល់ការចាប់ខ្លួនជនជាតិខ្មែរ និងថៃបន្ថែមទៀត ដែលកិច្ចប្រតិបត្តិការលើកទី២នេះ កម្លាំងបានឃាត់ខ្លួនបាន៤៥នាក់ ដោយបាននាំខ្លួនទៅកាន់អង្គភាពជំនាញក្នុងខេត្តស្រះកែវ ដើម្បីសាកសួរ។

ជនសង្ស័យបានសារភាពថា ពួកគេសរុបប្រមាណជាង១០០នាក់ ត្រូវបានមេក្លោងខ្មែរ និងថៃ បាននាំលួចឆ្លងដែនតាមខ្សែបន្ទាត់ព្រំដែនក្នុងខេត្តស្រះកែវ ដោយបានបន្តដំណើរលបចូលទៅកាន់តំបន់ហាមឃាត់នេះ ក្នុងគោលបំណងឲ្យកាប់ឈើ និងជញ្ជូនឈើទាំងនេះចេញមកខាងក្រៅ ដោយទទួលបានកម្រៃក្នុងឈើមួយគីឡូក្រាមចំនួនពី១៥០បាត ទៅ២០០ បាត។ បច្ចុប្បន្នសមត្ថកិច្ចកំពុងធ្វើការស្រាវជ្រាវរកមេក្លោង ដែលនៅពីក្រោយខ្នង ដើម្បីនាំខ្លួនយកមកសាកសួរតាមនីតិវិធីច្បាប់៕

## ថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់ផុតទោសដល់សមត្ថកិច្ចកម្ពុជានៅច្រកជាំ

http://www.rasmeinews.com/ November 30, 2017

(ឧត្តរមានជ័យ)៖ ពលរដ្ឋខ្មែរម្នាក់ផុតទោសករណីឆ្លងព្រំដែនចូលកាប់ឈើខុសច្បាប់ត្រូវបានសមត្ថកិច្ចថៃប្រគល់ដល់សមត្ថកិច្ចកម្ពុជាវិញនៅច្រកជាំសាងាំស្រុកអន្លង់វែងកាលពីវេលាម៉ោង១០និង៣២នាទី នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧។ សមត្ថកិច្ចនៅព្រំដែនបានឱ្យដឹងថាពលរដ្ឋខ្មែរម្នាក់តាមច្រកអន្តរជាតិជាំសាងាំមាន ឈ្មោះ ឈឹម ជឹម ភេទប្រុស អាយុ ១៥ ឆ្នាំ រស់នៅភូមិអូរស្វាយឃុំអូរស្វាយស្រុកត្រពាំងប្រាសាទ។ថៃចាប់ខ្លួនកាលពីថ្ងៃទី១០ខែកញ្ញាឆ្នាំ២០១៧ពីបទឆ្លងដែនកាប់ឈើក្រញូងក្នុងដីថៃ ចូលតាមច្រកអូរស្វាយ ជាប់គុកនៅខេត្តអូរប៊ុន ប្រទេសថៃ ។ÍS/ដោយ៖សហការី

## តើកិច្ចព្រមព្រៀងការពារពលករអាស៊ាន អាចធានាផលប្រយោជន៍ដល់ពលករខ្មែរដែរទេ?

https://thmeythmey.com 29, Nov 2017 , 7:39 pm ដោយ: រំដួល ចិត្រា (Romdoul Chetra)

ភ្នំពេញ៖ ប្រមុខរដ្ឋាភិបាលអាស៊ាន បានចុះហត្ថលេខារួមគ្នាលើកិច្ចព្រមព្រៀងការពារពលករចំណាកស្រុកអាស៊ាន កាលពីថ្ងៃទី១៣ -១៤ វិច្ឆិកា ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១ នៅប្រទេសហ្វីលីពីនកន្លងមក។ ខ្លឹមសារដែលម្ចាស់ប្រទេសបញ្ជូន និងទទួលយកពលករក្នុងតំបន់អាស៊ាន ត្រូវអនុវត្តនោះ គឺការការពារអត្ថប្រយោជន៍ពលករចំណាកស្រុក (ទេសន្តរប្រវេសន៍) ដូចជាលើកកម្ពស់សិទ្ធិការងារ សុវត្ថិភាព និងផ្តល់ប្រាក់បៀវត្សឲ្យបានត្រឹមត្រូវជាដើម។

ប៉ុន្តែលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មិនទាន់ប្រាកដថា កិច្ចព្រមព្រៀងការពារពលករចំណាកស្រុកអាស៊ាននេះ អាចធានាភាពត្រឹមត្រូវដល់ពលករចំណាកស្រុកបាន១០០ភាគរយ ឬអត់នោះទេ ដោយសារតែវាអាស្រ័យទៅលើការចូលរួមអនុវត្តរបស់បណ្តាប្រទេសនីមួយៗ ក្នុងតំបន់អាស៊ាន (អាស៊ានគ្មានអំណាចបង្ខំឲ្យរដ្ឋជាសមាជិកធ្វើតាមខ្លួនទេ)។

បើទោះជាកិច្ចព្រមព្រៀងនេះ មិនមានអំណាចគតិយុត្តិក្តី តែកម្ពុជាបានត្រៀមខ្លួន និងបានសហការការពារពលករខ្មែរ ដែលចំណាកស្រុកនេះ ជាមួយបណ្តាប្រទេសក្នុងអាស៊ានរួចហើយ។នេះបើតាមលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ស្វែងយល់ពីច្បាប់ការងារថៃ

http://www.pheaktraprak.com/ November 28 at 11:10pm · Prak PheakTra

បច្ចុប្បន្ននេះច្បាប់ការងារប្រទេសថៃ បានហាមឃាត់មិនឱ្យពលករខ្មែរ ធ្វើការលក់ដូរក្នុងផ្សារឬតាមភោជនីយដ្ឋាន,និងផ្សេងទៀតជាដាច់ខាត។

-ករណីពលករខ្មែរធ្វើការលក់ដូរគឺខុសច្បាប់ នៅពេលត្រូវសមត្ថកិច្ចថៃចាប់ (ត្រូវមានទោស)ផាកពិន័យជាប្រាក់1000បាត-100,000បាត ឬត្រូវជាប់ពន្ធនាគាររយៈពេល5 ឆ្នាំ។

-ករណីថៅកែថៃជួលពលករខ្មែរឱ្យធ្វើការលក់ដូរ គឺខុសច្បាប់ នៅពេលត្រូវសមត្ថកិច្ចថៃចាប់(ត្រូវមានទោស)ផាកពិន័យជាប្រាក់400.000បាត-800.000បាតក្នុងពលករម្នាក់។

## ក្រសួងការងារថៃ ជឿជាក់ថាការត្រួតសញ្ជាតិ របស់ពលករទាំងបីសញ្ជាតិ ទាន់ពេលកំណត់100%

http://www.pheaktraprak.com/ November 28, 2017

ក្នុងកិច្ចផ្តល់បទសម្ភាសន៍មួយរបស់លោក Jarin Jakapa អគ្គនាយកនៃក្រសួងការងារថៃ តាមរយៈវិទ្យុ FM.101 Radio Report កាលពីថ្ងៃទី24 ខែវិច្ឆិកា ឆ្នាំ2017 កន្លងទៅនេះ លោកអគ្គនៃក្រសួងការងារបានមានប្រសាសន៍ថា ក្រសួងការងារថៃ ចូលចាត់លេខរៀងជូនពលករកម្ពុជា, ភូមា, ឡាវ នៅពេលឆាប់ៗខាងមុខនេះ នៅតាមទីតាំងបញ្ជាក់អត្តសញ្ញាណនីមួយៗ របស់ក្រុមការងារផ្តល់ភាពស្របច្បាប់ជូនពលករក្នុងប្រទេសថៃ។

ការលើកឡើងដូច្នេះបន្ទាប់ពីរយៈពេលបញ្ជាក់អត្តសញ្ញាណជូនពលករទាំងសញ្ជាតិនាពេលកន្លងមកមានភាពយឺតយ៉ាវ អាចធ្វើអោយពលករបញ្ជាក់អត្តសញ្ញាណ មិនទាន់សភាពការណ៍ដែលខាងក្រសួងការងារកំណត់ ចំពោះបញ្ហាផ្តល់លេខរៀងជូនពលករវិញខាងភាគីក្រសួងការងារថៃ និងផ្តល់ជូនតាមរយៈនិយោជិតអោយសំស្របទៅតាមតំបន់ខេត្តដែលមានពលករធ្វើការរស់នៅច្រើន។

បច្ចុប្បន្នពលករ(ឈ្មោះថ្មី)ដែលមិនទាន់ត្រួតសញ្ជាតិមានប្រមាណជាង40ម៉ឺននាក់ និងពលករមានប័ណ្ណស៊ីជម្ពូមិនត្រួតសញ្ជាតិមានប្រមាណ1 លាននាក់ ហើយក្នុងករណីបញ្ជាក់អត្តសញ្ញាណជូនពលករមានលិខិតបញ្ជាក់ពី

ក្រសួង(អ្នកចុះឈ្មោះថ្មី)មិនទាន់ពេលកំណត់ ក្រសួងនិងធ្វើច្បាប់ស្នើទៅក្រសួងមហាផ្ទៃថៃ ដើម្បីបន្ថែមរយៈពេលចំនួនបីខែបន្តទៅមុខទៀតដើម្បីអោយពលករបានបញ្ជាក់អត្តសញ្ញាណទាន់ពេលវេលាដែលបានកំណត់។

## ពលករខ្មែរធ្វើការសន្តិសុខយាម ពេលយប់ម្នាក់ ត្រូវកម្មករសំណង់ព្រួតគ្នាកាប់ឲ្យរងរបួសធ្ងន់

http://www.pheaktraprak.com/ November 28, 2017

កាលពីថ្ងៃច័ន្ទ ទី27 ខែវិច្ឆិកា ឆ្នាំ2017កន្លងទៅ មានករណីបុរសពលករខ្មែរធ្វើការសន្តិសុខយាមនៅការដ្ឋានសំណង់មួយកន្លែង ក្នុងតំបន់ប៉ាតាយ៉ា-ចមធៀនត្រូវក្រុមមេការសំណងនិងបក្សពួកដេញកាប់បណ្តាលអោយរងរបួសធ្ងន់ ករណីខាងលើនេះបានកើតឡើងនៅវេលាម៉ោង10យប់ នៅត្រង់បរិវេណការដ្ឋានសំណង់មួយស្ថិតនៅតំបន់ប៉ាតាយ៉ា-ចមធៀន ស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ។

យោងតាមប្រភពពីកន្លែងកើតហេតុ បានឲ្យដឹងថាជនរងគ្រោះមានឈ្មោះ បែង អាយុ 22ឆ្នាំ សញ្ជាតិខ្មែរ ធ្វើការជាសន្តិសុខយាមយប់ បានរងរបួសក្បាលជាច្រើនកន្លែង បន្ទាប់ពីត្រូវជនដៃដល់ ជាមេការសំណង់ស្នាក់នៅក្នុងការដ្ឋានកើតហេតុរួមជាមួយបក្សពួកយកដាវសាម៉ូរ៉ៃកាប់មកលើជនរងគ្រោះបណ្តាលរងរបួសធ្ងន់។ បើតាមការរៀបរាប់របស់ជនរងគ្រោះបានប្រាប់ថា កាលពីពេលថ្ងៃ ជនរងគ្រោះនិងបក្សពួកបាននាំគ្នាចូលទៅលេង ការដ្ឋានខាងលើហើយមានរឿងឈ្លោះគ្នាជាមួយក្រុមជនដៃដល់ជាមេការសំណង់ លុះដល់ពេលល្ងាចឡើងជនរងគ្រោះបានមកចូលវេនយាមនៅត្រង់កន្លែងកើតហេតុ សម្រាប់តែក្រុមគូរជំលោះបានលើកគ្នាប្រដាប់ដោយដាវ,កាំបិត ព្រួតគ្នាកាប់ទៅលើជនរងគ្រោះ ដែលកំពុងឈរយាមបណ្តាលឱ្យរងរបួសបួសធ្ងន់ ក្រោយបង្កហេតុរួចបក្សពួកជនដៃដល់បាននាំគ្នារត់គេចខ្លួនបាត់អស់។

បច្ចុប្បន្នជនរងគ្រោះ ត្រូវបានភ្នាក់ងារសង្គ្រោះស្រុកបាងឡាម៉ុងបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យបាងឡាម៉ុង ចំណែកឯជនដៃដល់កម្លាំងសមត្ថកិច្ចតម្រួតក្រុងប៉ាតាយ៉ាបានតាមស្រាវជ្រាវឃាត់ខ្លួនបានជនសង្ស័យ2នាក់ទៅធ្វើការសាកសួរដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ពលរដ្ឋខ្មែរ១៧នាក់ ត្រូវបានទូតអន្តរាគមន៍ពី ម៉ាឡេស៊ី និងវៀតណាម ឲ្យវិលត្រឡប់មកកាន់ស្រុកកំណើតវិញ

http://ann.com.kh/site/news/ ថ្ងៃព្រហស្បតិ៍, 30 ខែវិច្ឆិកា 2017 10:23 ព្រឹក

**រាជធានីភ្នំពេញ៖** ស្ថានទូតតំណាងកម្ពុជា កាលពីពេលថ្មីៗនេះ បានអន្តរាគមន៍ជួយដល់ពលរដ្ឋខ្មែរ១៧នាក់ ដែលទៅបម្រើការនៅប្រទេសម៉ាឡេស៊ី និងវៀតណាម ដោយខុសច្បាប់ឲ្យបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ យោងតាមសេចក្តីប្រកាសព័ត៌មានមួយ កាលពីថ្ងៃទី២៩ វិច្ឆិកា ម្សិលមិញ របស់ការិយាល័យអ្នកនាំពាក្យក្រសួងការបរទេសឲ្យដឹងថា ពលករ និងពលការិនីខ្មែរ៤នាក់ ដែលទៅបម្រើការងារជាកម្មកររោងចក្រ និងអ្នកបម្រើតាមផ្ទះ នៅប្រទេសម៉ាឡេស៊ី ដោយខុសច្បាប់តាមរយៈមេខ្យល់ ត្រូវបានស្ថានទូតចេញលិខិតធ្វើដំណើរ និងសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពួកគេ បានវិលត្រឡប់មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាចុងខែវិច្ឆិកានេះ។

ចំណែកស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ ក៏បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍ ពលរដ្ឋខ្មែរ១៣នាក់ ដែលចូលទៅស្នាក់នៅ និងប្រកបរបរលក់ឆ្នោតនៅវៀតណាមផងដែរ។ ដែលអ្នកទាំងនោះ មកពីខេត្តស្វាយរៀង មានអាយុចន្លោះពី១ឆ្នាំដល់៧០ឆ្នាំ (កុមារចំនួន៨នាក់) ហើយអាជ្ញាធរវៀតណាមបានរៀបចំអោយស្នាក់នៅបណ្តោះអាសន្ន ក្នុងមជ្ឈមណ្ឌលគាំពារសង្គមទីក្រុងហូជីមិញ មុនពេលបញ្ជូនមកស្ថានអគ្គកុងស៊ុល និងបន្តមកស្រុកកំណើតវិញ តាមច្រកអន្តរជាតិបាវិត កាលពីថ្ងៃទី២៩ វិច្ឆិកា ម្សិលមិញ នោះ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ១៧នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមជួយដោះស្រាយបញ្ហារបស់ពលរដ្ឋខ្មែរចំនួន**៤នាក់** តាមសំណើរបស់សាម៉ីខ្លួន ដូចខាងក្រោម៖

(១) ពលការិនី **លឿង ធីតា** អាយុ៣០ឆ្នាំ មកពីខេត្តក្រចេះ បានធ្វើដំណើរទៅម៉ាឡេស៊ីដោយខ្លួនឯង និងបានធ្វើការងារតាមផ្ទះ នៅឆ្នាំ២០១២ ប៉ុន្តែបានឈប់ពីការងារនៅឆ្នាំ២០១៦ បន្ទាប់ពីសម្រាលកូនស្រីម្នាក់។

(២) ពលករ **ឡឹប ដារ៉ាហ៊ឿន** អាយុ៣០ឆ្នាំ មកពីខេត្តបាត់ដំបង បានទៅធ្វើការនៅរោងចក្រឈើនៅរដ្ឋ Selangor ប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០១៤ តាមរយៈមេខ្យល់។

(៣) ពលការិនីឈ្មោះ **ម៉េង ខ្លី** អាយុ២៣ឆ្នាំ មកពីខេត្តកំពង់ចាម បានទៅម៉ាឡេស៊ី ធ្វើការជាអ្នកបោសសំអាត នៅឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ នាងបានស្នើសុំស្ថានទូតជួយទាមទារប្រាក់ខែដែលខ្វះពីនិយោជក ហើយក្រោយស្ថានទូតធ្វើអន្តរាគមន៍ ពលការិនីបានទទួលប្រាក់ខែគ្រប់ចំនួននិងលិខិតឆ្លងដែនវិញ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

ស្ថានទូតបានចេញលិខិតធ្វើដំណើរ និងសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលរដ្ឋខ្មែរទាំង៤នាក់ បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** ក្នុងចុងខែវិច្ឆិកានេះ។

២. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**ហូជីមិញ** បានសហការជាមួយអាជ្ញាធរវៀតណាម រៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ**១៣នាក់** ដែលចូលទៅស្នាក់នៅ និងប្រកបរបរលក់ឆ្នោតនៅវៀតណាម។ ពលរដ្ឋទាំងនោះ មកពីខេត្តស្វាយរៀង មានអាយុចន្លោះពី១ឆ្នាំដល់៧០ឆ្នាំ(កុមារចំនួន៨នាក់) ហើយអាជ្ញាធរវៀតណាមបានរៀបចំអោយស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលគាំពារសង្គមទីក្រុងហូជីមិញ មុនពេលបញ្ជូនមកស្ថានអគ្គកុងស៊ុល។

ស្ថានអគ្គកុងស៊ុល បានជូនពលរដ្ឋទាំង១៣នាក់ មកកម្ពុជាវិញ នៅថ្ងៃទី**២៩** ខែ **វិច្ឆិកា** ឆ្នាំ **២០១៧** តាមច្រកទ្វារព្រំដែនអន្តរជាតិ**បាវិត** ដើម្បីប្រគល់ជូនអាជ្ញាធរកម្ពុជា ចាត់ចែងបញ្ជូនបន្តទៅស្រុកកំណើត។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ